# ព្រឹទ្ធសភា
SENATE MAGAZINE

ទស្សនាវដ្ដីខែមីនា








លេខ ៣០៥ ឆ្នាំទី២៦ ព.ស.២៥៦៩ គ.ស.២០២៦

Issue 305 Volume 26 B.E.2569 C.E.2026

# មាតិកា


១


១១


៣០

## ក្របមុខ

- *ឯកឧត្តម **អេឡិចសិនដឺ មីខូវស៊ិន** ឯកអគ្គរដ្ឋទូតស្លូវ៉ាគី ចូលជូនសារតាំងសម្ដេចតេជោ **ហ៊ុន សែន** ប្រមុខរដ្ឋស្ដីទី។*
- *លោកជំទាវ Katharina Wieser ឯកអគ្គរដ្ឋទូតអូទ្រីស ចូលជូនសារតាំងសម្ដេចតេជោ **ហ៊ុន សែន** ប្រមុខរដ្ឋស្ដីទី។*
- *ឯកឧត្តម Sonexay Vannaxay ឯកអគ្គរដ្ឋទូតឡាវ ចូលជូនសារតាំងសម្ដេចតេជោ **ហ៊ុន សែន** ប្រមុខរដ្ឋស្ដីទី។*
- *ឯកឧត្តម **អ៊ុច បូររិទ្ធ** ប្រធានស្ដីទីព្រឹទ្ធសភា និងលោកជំទាវ អញ្ជើញស្រោចសុគន្ធវារីប្រគេនព្រះវិរិយានុបាល **សេខ ពេជ្រ** នៅវត្តព្រះអង្គកងជុំ (ហៅវត្តព្រះអង្គខ្មៅ) ខេត្តសៀមរាប។*
- *ឯកឧត្តមបណ្ឌិត **ធន់ ខឡុនា** អនុប្រធានទី២ព្រឹទ្ធសភា អញ្ជើញចុះទស្សនកិច្ចចម្ការកាហ្វេ PIDA នៅមណ្ឌលគិរី៕*

## អ្នកគ្រប់គ្រងទូទៅ
ឯកឧត្តម ឡាយ សំកុល

## អ្នកសម្រួលខ្លឹមសារ និងអក្ខរាវិរុទ្ធ
ឯកឧត្តម ខេង សិទ្ធិគុណ
ឯកឧត្តម ជាម សុផលមករា
ឯកឧត្តម ជួន ណា
លោក ជួន សុខជី
លោក ទេព មករា
លោក កុក វ៉ៃ
លោក សុង សុខភារ័ត្ន

## អ្នកគ្រប់គ្រងផ្ទាល់
លោក ទេព មករា

## ក្រុមអ្នកយកព័ត៌មាន
ការិយាល័យព័ត៌មាន

## ភារីកុំព្យូទ័រ
លោក ជុំ ច័ន្ទរតនា
លោកស្រី សុខ សុជាតា

## សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភា ( ១-៣៣ )


- សម្ដេចតេជោ **ហ៊ុន សែនៈ** កម្ពុជានឹងធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំកំពូលហ្វ្រង់កូហ្វូនីឱ្យបានជោគជ័យ ........ ១
- សម្ដេចតេជោ **ហ៊ុន សែន** អនុញ្ញាតឱ្យឯកអគ្គរដ្ឋទូតអូទ្រីស ចូលជូនសារតាំង និងសម្ដែងការគួរសម........ ៣
- សម្ដេចតេជោ **ហ៊ុន សែនៈ** នយោបាយ ការទូត ពាណិជ្ជកម្ម ជាវិស័យជំរុញចំណងមិត្តភាពកម្ពុជានិងសិង្ហបុរី ........ ៥
- សម្ដេចតេជោ **ហ៊ុន សែន** អនុញ្ញាតឱ្យសមាជិកក្រុមប្រឹក្សាភិបាលនៃគណបក្ស AFD មូលដ្ឋាន ប្រចាំទីក្រុង Karlsruhe ប្រទេសអាល្លឺម៉ង់ ចូលជួបសម្ដែងការគួរសម........ ៧
- សម្ដេចតេជោ **ហ៊ុន សែនៈ** កម្ពុជានិងដាណឺម៉ាកនៅមានសក្ដានុពលជាច្រើនទៀត ដែលភាគីទាំងពីរអាចធ្វើការជាមួយគ្នា ........ ៨
- សម្ដេចតេជោ **ហ៊ុន សែន** ចាត់ទុកទំនាក់ទំនងពាណិជ្ជកម្ម សេដ្ឋកិច្ច ធុរកិច្ច និងការវិនិយោគជាចំណុចស្នូលនៃទំនាក់ទំនងកម្ពុជា-ស្លូវ៉ាគី ក្រៅពីការទូត និងនយោបាយ ........ ៩
- កម្ពុជា-ឡាវ គួរតែបន្តពង្រីកសហប្រតិបត្តិការលើវិស័យពាណិជ្ជកម្ម សេដ្ឋកិច្ច និងការវិនិយោគ ដើម្បីគាំទ្រដល់ទំនាក់ទំនងនយោបាយ និងការទូត ... ១០
- ឯកឧត្តម **អ៊ុច បូររិទ្ធ** អញ្ជើញសំណេះសំណាលជាមួយសមាជិកាព្រឹទ្ធសភា មន្ត្រីរាជការជាស្ត្រី និងនិវត្តជននារី នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ក្នុងឱកាសអបអរសាទរខួបលើកទី១១៥ ទិវាអន្តរជាតិនារី ៨មីនា ........ ១១
- ឯកឧត្តម **អ៊ុច បូររិទ្ធ** អញ្ជើញជាអធិបតីក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាឆ្នាំ២០២៥ និងទិសដៅការងារឆ្នាំ២០២៦ ........ ១៤
- ឯកឧត្តម **អ៊ុច បូររិទ្ធ** អញ្ជើញចុះសួរសុខទុក្ខនិងនាំយកអំណោយរបស់សម្ដេចតេជោ ជូនវីរកងទ័ពជួរមុខនៅទិសខេត្តព្រះវិហារ ខេត្តឧត្តរមានជ័យ ខេត្តពោធិ៍សាត់ និងទិសយោធភូមិភាគទី៤ ........ ១៦
- ឯកឧត្តម **អ៊ុច បូររិទ្ធ** អញ្ជើញជាអធិបតីក្នុងពិធីចម្រើនអាយុវឌ្ឍនមង្គល សម្ពោធឆ្លងកុដិ និងបុណ្យផ្កាប្រាក់សាមគ្គី នៅវត្តព្រះអង្គកងជុំ ខេត្តសៀមរាប ........ ១៨
- ឯកឧត្តម **អ៊ុច បូររិទ្ធ** អញ្ជើញជួបសំណេះសំណាល និងចែកកញ្ចប់អាហារស្រាយបួសខែរ៉ាម៉ាឌនជូនប្រជាពលរដ្ឋខ្មែរអ៊ិស្លាម ប្រមាណជាង៤០០គ្រួសារ នៅក្រុងកំពង់ចាម និងស្រុកកងមាស..... ២០
- ឯកឧត្តម **អ៊ុច បូររិទ្ធ** អញ្ជើញចុះជួបសំណេះសំណាលជាមួយសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ និងមន្ត្រីអាជ្ញាធរមូលដ្ឋានគ្រប់ជាន់ថ្នាក់ នៅទូទាំងក្រុង ស្រុកទាំង១០ ក្នុងខេត្តកំពង់ចាម........ ២២
- ឯកឧត្តម **អ៊ុច បូររិទ្ធ** អនុញ្ញាតឱ្យអគ្គលេខាធិការរដ្ឋសភាហុងគ្រី ចូលជួបសម្ដែងការគួរសម........ ២៤
- ឯកឧត្តម **អ៊ុច បូររិទ្ធ** អនុញ្ញាតឱ្យឯកឧត្តមឯកអគ្គរដ្ឋទូត នៃសាធារណរដ្ឋកូរ៉េប្រចាំកម្ពុជា ចូលជួបសម្ដែងការគួរសម និងពិភាក្សាការងារ........ ២៥
- ឯកឧត្តមបណ្ឌិត **ធន់ ខឡុនា** ជំរុញការអភិវឌ្ឍ «កសិ-ទេសចរណ៍» និងលើកកម្ពស់ជំណាំយុទ្ធសាស្ត្រនៅភូមិភាគឦសាន ........ ២៧
- ឯកឧត្តមបណ្ឌិត **ធន់ ខឡុនា** មានប្រសាសន៍ថា អាទិភាពសម្រាប់សេដ្ឋកិច្ចកម្ពុជាបច្ចុប្បន្ន គឺវិស័យទេសចរណ៍និងកម្មន្តសាល ........ ២៩
- ឯកឧត្តមបណ្ឌិត **ធន់ ខឡុនា** ជំរុញយុទ្ធសាស្ត្រ «ដំណោះស្រាយដោយខ្មែរ» ដើម្បីពង្រឹងភាពធន់សេដ្ឋកិច្ច និងអធិបតេយ្យភាពជាតិ........ ៣០
- កម្ពុជាប្ដេជ្ញាលុបបំបាត់បទល្មើសឆបោកអនឡាញ និងជំរុញសេដ្ឋកិច្ចស្អាត ប្រកបដោយបរិយាបន្ន........ ៣២
- សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភាចូលរួមពិធីផ្សេងៗ ........ ៣៣


## សកម្មភាពគណៈកម្មការនានារបស់ព្រឹទ្ធសភា ( ៣៤-៧០ )


- គណៈកម្មការទី១ព្រឹទ្ធសភាជួបពិភាក្សាការងារជាមួយថ្នាក់ដឹកនាំក្រសួងអធិការកិច្ច ........ ៣៤
- គណៈប្រតិភូគណៈកម្មការទី៣ព្រឹទ្ធសភា អញ្ជើញជួបពិភាក្សាការងារជាមួយរដ្ឋបាលខេត្តកំពត ........ ៣៦
- សន្តិភាពមិនមែនជាការចៃដន្យនោះទេ ប៉ុន្តែគឺជាផលនៃធន្ទះរួម និងការលះបង់ដ៏ខ្ពង់ខ្ពស់របស់យើងទាំងអស់គ្នា........ ៣៨
- ឯកឧត្តមបណ្ឌិត **ឈិត ឈីស៊ាង** វាយតម្លៃខ្ពស់ចំពោះសមិទ្ធផលនិងទិសដៅការងាររបស់ក្រសួងព័ត៌មាន ដែលជាបច្ច័យយ៉ាងសំខាន់ក្នុងការបន្តការពារផលប្រយោជន៍ជាតិនិងប្រជាជន........ ៤០
- គណៈកម្មការទី៦ព្រឹទ្ធសភា ចុះឈ្វេងយល់ការងារពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ចរបស់ខ្លួន នៅខេត្តកំពង់ស្ពឺ និងខេត្តកោះកុង ........ ៤២
- គណៈប្រតិភូគណៈកម្មការទី៧ព្រឹទ្ធសភា អញ្ជើញជួបពិភាក្សាការងារជាមួយថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា ........ ៤៤
- គណៈប្រតិភូគណៈកម្មការទី៩ព្រឹទ្ធសភា អញ្ជើញចុះឈ្វេងយល់វិស័យពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់ខ្លួន នៅខេត្តកំពត និងខេត្តស្វាយរៀង ........ ៤៦
- ឯកឧត្តម **ម៉ុល លឹម** លើកទឹកចិត្តដល់រដ្ឋបាលស្រុកនិងក្រុមប្រឹក្សាឃុំទាំងអស់ បន្តខិតខំលើកកម្ពស់ការបំពេញតួនាទី និងភារកិច្ចរបស់ខ្លួន ប្រកបដោយការទទួលខុសត្រូវខ្ពស់ ........ ៤៨
- ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៦ អញ្ជើញចុះជួបសំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំ នៅខេត្តព្រៃវែង និងខេត្តស្វាយរៀង ........ ៥០
- ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៧ អញ្ជើញជួបសំណេះសំណាលជាមួយអាជ្ញាធរមូលដ្ឋានខេត្តកំពង់ស្ពឺ........ ៥២
- ឯកឧត្តម **ឈួន ឆាមៈ** ពិធីសំណេះសំណាលនឹងផ្ដល់នូវធាតុចូលជាគុណតម្លៃដ៏ល្អប្រសើរជូនអាជ្ញាធរពាក់ព័ន្ធជំរុញការអនុវត្តការងារនៅថ្នាក់ក្រោមជាតិ........ ៥៤
- ឯកឧត្តម **យស ផានីត្តា** ធ្វើបទបង្ហាញជូនសាស្ត្រាចារ្យ និងនិស្សិត នៃសាកលវិទ្យាល័យអាម៉េរិកកាំងភ្នំពេញ ក្នុងឱកាសទស្សនកិច្ចសិក្សាស្វែងយល់អំពីព្រឹទ្ធសភា ........ ៥៦
- កិច្ចប្រជុំគណៈកម្មការទាំង១០ ក្រុមភូមិភាគ និងក្រុមនានានៃព្រឹទ្ធសភា........ ៥៨
- ការទទួលពាក្យបណ្ដឹង ........ ៦០
- សមាជិក សមាជិកាព្រឹទ្ធសភាបំពេញការងារនៅតាមបណ្ដាភូមិភាគទាំង៨........ ៦១
- សមាជិក សមាជិកាព្រឹទ្ធសភាចូលរួមពិធីផ្សេងៗ........ ៦៨


## សកម្មភាពអគ្គលេខាធិការដ្ឋាន ( ៧១-៧២ )


- សកម្មភាពថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចូលរួមពិធីផ្សេងៗ........ ៧១

# សម្តេចតេជោ ហ៊ុន សែន៖ កម្ពុជានឹងធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំកំពូលហ្វ្រង់កូហ្វូនីឱ្យបានជោគជ័យ



*លោកជំទាវ ល្វីស មូស៊ីគីវ៉ាបូ និងសម្តេចតេជោ ហ៊ុន សែន*

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រមុខរដ្ឋស្តីទី នៃព្រះរាជាណាចក្រកម្ពុជា បានមានប្រសាសន៍ថា ទោះបីស្ថានការណ៍ពិភពលោកបច្ចុប្បន្នកំពុងប្រឈមនឹងភាពស្មុគស្មាញក៏ពិតមែន ប៉ុន្តែតាមរយៈនៃកិច្ចប្រជុំកំពូលហ្វ្រង់កូហ្វូនីដែលកម្ពុជានឹងធ្វើជាម្ចាស់ផ្ទះនោះ នឹងទទួលបានជោគជ័យល្អប្រសើរនិងក្លាយជាព្រឹត្តិការណ៍ដែលមានអត្ថន័យដ៏សំខាន់ក្នុងប្រវត្តិសាស្ត្ររបស់កម្ពុជា ព្រមទាំងក្នុងប្រវត្តិសាស្ត្រនៃកិច្ចប្រជុំកំពូលហ្វ្រង់កូហ្វូនីផងដែរ។

**សម្តេចតេជោ** លើកឡើងដូចនេះ ក្នុងឱកាសដែលអនុញ្ញាតឱ្យលោកជំទាវ **ល្វីស មូស៊ីគីវ៉ាបូ** (Louise Mushikiwabo) អគ្គលេខាធិការអង្គការអន្តរជាតិនៃក្រុមប្រទេសនិយាយភាសាបារាំង ចូលជួបសម្តែងការគួរសម នៅវិមានសាមគ្គីភាព នៃព្រឹទ្ធសភា នាព្រឹកថ្ងៃទី២ ខែមីនា ឆ្នាំ២០២៦។

**សម្តេចតេជោ** បានស្វាគមន៍និងចាត់ទុកការបំពេញទស្សនកិច្ចនៅកម្ពុជាសាជាថ្មីរបស់លោកជំទាវ Louise Mushikiwabo ជាផ្នែកមួយដ៏សំខាន់ក្នុងការចូលរួមចំណែកលើកទឹកចិត្តនិងគាំទ្រកម្ពុជាក្នុងការរៀបចំកិច្ចប្រជុំ



*ទិដ្ឋភាពក្នុងជំនួបសម្តែងការគួរសម*



*ទិដ្ឋភាពក្នុងជំនួបសម្តែងការគួរសម*

កំពូលហ្វ្រង់កូហ្វូនី ដែលគ្រោងធ្វើឡើងនៅក្នុងអំឡុងខែវិច្ឆិកា ឆ្នាំ២០២៦។

ក្នុងឱកាសនោះ លោកជំទាវ Louise Mushikiwabo បានសម្តែងនូវអំណរគុណចំពោះ**សម្តេចតេជោ**និងបានកោតសរសើរពីភាពរីកចម្រើនរបស់កម្ពុជា ជាពិសេសអាកាសយានដ្ឋានអន្តរជាតិតេជោ ជាអាកាសយានដ្ឋានថ្មីរបស់កម្ពុជា ដែលមានភាពស្រស់ស្អាត កំពុងរង់ចាំទទួលស្វាគមន៍ប្រតិភូថ្នាក់ដឹកនាំបណ្តាប្រទេសនៃអង្គការអន្តរជាតិហ្វ្រង់កូហ្វូនី អញ្ជើញមកចូលរួមកិច្ចប្រជុំកំពូលហ្វ្រង់កូហ្វូនី នាពេលខាងមុខ។ លោកជំទាវ ក៏បានបញ្ជាក់អំពីការប្តេជ្ញាចិត្តក្នុងការចូលរួមសហការជាមួយកម្ពុជា ដើម្បីគាំទ្រការរៀបចំកិច្ចប្រជុំកំពូលនេះ។ លោកជំទាវបានចាត់ទុកកម្ពុជា ជាប្រទេសមួយដែលបានចូលរួមចំណែកដ៏សកម្មក្នុងអង្គការអន្តរជាតិហ្វ្រង់កូហ្វូនី ព្រមទាំងបានកោតសរសើរភាពជាអ្នកដឹកនាំរបស់**សម្តេចតេជោ** តាំងពីអតីតកាល ក្នុងការស្វែងរកនិងថែរក្សាសន្តិភាព ធ្វើឱ្យប្រទេសមានស្ថិរភាពដល់សព្វថ្ងៃ។ សម្រាប់បរិបទប្រទេសកម្ពុជា លោកជំទាវក៏បានតាមដានផងដែរអំពីបញ្ហាព្រំដែនកម្ពុជានិងថៃនិងមានបំណងចង់ទៅសួរសុខទុក្ខបងប្អូនជនភៀសខ្លួននៅព្រំដែនផងដែរ ។

**សម្តេចតេជោ** បានសម្តែងការពេញចិត្តចំពោះការលើកឡើងរបស់លោកជំទាវ ហើយបានបញ្ជាក់ថា កម្ពុជាត្រៀមរួចជាស្រេចក្នុងការទទួលស្វាគមន៍ប្រតិភូអង្គការហ្វ្រង់-កូហ្វូនីនៅពេលខាងមុខ។ **សម្តេច**ក៏សង្ឃឹមថា លោកជំទាវនឹងបន្តគាំទ្រកម្ពុជា ក្នុងការធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំកំពូលនេះឱ្យទទួលបានជោគជ័យ។ **សម្តេចតេជោ** ក៏បានផ្ញើសារតាមរយៈលោកជំទាវថា សូមឱ្យថ្នាក់ដឹកនាំដែលត្រូវអញ្ជើញមកចូលរួមក្នុងកិច្ចប្រជុំនាពេលខាងមុខ សូមកុំមានការព្រួយបារម្ភ ដ្បិតតែកម្ពុជាមានបញ្ហាជម្លោះព្រំដែនជាមួយថៃ ប៉ុន្តែមិនជះឥទ្ធិពលដល់កិច្ចប្រជុំកំពូលដ៏មានសារៈសំខាន់នេះទេ។ **សម្តេច**បានចាត់ទុកដំណើរទស្សនកិច្ចរបស់លោកជំទាវនៅកម្ពុជា ជាពិសេសការគ្រោងទៅសួរសុខទុក្ខបងប្អូនភៀសសឹក គឺជាការបង្ហាញយ៉ាងច្បាស់នូវជំហររបស់លោកជំទាវក្នុងការគាំទ្រដល់សន្តិភាពដែលមិនចង់ឃើញសង្គ្រាមកើតឡើង។

ជាចុងក្រោយ **សម្តេចតេជោ** បានជូនពរលោកជំទាវនិងប្រតិភូ ទទួលបានជោគជ័យក្នុងដំណើរបំពេញទស្សនកិច្ចនៅកម្ពុជា៕

ប្រភព៖ Telegram Channel សម្តេចតេជោ

រូបភាព, សម្រួលខ្លឹមសារ៖ នាយកដ្ឋានព័ត៌មាន

# សម្តេចតេជោ ហ៊ុន សែន អនុញ្ញាតឱ្យឯកអគ្គរដ្ឋទូតអូទ្រីស ចូលជូនសារតាំង និងសម្តែងការគួរសម

នៅវិមានសាមគ្គីភាព នៃព្រឹទ្ធសភា នាព្រឹកថ្ងៃពុធ ទី៤ ខែមីនា ឆ្នាំ២០២៦ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រមុខរដ្ឋស្តីទី នៃព្រះរាជាណាចក្រកម្ពុជា បានអនុញ្ញាតឱ្យ លោកជំទាវ Katharina Wieser ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព នៃសាធារណរដ្ឋអូទ្រីស ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ចូលជូនសារតាំងនិងសម្តែងការគួរសម។



*លោកជំទាវ Katharina Wieser ចូលជូនសារតាំងសម្តេចតេជោ ហ៊ុន សែន*

នៅក្នុងជំនួបនោះ **សម្តេចតេជោ** បានស្វាគមន៍ និងចាត់ទុកវត្តមានដ៏ឆាប់រហ័សរបស់លោកជំទាវ Katharina Wieser មកកាន់តំណែងជាឯកអគ្គរដ្ឋទូតប្រចាំកម្ពុជា គឺបញ្ជាក់យ៉ាងច្បាស់ថា អូទ្រីសបានផ្តល់តម្លៃខ្ពស់ចំពោះទំនាក់ទំនងរវាងកម្ពុជា និងអូទ្រីស។ **សម្តេច**សង្ឃឹមថា ក្នុងបេសកកម្មរបស់លោកជំទាវ នឹងញ៉ាំងឱ្យទំនាក់ទំនងកម្ពុជា និងអូទ្រីសកាន់តែរីកចម្រើនបន្តទៀត។



*សម្តេចតេជោ ហ៊ុន សែន ប្រមុខរដ្ឋស្តីទី*

នៅក្នុងឱកាសនោះ **លោកជំទាវឯកអគ្គរដ្ឋទូត** បានអរគុណ**សម្តេចតេជោ** ដែលអនុញ្ញាតឱ្យលោកជំទាវ ចូលជូនសារតាំងនិងសម្តែងការគួរសម។ លោកជំទាវបានប្តេជ្ញា



*ទិដ្ឋភាពក្នុងជំនួបសម្តែងការគួរសម*

ចំពោះមុខ**សម្តេចតេជោ**ថា នឹងខិតខំប្រឹងប្រែងក្នុងការពូនជ្រំនូវទំនាក់ទំនងរវាងកម្ពុជា និងអូទ្រីស ឱ្យកាន់តែរីកចម្រើន។ លោកជំទាវបានលើកឡើងថា ក្នុងរយៈពេល ៧០ឆ្នាំកន្លងទៅ ពោលគឺចាប់តាំងពីឆ្នាំ១៩៥៦មក ប្រទេសទាំងពីរបានបង្កើតនូវទំនាក់ទំនងជាមួយគ្នាយ៉ាងល្អប្រសើរ ប្រកបដោយភាពជឿជាក់គ្នាទៅវិញទៅមក។

**លោកជំទាវឯកអគ្គរដ្ឋទូត** បានលើកឡើងអំពីសហប្រតិបត្តិការបន្ថែមទៀត ទាំងក្នុងក្របខ័ណ្ឌនយោបាយ ជាពិសេសក្នុងក្របខ័ណ្ឌសេដ្ឋកិច្ច ពាណិជ្ជកម្ម និងការវិនិយោគដោយលោកជំទាវនឹងខិតខំប្រឹងប្រែងជំរុញឱ្យកាន់តែច្រើនឡើង។ លោកជំទាវបានជម្រាបថា នៅពេលខាងមុខនឹងមានធុរជនរបស់អូទ្រីសប្រមាណ១០ក្រុមហ៊ុន នឹងអញ្ជើញមកកាន់ប្រទេសកម្ពុជា ដើម្បីស្វែងរកឱកាសក្នុងការវិនិយោគ។

មកកាន់ប្រទេសកម្ពុជា នាពេលខាងមុខ។

**សម្តេចតេជោ** សង្ឃឹមថា តាមរយៈធុរជននិងការប្តេជ្ញាចិត្តរបស់**លោកជំទាវឯកអគ្គរដ្ឋទូត** នឹងធ្វើឱ្យទំនាក់ទំនងផ្នែកនយោបាយ ជាពិសេសទំហំពាណិជ្ជកម្ម សេដ្ឋកិច្ចនិងការវិនិយោគរវាងប្រទេសទាំងពីរកាន់តែរីកចម្រើនបន្តទៀត។ នៅក្នុងឱកាសនោះផងដែរ **សម្តេចតេជោ** ក៏បានចែករំលែកអំពីបញ្ហាប្រឈមដ៏ស្មុគស្មាញរបស់ពិភពលោកនាពេលបច្ចុប្បន្នជាមួយ**លោកជំទាវឯកអគ្គរដ្ឋទូត** និងបានពន្យល់អំពីស្ថានភាពនៃបញ្ហាព្រំដែនរវាងកម្ពុជានិងថៃដែលកើតឡើងកន្លងទៅ ហើយពេលនេះ ប្រទេសទាំងពីរកំពុងតែខិតខំប្រឹងប្រែងក្នុងការធ្វើយ៉ាងណាអនុវត្តនូវបទឈប់បាញ់ឱ្យបានល្អប្រសើរ ក្នុងការធានានូវស្ថិរភាពតាមព្រំដែននិងការដោះស្រាយបញ្ហាដោយផ្អែកទៅលើទិដ្ឋភាពច្បាប់ និងការចរចាគ្នា។



*ទិដ្ឋភាពក្នុងជំនួបសម្តែងការគួរសម*

ជាការឆ្លើយតប **សម្តេចតេជោ** បានពេញចិត្តចំពោះការលើកឡើងរបស់**លោកជំទាវឯកអគ្គរដ្ឋទូត**ចំពោះទំនាក់ទំនងរវាងប្រទេសទាំងពីរនិងបានឯកភាពចំពោះការពង្រីកនូវទំហំពាណិជ្ជកម្មរវាងកម្ពុជានិងអូទ្រីសឱ្យកាន់តែកើនឡើង ជាពិសេសទាក់ទងនឹងការវិនិយោគដែលធុរជនរបស់អូទ្រីសប្រមាណ១០ក្រុមហ៊ុន គ្រោងនឹង

ជាចុងក្រោយ **សម្តេចតេជោ** បានជូនពរ**លោកជំទាវឯកអគ្គរដ្ឋទូត** ឱ្យបំពេញបេសកកម្មការទូត នៅព្រះរាជាណាចក្រកម្ពុជាទទួលបានជោគជ័យ៕

ប្រភព៖ Telegram Channel សម្តេចតេជោ

រូបភាព, សម្រួលខ្លឹមសារ៖ នាយកដ្ឋានព័ត៌មាន

# សម្តេចតេជោ៖ នយោបាយ ការទូត ពាណិជ្ជកម្ម
# ជាវិស័យជំរុញចំណងមិត្តភាពកម្ពុជានិងសិង្ហបុរី



*សម្តេចតេជោ ហ៊ុន សែន ប្រមុខរដ្ឋស្តីទី ស្វាគមន៍និងបំពាក់គ្រឿងឥស្សរិយយសជូនលោកជំទាវ Teo Lay Cheng*

ទំនាក់ទំនងនយោបាយ ការទូត ពាណិជ្ជកម្ម សេដ្ឋកិច្ច និងការវិនិយោគ ជារឿងដ៏ចាំបាច់ក្នុងការរុញច្រាននូវទំនាក់-ទំនងរវាងកម្ពុជានិងសិង្ហបុរីឱ្យមានភាពល្អប្រសើរ។ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រមុខរដ្ឋស្តីទី នៃព្រះរាជាណាចក្រកម្ពុជា បានលើកឡើងយ៉ាងដូច្នេះ ក្នុងពេលដែលសម្តេចអនុញ្ញាតឱ្យ លោកជំទាវ Teo Lay Cheng ឯកអគ្គរដ្ឋទូត នៃសាធារណរដ្ឋសិង្ហបុរី ប្រចាំនៅព្រះរាជា-ណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសមនិងជម្រាបលា នាថ្ងៃពុធ ទី៤ ខែមីនា ឆ្នាំ២០២៦ នៅវិមានសាមគ្គីភាព នៃព្រឹទ្ធសភា។



ក្នុងឱកាសនោះ សម្តេចតេជោ **ហ៊ុន សែន** បានផ្តល់កិត្តិយសបំពាក់មេដាយសហមេត្រី ថ្នាក់មហាសេរីវឌ្ឍន៍ជូនដល់**លោកជំទាវឯកអគ្គរដ្ឋទូត**និងបានកោតសរសើរចំពោះការខិតខំប្រឹងប្រែងរបស់លោកជំទាវ ក្នុងឋានៈជាឯកអគ្គរដ្ឋទូតសិង្ហបុរីប្រចាំនៅកម្ពុជា ដែលលោកជំទាវបានខិតខំប្រឹងប្រែងក្នុងការពូនជ្រំទំនាក់ទំនងរវាងកម្ពុជានិង



*ទិដ្ឋភាពក្នុងជំនួបសម្តែងការគួរសម*

សិង្ហបុរី ឱ្យមានភាពល្អប្រសើរ។

**លោកជំទាវឯកអគ្គរដ្ឋទូត** បានថ្លែងអំណរគុណចំពោះ **សម្ដេចតេជោ** ដែលបានអនុញ្ញាតឱ្យលោកជំទាវនិងសហការីបានជួបសម្ដែងការគួរសមនិងជម្រាបលា និងបានផ្ដល់កិត្តិយសបំពាក់មេដាយកិត្តិយស។ លោកជំទាវបានបញ្ជាក់ថា នេះជាលើកទី៣ក្នុងអាណត្តិ៥ឆ្នាំ ដែលបានជួបសម្ដែងការគួរសមជាមួយ**សម្ដេចតេជោ** ហើយរាល់ជំនួបតែងតែបានរៀនសូត្រនិងបានស្ដាប់នូវបទពិសោធដ៏កម្រនឹងធ្វើបានដូច**សម្ដេចតេជោ** ដែលបង្កើននូវពុទ្ធិយ៉ាងច្រើនដល់លោកជំទាវផងដែរ។ ជាមួយគ្នានោះ លោកជំទាវក៏បានរំលេចអំពីទំនាក់ទំនងរវាងកម្ពុជានិងសិង្ហបុរី ដែលមានភាពរីកចម្រើនជាបន្តបន្ទាប់ ជាពិសេសនៅក្នុងឆ្នាំកន្លងទៅដែលទំនាក់ទំនងបានកើនឡើងតាមរយៈវិស័យពាណិជ្ជកម្មនិងនយោបាយរីកចម្រើនទៅទន្ទឹមគ្នា។

**សម្ដេចតេជោ** បានសម្ដែងការពេញចិត្តចំពោះការខិតខំរបស់**លោកជំទាវឯកអគ្គរដ្ឋទូត** ក្នុងការពង្រឹងទំនាក់ទំនងរវាងកម្ពុជានិងសិង្ហបុរី។ **សម្ដេចតេជោ** ពេញចិត្តចំពោះទំហំពាណិជ្ជកម្មកម្ពុជានិងសិង្ហបុរី ដែលកើនដល់៥ពាន់លានដុល្លារអាមេរិកនិងសង្ឃឹមថា រដ្ឋាភិបាលទាំងពីរប្រឹងប្រែងដាក់គោលដៅឱ្យកើនដល់១០ពាន់លានដុល្លារអាមេរិកនៅឆ្នាំខាងមុខ។

ក្នុងឱកាសនោះផងដែរ **សម្ដេចតេជោ**បានចែករំលែកបទពិសោធនៃដំណើរការតស៊ូរំដោះជាតិ ការស្វែងរកសន្តិភាព និងអភិវឌ្ឍន៍របស់កម្ពុជា ព្រមទាំងលើកឡើងអំពីស្ថានការណ៍ព្រំដែនកម្ពុជា-ថៃនិងបញ្ហាប្រឈមស្មុគស្មាញរបស់ពិភពលោកបច្ចុប្បន្ន។

**លោកជំទាវឯកអគ្គរដ្ឋទូត** បានថ្លែងអំណរគុណចំពោះ**សម្ដេចតេជោ** ដែលបានចែករំលែកមេរៀននិងទស្សនទានដ៏ល្អៗ និងប្រសិទ្ធនាម**សម្ដេចតេជោ**ថាជា «រដ្ឋបុរសរបស់កម្ពុជា»។ លោកជំទាវបានលើកឡើងពីភាពរីកចម្រើនរបស់កម្ពុជា និងកត្តាសុខសន្តិភាព ក៏ដូចជាអនុស្សាវរីយ៍ល្អៗជាច្រើន ហើយបានហៅកម្ពុជាថាជាប្រទេសដ៏អស្ចារ្យ។

ជាចុងក្រោយ **សម្ដេចតេជោ** បានជូនពរលោកជំទាវ Teo Lay Cheng ឱ្យទទួលបាននូវភាពជោគជ័យជាបន្តបន្ទាប់ទៀត៕

ប្រភព៖ Telegram Channel សម្ដេចតេជោ

រូបភាព, សម្រួលខ្លឹមសារ៖ នាយកដ្ឋានព័ត៌មាន



*ទិដ្ឋភាពក្នុងជំនួបសម្ដែងការគួរសម*

# សម្ដេចតេជោ ហ៊ុន សែន អនុញ្ញាតឱ្យសមាជិកក្រុមប្រឹក្សាភិបាលនៃគណបក្ស AFD មូលដ្ឋាន ប្រចាំទីក្រុង Karlsruhe ប្រទេសអាល្លឺម៉ង់ ចូលជួបសម្ដែងការគួរសម




*លោក ភីតធឺ អាល់មែន និងសម្ដេចតេជោ ហ៊ុន សែន*

នៅវិមានសាមគ្គីភាព នៃព្រឹទ្ធសភា នាព្រឹកថ្ងៃព្រហស្បតិ៍ ទី៥ ខែមីនា ឆ្នាំ២០២៦ សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រមុខរដ្ឋស្ដីទី នៃព្រះរាជាណាចក្រកម្ពុជា បានអនុញ្ញាតឱ្យ លោក **ភីតធឺ អាល់មែន** (Peter Altmann) សមាជិកក្រុមប្រឹក្សាភិបាលនៃគណបក្ស AFD មូលដ្ឋាន ប្រចាំទីក្រុង Karlsruhe ប្រទេសអាល្លឺម៉ង់ ចូលជួបសម្ដែងការគួរសម។

នៅក្នុងជំនួបនោះ **សម្ដេចតេជោ** បានស្វាគមន៍ និងបង្ហាញក្ដីរំពឹងថា ក្នុងដំណើរទស្សនកិច្ចរបស់លោក **ភីតធឺ** នៅកម្ពុជា នឹងទទួលបានក្ដីសប្បាយរីករាយ ជាមួយទស្សនីយភាពដ៏ស្រស់ស្អាតក្នុងប្រទេសកម្ពុជា ជាពិសេស ទិដ្ឋភាពនិងស្ថានភាពពិតរបស់កម្ពុជា នាពេលបច្ចុប្បន្ន។

លោក **ភីតធឺ** បានថ្លែងអំណរគុណ**សម្ដេចតេជោ** ដែលបានអនុញ្ញាតឱ្យរូបលោកជួបសម្ដែងការគួរសម។ នៅចំពោះមុខ**សម្ដេចតេជោ** លោក **ភីតធឺ** បានថ្លែងថា លោកធ្លាប់តែអានប្រវត្តិសាស្ត្រ និងប្រវត្តិ**សម្ដេចតេជោ** ឮឈ្មោះ**សម្ដេចតេជោ**លើបណ្ដាញផ្សព្វផ្សាយនៅតំបន់អឺរ៉ុប ជាពិសេសនៅក្នុងប្រទេសអាល្លឺម៉ង់ ប៉ុន្ដែថ្ងៃនេះ លោកមានឱកាសបានជួប**សម្ដេចតេជោ** ដោយផ្ទាល់។ លោក **ភីតធឺ** បានបង្ហាញការស្ញប់ស្ញែងចំពោះការធ្វើពលិកម្ម ក៏ដូចជាបទពិសោធន៍របស់**សម្ដេចតេជោ** ក្នុងការដឹកនាំប្រទេសកម្ពុជានាពេលកន្លងទៅ។

លោក **ភីតធឺ** បានកោតសរសើរចំពោះការអភិវឌ្ឍនៅកម្ពុជា ដែលជាប្រទេសមួយដ៏ស្រស់ស្អាត ហើយលោកពិតជាស្រឡាញ់ប្រទេសកម្ពុជាខ្លាំងណាស់ នៅពេលបានមកឃើញដោយផ្ទាល់ភ្នែកបែបនេះ។

ប្រភព៖ Telegram Channel សម្ដេចតេជោ

រូបភាព, សម្រួលខ្លឹមសារ៖ នាយកដ្ឋានព័ត៌មាន



*ទិដ្ឋភាពក្នុងជំនួបសម្ដែងការគួរសម*

# សម្តេចតេជោ៖ កម្ពុជានិងដាណឺម៉ាកនៅមានសក្តានុពលជាច្រើនទៀត ដែលភាគីទាំងពីរអាចធ្វើការជាមួយគ្នា



*ឯកឧត្តម ដែននី អានណាន និងសម្តេចតេជោ ហ៊ុន សែន*



*ទិដ្ឋភាពក្នុងជំនួបសម្តែងការគួរសម*

ក្នុងឱកាសអនុញ្ញាតឱ្យ ឯកឧត្តម **ដែននី អានណាន** (Danny Annan) ឯកអគ្គរាជទូត នៃព្រះរាជាណាចក្រ ដាណឺម៉ាក ប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសម នៅវិមានសាមគ្គីភាព នៃព្រឹទ្ធសភា នាព្រឹកថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៦ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រមុខរដ្ឋស្តីទី នៃព្រះរាជាណាចក្រកម្ពុជា បានលើកឡើងថា ទំនាក់ទំនងរវាងកម្ពុជានិងដាណឺម៉ាកនៅមានសក្តានុពល ជាច្រើនទៀត ដែលប្រទេសទាំងពីរអាចធ្វើការជាមួយគ្នា ជាពិសេសលើវិស័យពាណិជ្ជកម្ម ការវិនិយោគ និងវិស័យ សេដ្ឋកិច្ច។

**សម្តេចតេជោ** បានបង្ហាញអំពីការពេញចិត្តចំពោះ ទំនាក់ទំនងដ៏ល្អរវាងកម្ពុជានិងដាណឺម៉ាក ហើយ**សម្តេច**មាន ជំនឿថា ទំនាក់ទំនងរវាងប្រទេសទាំងពីរ នឹងបន្តរីកចម្រើន បន្ថែមទៀត ក្រោមការដឹកនាំរបស់ឯកឧត្តមជាឯកអគ្គរាជទូត ប្រចាំនៅកម្ពុជា។ នៅឆ្នាំក្រោយដែលជាខួបលើកទី៦០ឆ្នាំ នៃ ទំនាក់ទំនងការទូតរវាងប្រទេសទាំងពីរ **សម្តេចតេជោ** សង្ឃឹមថា ប្រទេសទាំងពីរនឹងមានការរៀបចំកម្មវិធីនានា ដើម្បីអបអរសាទរនៃខួប៦០ឆ្នាំ ដែលនឹងឈានមកដល់ នាពេលខាងមុខ។

**ឯកឧត្តមឯកអគ្គរាជទូត** បានសម្តែងនូវការអរគុណ ចំពោះ**សម្តេចតេជោ** ដែលបានអនុញ្ញាតឱ្យឯកឧត្តមនិង សហការី ចូលជួបសម្តែងការគួរសម និងបានបញ្ជាក់អំពី ការប្តេជ្ញាចិត្តក្នុងការពង្រីកទំនាក់ទំនងរវាងប្រទេសទាំងពីរ ឱ្យកាន់តែរីកចម្រើនក្នុងក្របខ័ណ្ឌនៃការទូតនយោបាយ ជាពិសេសលើវិស័យសេដ្ឋកិច្ច ពាណិជ្ជកម្ម និងការវិនិយោគ។

ជាការឆ្លើយតប **សម្តេចតេជោ** បានពេញចិត្តនិង ឯកភាពក្នុងការធ្វើយ៉ាងណាឱ្យទំនាក់ទំនងរវាងប្រទេស ទាំងពីរកាន់តែល្អបន្ថែមទៀត ជាពិសេសទៅលើវិស័យ សេដ្ឋកិច្ច ពាណិជ្ជកម្ម និងការវិនិយោគឱ្យមានការកើនឡើង ស្របទៅនឹងសហប្រតិបត្តិការក្នុងវិស័យនយោបាយ និង ការទូតរវាងប្រទេសទាំងពីរដែលកំពុងមានជាមួយគ្នា។

នៅក្នុងឱកាសនោះ **សម្តេចតេជោ** បានចែក រំលែកអំពីស្ថានការណ៍អន្តរជាតិមួយចំនួន ជាពិសេសបញ្ហា ព្រំដែនរវាងកម្ពុជានិងថៃ ដែលភាគីទាំងពីរកំពុងតែរក្សា គោលជំហរបទឈប់បាញ់ ហើយ**សម្តេច**ក៏បានបញ្ជាក់ អំពីជំហររបស់កម្ពុជា គឺគាំទ្រចំពោះការរក្សានូវជំហរនៃ ការគោរពបទឈប់បាញ់ និងជំរុញការដោះស្រាយបញ្ហា តាមរយៈការចរចាដោយសន្តិវិធី។

**ឯកឧត្តមឯកអគ្គរាជទូត** បានសម្តែងការគាំទ្រចំពោះ ជំហររបស់កម្ពុជាក្នុងការដោះស្រាយបញ្ហាព្រំដែនរវាង កម្ពុជានិងថៃ ដោយឈរលើការគោរពបទឈប់បាញ់និង ការដោះស្រាយបញ្ហាដោយសន្តិវិធី។

ជាចុងក្រោយ **សម្តេចតេជោ** បានជូនពរ**ឯកឧត្តម ឯកអគ្គរាជទូត** ឱ្យទទួលបានជោគជ័យក្នុងការបំពេញ បេសកកម្មការទូតនៅព្រះរាជាណាចក្រកម្ពុជា៕

ប្រភព៖ Telegram Channel សម្តេចតេជោ

*រូបភាព, សម្រួលខ្លឹមសារ៖ នាយកដ្ឋានព័ត៌មាន*

# សម្តេចតេជោ ហ៊ុន សែន ចាត់ទុកទំនាក់ទំនងពាណិជ្ជកម្ម សេដ្ឋកិច្ច ធុរកិច្ច និងការវិនិយោគ ជាចំណុចស្នូលនៃទំនាក់ទំនងកម្ពុជា-ស្លូវ៉ាគី ក្រៅពីការទូត និងនយោបាយ

ក្នុងឱកាសអនុញ្ញាតឱ្យ ឯកឧត្តម **អេឡិចសិនដឺ មីខូវស៊ិន** (Alexander Micovčin) ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព នៃសាធារណរដ្ឋស្លូវ៉ាគី ប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជូនសាតាំងនិងសម្តែងការគួរសម នៅវិមានសាមគ្គីភាព នៃព្រឹទ្ធសភា នាព្រឹកថ្ងៃព្រហស្បតិ៍ ទី១៩ ខែមីនា ឆ្នាំ២០២៦ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រមុខរដ្ឋស្តីទី នៃព្រះរាជាណាចក្រកម្ពុជា បានចាត់ទុកទំនាក់ទំនងពាណិជ្ជកម្ម សេដ្ឋកិច្ច ធុរកិច្ច និងការវិនិយោគ ជាចំណុចស្នូលនៃទំនាក់ទំនងរវាងកម្ពុជា និងស្លូវ៉ាគី ក្រៅពីការទូត និងនយោបាយ។

ក្នុងព្រះបរមនាមព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា **សម្តេចតេជោ** បានអបអរសាទរនិងស្វាគមន៍ ចំពោះវត្តមាន**ឯកឧត្តមឯកអគ្គរដ្ឋទូត** ព្រមទាំងមានជំនឿថា ក្នុងអាណត្តិរបស់ឯកឧត្តមជាឯកអគ្គរដ្ឋទូត នឹងពូនជ្រំនូវទំនាក់ទំនងនិងកិច្ចសហប្រតិបត្តិការរវាងកម្ពុជានិងស្លូវ៉ាគី ឱ្យកាន់តែរីកចម្រើនបន្ថែមទៀត ជាពិសេសនៅក្នុងឱកាសខួប៧០ឆ្នាំ នៃទំនាក់ទំនងការទូតរវាងប្រទេសទាំងពីរនៅឆ្នាំក្រោយនេះ នឹងមានការរៀបចំពិធីអបអរសាទរ ដើម្បីបង្ហាញពីភាពរីកចម្រើននៃទំនាក់ទំនងរវាងកម្ពុជានិងស្លូវ៉ាគី។

ក្នុងឱកាសនោះ **ឯកឧត្តមឯកអគ្គរដ្ឋទូត** បានសម្តែងនូវការអរគុណចំពោះ**សម្តេចតេជោ** ដែលបានអនុញ្ញាតឱ្យឯកឧត្តមចូលជួបជូនសារតាំងនាឱកាសនេះ ព្រមទាំងបានជម្រាបជូន **សម្តេចតេជោ** ជ្រាបថា បេសកកម្មរបស់ឯកឧត្តមនៅពេលនេះ គឺមានភារកិច្ចក្នុងការលើកកម្ពស់ទំនាក់ទំនងដ៏ល្អរវាងកម្ពុជានិងស្លូវ៉ាគី ដែលមានស្រាប់ឱ្យកាន់តែប្រសើរឡើងបន្ថែមទៀត។ ឯកឧត្តមបានសង្កត់ធ្ងន់លើទំនាក់ទំនងពាណិជ្ជកម្ម សេដ្ឋកិច្ច ធុរកិច្ច និងការវិនិយោគដែលជាចំណុចស្នូល ដែលឯកឧត្តមចង់ពង្រីកក្នុងអាណត្តិរបស់ឯកឧត្តម។



*ឯកឧត្តម អេឡិចសិនដឺ មីខូវស៊ិន ជូនសារតាំង សម្តេចតេជោ ហ៊ុន សែន*



*ឯកឧត្តម អេឡិចសិនដឺ មីខូវស៊ិន និងសម្តេចតេជោ ហ៊ុន សែន*

**សម្តេចតេជោ** បានសម្តែងនូវការគាំទ្រចំពោះការពង្រីកទំនាក់ទំនងរវាងកម្ពុជានិងស្លូវ៉ាគី និងកោតសរសើរចំពោះក្រសួងការបរទេស និងរដ្ឋាភិបាលនៃប្រទេសទាំងពីរ តែងតែជជែកគ្នាអំពីការគាំទ្រគ្នាក្នុងឆាកអន្តរជាតិ និងលើវេទិកាអន្តរជាតិនានា។

ជាចុងក្រោយ **សម្តេចតេជោ** បានជូនពរ**ឯកឧត្តមឯកអគ្គរដ្ឋទូត** ឱ្យបំពេញបេសកកម្មនៅក្នុងប្រទេសកម្ពុជា ប្រកបដោយភាពជោគជ័យ៕

ប្រភព៖ Telegram Channel សម្តេចតេជោ

រូបភាព, សម្រួលខ្លឹមសារ៖ នាយកដ្ឋានព័ត៌មាន

# កម្ពុជា-ឡាវ គួរតែបន្តពង្រីកសហប្រតិបត្តិការលើវិស័យពាណិជ្ជកម្ម សេដ្ឋកិច្ច និងការវិនិយោគ ដើម្បីគាំទ្រដល់ទំនាក់ទំនងនយោបាយ និងការទូត



*ឯកឧត្តម Sonexay Vannaxay ជូនសារតាំងសម្ដេចតេជោ ហ៊ុន សែន*



*ទិដ្ឋភាពក្នុងជំនួបចូលជូនសារតាំង និងសម្ដែងការគួរសម*

សម្ដេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រមុខរដ្ឋស្ដីទី នៃព្រះរាជាណាចក្រកម្ពុជា បានជំរុញឱ្យកម្ពុជា និងឡាវ គួរតែបន្តពង្រីកសហប្រតិបត្តិការក្នុងក្របខ័ណ្ឌនៃទំនាក់ទំនងពាណិជ្ជកម្ម សេដ្ឋកិច្ច និងការវិនិយោគ ឱ្យកាន់តែកើនឡើងបន្ថែមទៀត ដែលជាផ្នែកដ៏សំខាន់ដើម្បីគាំទ្រដល់ទំនាក់ទំនងនយោបាយនិងការទូតរវាងប្រទេសទាំងពីរ។ **សម្ដេច**បានលើកឡើងបែបនេះ ក្នុងឱកាសដែលអនុញ្ញាតឱ្យឯកឧត្តម Sonexay Vannaxay ឯកអគ្គរដ្ឋទូតវិសាមញ្ញនិងពេញសមត្ថភាព នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ចូលជូនសារតាំងនិងសម្ដែងការគួរសម នៅវិមានសាមគ្គីភាព នៃព្រឹទ្ធសភា នាព្រឹកថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២៦។

ក្នុងព្រះបរមនាមព្រះករុណាព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា សម្ដេចតេជោ **ហ៊ុន សែន** បានសម្ដែងការស្វាគមន៍និងចាត់ទុកវត្តមានដ៏ឆាប់រហ័សរបស់ឯកឧត្តម Sonexay Vannaxay មកកាន់តំណែងជាឯកអគ្គរដ្ឋទូតប្រចាំនៅកម្ពុជា គឺបង្ហាញអំពីការផ្ដល់តម្លៃខ្ពស់ពីភាគីឡាវចំពោះទំនាក់ទំនងរវាងកម្ពុជានិងឡាវ។

នៅក្នុងជំនួបនោះ **ឯកឧត្តមឯកអគ្គរដ្ឋទូត** បានលើកឡើងអំពីទំនាក់ទំនងរវាងកម្ពុជានិងឡាវ ដែលជាទំនាក់ទំនងដ៏ល្អប្រសើរ ហើយភាគីទាំងពីរក៏ជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ គង់វង្ស និងយូរអង្វែង។ មិត្តភាពនៃទំនាក់ទំនងរវាងប្រទេសទាំងពីរ ជាមិត្តភាពដែលមានប្រវត្តិសាស្ត្រនៃការជួយគ្នាទៅវិញទៅមក និងជាប្រទេសជន្លងនឹងគ្នា។

ឆ្នាំនេះ ជាខួប៧០ឆ្នាំ នៃទំនាក់ទំនងរវាងប្រទេសទាំងពីរ ក្នុងនាមជា**ឯកអគ្គរដ្ឋទូតថ្មី** ឯកឧត្តមនឹងប្ដេជ្ញាខិតខំប្រឹងប្រែងពូនជ្រំទំនាក់ទំនងរវាងកម្ពុជានិងឡាវឱ្យកាន់តែរឹងមាំរីកចម្រើនបន្តទៀត។ ឯកឧត្តមក៏បានសម្ដែងនូវការអរគុណចំពោះរាជរដ្ឋាភិបាលនិងប្រជាជនកម្ពុជា ដែលតែងតែជួយដល់ប្រទេសនិងប្រជាជនឡាវគ្រប់កាលៈទេសៈ ជាពិសេសនៅក្នុងបរិបទនៃជំងឺកូវីដ-១៩ កន្លងទៅ ដែលកម្ពុជាបានចូលរួមចំណែកជួយផ្ដល់វ៉ាក់សាំងនិងសម្ភារៈបច្ចេកទេសមួយចំនួន។

**សម្ដេចតេជោ** បានពេញចិត្តចំពោះការលើកឡើងរបស់**ឯកឧត្តមឯកអគ្គរដ្ឋទូត** ជុំវិញបរិបទនៃទំនាក់ទំនងរវាងកម្ពុជានិងឡាវ ដែលមានភាពជិតស្និទ្ធជាមួយគ្នា។ **សម្ដេច**បានលើកឡើងថា កម្ពុជានិងឡាវមានប្រវត្តិសាស្ត្រនៃទំនាក់ទំនងប្រទេសទាំងពីរតាំងពីអតីតកាល រហូតមកដល់ពេលបច្ចុប្បន្ននេះក៏នៅតែមានទំនាក់ទំនងដ៏ល្អនិងស្អិតល្មួត ហើយប្រទេសទាំងពីរជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ គង់វង្សយូរអង្វែងជាមួយគ្នា។ ទន្ទឹងនឹងនោះ **សម្ដេច**បានរំលេចថា កម្ពុជានិងឡាវជាមិត្តដែលមានចិត្តស្មោះសរនឹងគ្នាជានិច្ច។

ជាចុងក្រោយ **សម្ដេចតេជោ**បានជូនពរឱ្យ**ឯកឧត្តមឯកអគ្គរដ្ឋទូត**ដែលបានបំពេញបេសកកម្មការទូតនៅព្រះរាជាណាចក្រកម្ពុជា ទទួលបានជោគជ័យនិងពូនជ្រំទំនាក់ទំនងកម្ពុជានិងឡាវឱ្យកាន់តែរីកចម្រើន៕

ប្រភព៖ Telegram Channel សម្ដេចតេជោ
រូបភាព, សម្រួលខ្លឹមសារ៖ នាយកដ្ឋានព័ត៌មាន

# ឯកឧត្តម អ៊ុច បូរិទ្ធ អញ្ជើញសំណេះសំណាលជាមួយសមាជិកាព្រឹទ្ធសភា មន្ត្រីរាជការជាស្ត្រី និងនិយោជិតនារី នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ក្នុងឱកាសអបអរសាទរខួបលើកទី១១៥ ទិវាអន្តរជាតិនារី ៨មីនា




*ឯកឧត្តម អ៊ុច បូរិទ្ធ អញ្ជើញជាអធិបតីក្នុងពិធីសំណេះសំណាលអបអរសាទរខួបលើកទី១១៥ ទិវាអន្តរជាតិនារី ៨មីនា*

នៅរសៀលថ្ងៃទី៥ ខែមីនា ឆ្នាំ២០២៦ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាបានប្រារព្ធពិធីអបអរសាទរទិវាអន្តរជាតិនារី ៨មីនា ខួបលើកទី១១៥ ឆ្នាំ២០២៦ ក្រោមប្រធានបទ «សន្តិភាពនិងសន្តិសុខសម្រាប់ស្ត្រីនិងគ្រួសារ» ដែលប្រព្រឹត្តទៅនៅវិមានសាមគ្គីភាពនៃព្រឹទ្ធសភា ក្រោមអធិបតីភាពឯកឧត្តម **អ៊ុច បូរិទ្ធ** ប្រធានស្តីទីព្រឹទ្ធសភា។

បន្ទាប់ពីលោកជំទាវ **សួន ពុធថាវី** អគ្គនាយិកាស្រាវជ្រាវ និងជាប្រធានគណៈកម្មការសាខាសមាគមនារីកម្ពុជាដើម្បីសន្តិភាពនិងអភិវឌ្ឍន៍នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា រាយការណ៍ជូនជ្រាបអំពីស្ថានភាពមន្ត្រីរាជការនារីនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងលោកជំទាវ **ឃួន យុនឌី** សមាជិកាព្រឹទ្ធសភា អានព្រះរាជសារសម្តេចព្រះមហាក្សត្រីព្រះវររាជមាតាជាតិខ្មែរក្នុងឱកាសអបអរសាទរទិវាអន្តរជាតិនារី ៨មីនា ខួបលើកទី១១៥រួចមក ឯកឧត្តម **អ៊ុច បូរិទ្ធ** បាននាំនូវការផ្តាំផ្ញើសាកសួរសុខទុក្ខនិងប្រសិទ្ធពរជ័យរបស់**សម្តេចតេជោ**និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុនសែន** ជូនចំពោះលោកជំទាវ លោក លោកស្រី នាងកញ្ញា ដែលកំពុងបម្រើការងារក្នុងស្ថាប័នព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាទាំងអស់ និងបានចាត់ទុកប្រធានបទនាឆ្នាំនេះ គឺបានឆ្លុះបញ្ចាំងពីសេចក្តីប្រាថ្នាដ៏ជ្រាលជ្រៅបំផុតនៃប្រជាជាតិទាំងមូលនោះ គឺការធានាឱ្យបុគ្គលគ្រប់រូបអាចរស់នៅដោយសេចក្តីថ្លៃថ្នូរនិងគ្រួសារគ្រប់រូបអាចរីកចម្រើនទៅមុខក្នុងសុខសុវត្ថិភាព។



*ឯកឧត្តម អ៊ុច បូរិទ្ធ អញ្ជើញមានមតិសំណេះសំណាល*

**ឯកឧត្តមប្រធានស្តីទីព្រឹទ្ធសភា** បានបញ្ជាក់ថា នៅក្នុងបរិបទប្រទេសកម្ពុជា សន្តិភាព និងសន្តិសុខ ជាមូលដ្ឋានគ្រឹះក្នុងការធ្វើឱ្យសម្រេចបាននូវកិច្ចអភិវឌ្ឍ ធានាលើកកម្ពស់សិទ្ធិមនុស្ស និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋការលើកកម្ពស់ឋានៈតួនាទីនិងស្ថានភាពស្ត្រីនិងក្មេងស្រី



*លោកជំទាវ ឃួន ឃុនឌី ឡើងអានព្រះរាជសារ សម្ដេចព្រះមហាក្សត្រីព្រះវររាជមាតាជាតិខ្មែរ*



*លោកជំទាវ សួន ពុធថាវី ឡើងរាយការណ៍*

នៅគ្រប់វិស័យ។ រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា ក្រោមការដឹកនាំរបស់សម្ដេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី ប្ដេជ្ញាបន្តថែរក្សាសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្ដាប់ធ្នាប់សាធារណៈ ដែលកត្តាទាំងនេះ ជាបុរេលក្ខខណ្ឌមិនអាចខ្វះបានសម្រាប់ពន្លឿនកិច្ចអភិវឌ្ឍប្រទេសជាតិ។

នៅក្នុងបរិបទដែលមានការឈ្លានពាននិងការបង្កើនភាពតានតឹងតាមព្រំដែនដោយភាគីថៃ ផលប៉ះពាល់បានធ្លាក់ទៅលើស្ត្រី និងក្មេងស្រីយ៉ាងច្បាស់លាស់ ដោយធ្វើឱ្យមានការកើនឡើងនូវហានិភ័យសន្តិសុខផ្ទាល់ខ្លួន ការផ្លាស់ទីលំនៅបណ្ដោះអាសន្ន ការបាត់បង់មធ្យោបាយរកប្រាក់ចំណូល និងការរាំងស្ទះក្នុងការទទួលបានសេវាសុខាភិបាល ជាពិសេសសេវាសុខភាពមាតានិងទារក និងសុខភាពផ្លូវចិត្ត។ ស្ថានភាពអស្ថិរភាពបែបនេះ ក៏អាចបង្កើនហានិភ័យអំពើហិង្សាទាក់ទងនឹងយេនឌ័រនិងការកេងប្រវ័ញ្ចលើស្ត្រីនិងក្មេងស្រីផងដែរ ដែលជាមូលហេតុធ្វើឱ្យការរក្សាសន្តិភាព និងសន្តិសុខក្លាយជាប្រធានបទមានន័យជាក់ស្ដែង និងមានតម្លៃខ្លាំងជាងមុនក្នុងឱកាសអបអរសាទរទិវាអន្តរជាតិនារីឆ្នាំនេះ។

សន្តិភាព និងសន្តិសុខ ជាគ្រឹះនៃសុខុមាលភាពរបស់ស្ត្រី និងក្រុមគ្រួសារ ដែលផ្ដល់នូវបរិយាកាសអំណោយផលដល់ការរស់នៅប្រកបដោយសុវត្ថិភាព គ្មានអំពើហិង្សា គ្មានការភ័យខ្លាច ការពារស្ត្រី និងក្មេងស្រីពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ ការងារសិទ្ធិស្ត្រី និងក្មេងស្រី និងការផ្ដល់នូវកាលានុវត្តភាពពេញលេញសម្រាប់ស្ត្រីក្នុងការចូលរួមធ្វើសេចក្ដីសម្រេចចិត្ត កសាងនិងថែរក្សាសន្តិភាពនិងសន្តិសុខទាំងបែបប្រពៃណីនិងមិនប្រពៃណី រួមចំណែកពន្លឿនការអភិវឌ្ឍសេដ្ឋកិច្ចជាតិ លើកកម្ពស់សុខុមាលភាពនិងវិបុលភាពគ្រួសារនិងសង្គម។

សន្តិភាពនៅកម្ពុជាកើតមានឡើង តាមរយៈការខិតខំ



*ទិដ្ឋភាពក្នុងពិធីសំណេះសំណាលអបអរសាទរខួបលើកទី១១៥ ទិវាអន្តរជាតិនារី ៨មីនា*



*ទិដ្ឋភាពក្នុងពិធីសំណេះសំណាលអបអរសាទរខួបលើកទី១១៥ ទិវាអន្តរជាតិនារី ៨មីនា*

រួមនិងយុទ្ធសាស្ត្រ ប្រកបដោយចក្ខុវិស័យច្បាស់លាស់របស់ឥស្សរជនគណបក្សប្រជាជនកម្ពុជានិងថ្នាក់ដឹកនាំកំពូលរបស់ជាតិ។ ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា (អតីតនាយករដ្ឋមន្ត្រី) ដែលជាអគ្គមគ្គុទ្ទេសក៍ឯកនិងប្រតិបត្តិករនៃ«នយោបាយឈ្នះ-ឈ្នះ» បាននាំមកនូវសន្តិភាព ឯកភាពជាតិពេញលេញបរិបូរណ៌ និងសម្រេចបាននូវកិច្ចអភិវឌ្ឍលើគ្រប់វិស័យ នាំមកនូវភាពសុខសាន្តសម្បូរសប្បាយរបស់ប្រជាជនខ្មែរ និងការអភិវឌ្ឍប្រទេសប្រកបដោយចីរភាព ព្រមទាំងការគោរពសិទ្ធិមនុស្ស ការអនុវត្តលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស និងការលើកកម្ពស់សមភាពយេនឌ័រ។

ការបន្តរក្សាបាននូវសន្តិភាព ស្ថិរភាពនយោបាយ និងស្ថិរភាពសង្គម គឺមិនអាចកាត់ផ្តាច់បានពីការផ្តល់ឱកាសស្មើៗគ្នាជូនប្រជាជនគ្រប់រូប នូវផ្លែផ្កានៃការអភិវឌ្ឍសេដ្ឋកិច្ចនិងវិបុលភាពសង្គម ក៏ដូចជាការអភិវឌ្ឍធនធានមនុស្សឱ្យក្លាយទៅជាធនធានដែលមានសក្តានុពលមិនចេះរីងស្ងួត។

ជាចុងក្រោយ **ឯកឧត្តមប្រធានស្តីទីព្រឹទ្ធសភា** បានលើកទឹកចិត្តដល់មន្ត្រីរាជការនារីទាំងអស់ត្រូវខិតខំកសាងសមត្ថភាព ដើម្បីចូលរួមឱ្យបានកាន់តែសកម្មនិងកាន់តែមានប្រសិទ្ធភាពថែមទៀត ក្នុងគ្រប់យន្តការរបស់អគ្គលេខាធិការដ្ឋាន ស្របទៅនឹងការអភិវឌ្ឍថ្មីរបស់ព្រឹទ្ធសភាជាពិសេសអាចឆ្លើយតបបានចំពោះចក្ខុវិស័យមុខងារនិងអាទិភាពចម្បងដែលដាក់ចេញប្រកបដោយគតិបណ្ឌិតនិងភាពឈ្លាសវៃបំផុតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ព្រមទាំងខិតខំជម្នះឱ្យបានលើបញ្ហាប្រឈមផ្សេងៗទាំងក្នុងគ្រួសារនិងសង្គម៕

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន



*ឯកឧត្តម អ៊ុច បូរិទ្ធ អញ្ជើញថតរូបអនុស្សាវរីយ៍ជាមួយសមាជិកាព្រឹទ្ធសភា មន្ត្រីរាជការ និងនិវត្តជនជានារី នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*

# ឯកឧត្តម អ៊ុច បូររិទ្ធ អញ្ជើញជាអធិបតីក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងាររបស់ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាឆ្នាំ២០២៥ និងទិសដៅការងារឆ្នាំ២០២៦



*ឯកឧត្តម អ៊ុច បូររិទ្ធ អញ្ជើញជាអធិបតីក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងារ របស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាប្រចាំឆ្នាំ២០២៥ និងទិសដៅការងារឆ្នាំ២០២៦*

នារសៀលថ្ងៃ ទី១២ ខែមីនា ឆ្នាំ២០២៦ ឯកឧត្តម **អ៊ុច បូររិទ្ធ** ប្រធានស្តីទីព្រឹទ្ធសភា បានអញ្ជើញជាអធិបតីក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាប្រចាំឆ្នាំ២០២៥ និងទិសដៅការងារឆ្នាំ២០២៦ នៅវិមានសាមគ្គីភាព នៃព្រឹទ្ធសភា ដោយមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំខុទ្ទកាល័យថ្នាក់ដឹកនាំព្រឹទ្ធសភា និងថ្នាក់ដឹកនាំអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចាប់ពីអនុប្រធាននាយកដ្ឋានឡើង។

មុននឹងដំណើរការកិច្ចប្រជុំ អង្គពិធីបានគោរពវិញ្ញាណក្ខន្ធវីរយុទ្ធជនដែលបានពលីជីវិតដើម្បីបុព្វហេតុការពារជាតិមាតុភូមិ។



*ឯកឧត្តម អ៊ុច បូររិទ្ធ ប្រធានស្តីទីព្រឹទ្ធសភា*

ក្រោយពីការឡើងធ្វើបទបង្ហាញ អំពីលទ្ធផលការងារ បញ្ហាប្រឈម និងទិសដៅការងារបន្តសម្រាប់ឆ្នាំ២០២៦ របស់ឯកឧត្តម លោកជំទាវ អគ្គនាយក អគ្គនាយិកា នៃអគ្គនាយកដ្ឋានទាំង៥ ឯកឧត្តម **ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភាបានវាយតម្លៃខ្ពស់ចំពោះលទ្ធផលដែលសម្រេចបានគួរជាទីកត់សម្គាល់របស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា សម្រាប់ការគាំទ្រនិងរួមចំណែកលើកកម្ពស់តួនាទីរបស់ព្រឹទ្ធសភា ដែលបានក្លាយជាមជ្ឈមណ្ឌលនៃកិច្ចការនយោបាយ ការទូត និងសហប្រតិបត្តិការអន្តរជាតិ និងការសម្រេចចិត្តលើបញ្ហាធំៗមួយចំនួនរបស់ជាតិ។

ទន្ទឹមនឹងនោះ **ឯកឧត្តមអគ្គលេខាធិការ** ក៏បានលើកឡើងនូវបញ្ហាប្រឈមនិងសំណូមពរឱ្យថ្នាក់ដឹកនាំ និងមន្ត្រីអគ្គលេខាធិការដ្ឋាន បន្តលើកកម្ពស់ប្រសិទ្ធភាព និងគុណភាពការងារ តាមរយៈការពង្រឹងស្មារតីយកចិត្តទុកដាក់និងទទួលខុសត្រូវខ្ពស់ ជាពិសេសពង្រឹងសហការ និងការសម្របសម្រួលបន្ថែមជាមួយអង្គភាពផ្ទៃក្នុង និងជាមួយក្រសួងស្ថាប័ននានា។ ជាមួយគ្នានោះដែរ **ឯកឧត្តមអគ្គលេខាធិការ** បានដាក់ចេញផែនការសំខាន់ៗនៅក្នុងឆ្នាំ២០២៦ រួមមាន៖ ការពិនិត្យឡើងវិញនូវការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ការបន្តដោះស្រាយនិងបំពេញតម្រូវការផ្សេងៗរបស់ស្ថាប័ន ការអភិវឌ្ឍធនធានមនុស្ស ជាពិសេសការរៀបចំសូចនាករដែលអាចវាស់វែង និងវាយតម្លៃបាន សម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រឆ្នាំ២០២៧-២០៣០។



ឯកឧត្តម ឡាយ សំកុល អគ្គលេខាធិការព្រឹទ្ធសភា

**ឯកឧត្តមអគ្គលេខាធិការ** បានសម្តែងនូវការគោរពដឹងគុណជាទីបំផុត ជូនចំពោះវីរយុទ្ធជនជួរមុខកម្ពុជាដ៏អង់អាចក្លាហាន ដែលបានបូជាសាច់ស្រស់ ឈាមស្រស់ ក្នុងការការពារបូរណភាពទឹកដីជូនជាតិ មាតុភូមិ និងវីរភាពរបស់ថ្នាក់ដឹកនាំកម្ពុជាប្រកបដោយគតិបណ្ឌិតដ៏ខ្ពង់ខ្ពស់ ខិតខំថែរក្សានូវសុខសន្តិភាពជូនប្រជាពលរដ្ឋកម្ពុជា។

ឯកឧត្តម **អ៊ុច បូររិទ្ធ** ប្រធានស្តីទីព្រឹទ្ធសភា ក៏បានកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះលទ្ធផលដែលសម្រេចបាន ក្រោមការដឹកនាំរបស់**ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា** ស្របតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់ប្រកបដោយគតិបណ្ឌិតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា ដែលបានកំណត់ការងារអាទិភាពចម្បងចំនួន២ គឺការលើកកម្ពស់ការទូតសភា និងការផ្សារភ្ជាប់ទំនាក់ទំនងឱ្យកាន់តែជិតស្និទ្ធជាមួយអង្គបោះឆ្នោតនិងអាជ្ញាធរមូលដ្ឋាន ជាពិសេសការចូលរួមចំណែកគាំទ្ររាជរដ្ឋាភិបាល តស៊ូប្រឆាំងនឹងការឈ្លានពានពីភាគីថៃ។

ដើម្បីលើកកម្ពស់ប្រសិទ្ធភាពការងារ **ឯកឧត្តមប្រធានស្តីទីព្រឹទ្ធសភា** បានសង្កត់ធ្ងន់ថា យើងត្រូវបន្តលើកកម្ពស់សមត្ថភាពរបស់ខ្លួនជាប្រចាំ តាមរយៈការជុះខាត់ចំណេះដឹង ចំណេះធ្វើ និងចំណេះដឹងផ្នែកភាសាបរទេស។ ហើយការដែលមានសមត្ថភាពតែមួយមុខក៏ពុំទាន់គ្រប់គ្រាន់នោះដែរ គឺត្រូវមានស្មារតីខិតខំ តស៊ូ ព្យាយាម និងការទទួលខុសត្រូវចំពោះតួនាទី និងការងារដែលខ្លួនរ៉ាប់រង។ យើងម្នាក់ៗមានតួនាទី ភារកិច្ចបម្រើជាតិមាតុភូមិនិងប្រជាជន ហើយការខិតខំប្រឹងប្រែងរបស់យើងក៏ជាការឆ្លុះបញ្ចាំងពីមនសិការស្នេហាជាតិផងដែរ។

សម្រាប់ឆ្នាំ២០២៦ **ឯកឧត្តមប្រធានស្តីទីព្រឹទ្ធសភា** បានណែនាំដល់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភានិងអង្គភាពពាក់ព័ន្ធ ពិនិត្យពិចារណាឡើងវិញក្នុងការកែលម្អរចនាសម្ព័ន្ធការងារ ដើម្បីឱ្យស្របនឹងសភាពការណ៍វិវត្តនិងទំហំការងារដែលមានការកើនឡើង និងចំពោះមុខត្រូវយកចិត្តទុកដាក់ក្នុងការចូលរួមរៀបចំកិច្ចប្រជុំអន្តរសភាសំខាន់ៗ ដែលកម្ពុជានឹងធ្វើជាម្ចាស់ផ្ទះ ដូចជា កិច្ចប្រជុំគណៈកម្មការនយោបាយនៃសភាប្រើភាសាបារាំង (APF) នៅខេត្តសៀមរាប ការរៀបចំសន្និសីទប្រធានសភានៃអន្តរសភា (ISC) និងការចូលរួមចំណែករបស់ព្រឹទ្ធសភានៅក្នុងការធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំកំពូលហ្វ្រង់កូហ្វូនី។

នៅទីបញ្ចប់ **ឯកឧត្តមប្រធានស្តីទី** បានថ្លែងអំណរគុណដល់ថ្នាក់ដឹកនាំ មន្ត្រី និងបុគ្គលិកទាំងអស់ ដែលបានរួមសាមគ្គីគ្នាសម្រេចលទ្ធផលដ៏គួរឱ្យកត់សម្គាល់នាឆ្នាំ២០២៥ និងសូមបន្តលើកកម្ពស់ស្មារតីសាមគ្គីនិងសហការគ្នា ដើម្បីសម្រេចទិសដៅការងារនិងលើកកម្ពស់កិត្យានុភាពស្ថាប័នឱ្យបានខ្ពង់ខ្ពស់បន្ថែមទៀត៕

អត្ថបទ និងរូបភាពៈ នាយកដ្ឋានព័ត៌មាន



ទិដ្ឋភាពក្នុងពិធីប្រជុំបូកសរុបលទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាប្រចាំឆ្នាំ២០២៥ និងទិសដៅការងារឆ្នាំ២០២៦

# ឯកឧត្តម អ៊ុច បូររិទ្ធ អញ្ជើញចុះសួរសុខទុក្ខនិងនាំយកអំណោយរបស់សម្តេចតេជោ ជូនវីរកងទ័ពជួរមុខនៅទិសខេត្តព្រះវិហារ ខេត្តឧត្តរមានជ័យ ខេត្តពោធិ៍សាត់ និងទិសយោធភូមិភាគទី៤





*ឯកឧត្តម អ៊ុច បូររិទ្ធ អញ្ជើញសំណេះសំណាលនិងនាំយកសម្ភារៈចាំបាច់ជូនដល់វីរយុទ្ធជន នៅខេត្តព្រះវិហារ*

នាថ្ងៃទី២៤ ដល់ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២៦ ឯកឧត្តម **អ៊ុច បូររិទ្ធ** អនុប្រធានទី១ ព្រឹទ្ធសភា និងសហការី បានអញ្ជើញចុះសួរសុខទុក្ខនិងនាំយកនូវអំណោយដ៏ថ្លៃថ្លារបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ជូនដល់វីរយុទ្ធជនឈរជើងនៅទិសខេត្តព្រះវិហារ ខេត្តឧត្តរមានជ័យ ខេត្តពោធិ៍សាត់ និងទិសយោធភូមិភាគទី៤។

ក្នុងឱកាសជួបសំណេះសំណាលជាមួយវីរកងទ័ពនៅគ្រប់ទីកន្លែង **ឯកឧត្តមអនុប្រធានទី១** បាននាំនូវការផ្តាំផ្ញើការនឹករឭកនិងការសួរសុខទុក្ខ ព្រមទាំងសព្ទសាធុការពរពីសម្តេចតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី និងលោកជំទាវ ជូនដល់វីរកងទ័ពដែលកំពុងឈរជើងយ៉ាងរឹងមាំនៅតាមបណ្តោយព្រំដែនកម្ពុជា-ថៃ ប្តូរផ្តាច់ការពារបូរណភាពទឹកដីនិងមាតុភូមិកម្ពុជា។

**ឯកឧត្តមអនុប្រធានទី១** បានសម្តែងនូវការដឹងគុណនិងគារវកិច្ចដ៏ជ្រាលជ្រៅបំផុតចំពោះវីរភាពដ៏អង់អាចក្លាហានមោះមុតដ៏គួរឱ្យកោតស្ញប់ស្ញែងរបស់វីរយុទ្ធជន ដើម្បីបុព្វហេតុការពារបូរណភាពទឹកដីកម្ពុជា ព្រមទាំងបាន





*ឯកឧត្តម អ៊ុច បូររិទ្ធ អញ្ជើញសំណេះសំណាលនិងនាំយកសម្ភារៈចាំបាច់ជូនដល់វីរយុទ្ធជន នៅខេត្តឧត្តរមានជ័យ*





*ឯកឧត្តម អ៊ុច បូរិទ្ធ អញ្ជើញនាំយកសម្ភារៈចាំបាច់ជូនដល់វីរយុទ្ធជន និងចុះសួរសុខទុក្ខប្រជាពលរដ្ឋភៀសសឹក នៅខេត្តពោធិ៍សាត់*

បួងសួងដល់គុណបុណ្យព្រះរតនត្រ័យ គុណកែវទាំងបី សូមតាមអភិបាលប្រោះព្រំ ឃុំគ្រងថែរក្សា និងប្រសិទ្ធពរជ័យជូនវីរយុទ្ធជនដ៏អង់អាចក្លាហាននៅតាមបណ្តោយព្រំដែន សូមប្រកបតែសុខភាពល្អ និងទទួលបានជ័យជម្នះលើពួកឈ្លានពាន។

ជាមួយគ្នានោះដែរ ឯកឧត្តមបានបញ្ជាក់ថា ការឈ្លានពានដែលបង្កឡើងដោយការរំលោភបំពានយ៉ាងឃោរឃៅរបស់ថៃមកលើបូរណភាពទឹកដីកម្ពុជា មិនបានធ្វើឱ្យប្រជាជាតិយើងចុះទន់ខ្សោយនោះទេ ផ្ទុយទៅវិញ ទង្វើទាំងនេះបានដុតបញ្ឆេះនូវសន្ទុះសាមគ្គីភាពយ៉ាងខ្លាំងក្លានិងឯកភាពជាតិដ៏រឹងមាំដែលមិនអាចរង្គោះរង្គើបាន នៅក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់**សម្តេចតេជោ** និងរាជរដ្ឋាភិបាល ក្រោមការដឹកនាំដ៏ឈ្លាសវៃ និងម៉ឺងម៉ាត់របស់**សម្តេចធិបតី**។ សាមគ្គីភាពនេះ ដែលកើតចេញពីជម្រៅទឹកចិត្ត និងមិនងាករេ មិនត្រឹមតែជាខែលការពាររបស់ប្រទេសជាតិក្នុងគ្រាដ៏លំបាកប៉ុណ្ណោះទេ ប៉ុន្តែក៏ជាមោទនភាពជាតិដ៏អស្ចារ្យបំផុត ក្នុងនាមជាប្រជាជាតិអធិបតេយ្យមួយដែលប្តេជ្ញាការពារទឹកដី មរតក និងអនាគតរបស់ខ្លួន។

ជាមួយនឹងវត្តមានដ៏ថ្លៃថ្លារបស់ព្រះធម្មវនវាសី **ចន្ទ មុនី** នៅក្នុងពិធីសំណេះសំណាលជាមួយវីរកងទ័ពឈរជើងនៅទិសយោធភូមិភាគទី៤ (ខេត្តព្រះវិហារ) និងឃុំថ្មដា (ខេត្តពោធិ៍សាត់) ព្រះអង្គក៏បាននិមន្តប្រោះព្រំ និងប្រសិទ្ធពរជ័យជូនដល់វីរយុទ្ធជន ព្រមទាំងចូលរួមចែកអំណោយដល់គ្រួសារវីរយុទ្ធជនផងដែរ៕

អត្ថបទ៖ ខុទ្ទកាល័យឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា

រូបភាព៖ នាយកដ្ឋានព័ត៌មាន





*ឯកឧត្តម អ៊ុច បូរិទ្ធ អញ្ជើញនាំយកសម្ភារៈចាំបាច់ជូនដល់វីរយុទ្ធជនឈរជើងនៅទិសយោធភូមិភាគទី៤*

# ឯកឧត្តម អ៊ុច បូរិទ្ធ អញ្ជើញជាអធិបតីក្នុងពិធីចម្រើនអាយុវឌ្ឍនមង្គល សម្ពោធឆ្លងកុដិ និងបុណ្យផ្កាប្រាក់សាមគ្គី នៅវត្តព្រះអង្គកងជុំ ខេត្តសៀមរាប




នាថ្ងៃទី៣ និងថ្ងៃទី៤ ខែមីនា ឆ្នាំ២០២៦ ឯកឧត្តម **អ៊ុច បូរិទ្ធ** ប្រធានស្ដីទីព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវ បានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីក្រុងពាលី ចម្រើនអាយុវឌ្ឍនមង្គល ព្រះវិរិយានុបាល **សេង ពេជ្រ** ព្រះចៅអធិការវត្តព្រះអង្គកងជុំ សម្ពោធឆ្លងកុដិ និងបុណ្យផ្កាប្រាក់សាមគ្គី នៅវត្តព្រះអង្គកងជុំ (ហៅវត្តព្រះអង្គខ្មៅ) ខេត្តសៀមរាប។



*ឯកឧត្តម អ៊ុច បូរិទ្ធ អញ្ជើញចូលរួមពិធីចម្រើនអាយុវឌ្ឍនមង្គល សម្ពោធសមិទ្ធផលនានានៅក្នុងវត្តព្រះអង្គកងជុំ*

ជាមួយនឹងការអញ្ជើញចូលរួមជាអធិបតីក្នុងពិធីចម្រើនអាយុវឌ្ឍនមង្គល នាពេលនោះ **ឯកឧត្តមប្រធានស្ដីទីព្រឹទ្ធសភា** និងលោកជំទាវ បានអញ្ជើញផ្ដល់កិត្តិយសកាត់




*ឯកឧត្តម អ៊ុច បូរិទ្ធ និងលោកជំទាវ អញ្ជើញស្រោចសុគន្ធវារីប្រគេនព្រះវិរិយានុបាល សេង ពេជ្រ ព្រះចៅអធិការវត្តព្រះអង្គកងជុំ*



*ឯកឧត្តម អ៊ុច បូររិទ្ធ អញ្ជើញកាត់ខ្សែបូសម្ពោធឆ្លងកុដិ*



*ឯកឧត្តម អ៊ុច បូររិទ្ធ អញ្ជើញវេរប្រគេនផ្កាប្រាក់សាមគ្គីដល់ព្រះសង្ឃ*

ខ្សែបូសម្ពោធឆ្លងកុដិ ដែលជាអំណោយដ៏ថ្លៃថ្លារបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុនសែន** ព្រមទាំងមានការដង្ហែអង្គផ្កាប្រាក់សាមគ្គី វេរប្រគេន ដើម្បីប្រមូលបច្ច័យកសាងសមិទ្ធផលនានានៅក្នុងវត្តព្រះអង្គកងជុំ។



*ឯកឧត្តម អ៊ុច បូររិទ្ធ និងលោកជំទាវ អញ្ជើញរាប់បាត្រប្រគេនព្រះសង្ឃ*

នាវេលាព្រឹកថ្ងៃដដែល **ឯកឧត្តមប្រធានស្តីទីព្រឹទ្ធសភា** អមដំណើរដោយ ឯកឧត្តម លោកជំទាវ ជាទីប្រឹក្សានិងសហការី បានអញ្ជើញនាំយកអំណោយដ៏ថ្លៃថ្លារបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុនសែន** ប្រគល់ជូនដល់វីរកងទ័ពជួរមុខកំពុងឈរជើងការពារព្រំដែននៅតំបន់ប្រាសាទតាមាន់និងប្រាសាទតាក្របី រួមមាន៖ ស៊ីទែនស្តុកទឹកចំណុះ២.០០០លីត្រចំនួន២០ស៊ីទែននិងទឹកបរិសុទ្ធចំនួន៤០០យួរ នៅសាលាខេត្តសៀមរាប។

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន



*ឯកឧត្តម អ៊ុច បូររិទ្ធ អញ្ជើញនាំយកសម្ភារៈចាំបាច់ជូនដល់វីរកងទ័ពជួរមុខ នៅតំបន់ប្រាសាទតាមាន់ និងប្រាសាទតាក្របី*

# ឯកឧត្តម អ៊ុច បូររិទ្ធ អញ្ជើញជួបសំណេះសំណាល និងចែកកញ្ចប់អាហារស្រាយបួស ខែរ៉ាម៉ាឧនជូនប្រជាពលរដ្ឋខ្មែរអ៊ិស្លាម ប្រមាណជាង៤00គ្រួសារ នៅក្រុងកំពង់ចាម និងស្រុកកងមាស



ឯកឧត្តម អ៊ុច បូររិទ្ធ អញ្ជើញសំណេះសំណាល និងចែកកញ្ចប់អាហារស្រាយបួសជូនប្រជាពលរដ្ឋខ្មែរអ៊ិស្លាម នៅក្រុងកំពង់ចាម

នាព្រឹកថ្ងៃអង្គារ ទី១០ ខែមីនា ឆ្នាំ២០២៦ ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ (ខេត្តកំពង់ចាម និងខេត្តត្បូងឃ្មុំ) ដឹកនាំដោយ ឯកឧត្តម **អ៊ុច បូររិទ្ធ** ប្រធានស្តីទីព្រឹទ្ធសភានិងជាប្រធានក្រុម អមដំណើរដោយឯកឧត្តម **អ៊ុន ចាន់ដា** អភិបាលនៃគណៈអភិបាលខេត្តកំពង់ចាម បានអញ្ជើញជួបសំណេះ-សំណាល និងចែកកញ្ចប់អាហារស្រាយបួស ខែរ៉ាម៉ាឧន ជូនប្រជាពលរដ្ឋខ្មែរអ៊ិស្លាមប្រមាណជាង៤00គ្រួសារ នៅក្នុងសង្កាត់សំបួរមាស ក្រុងកំពង់ចាម និងឃុំពាមជីកង ស្រុកកងមាស ខេត្តកំពង់ចាម។



ឯកឧត្តម អ៊ុច បូររិទ្ធ អញ្ជើញចែកកញ្ចប់អាហារស្រាយបួស ជូនប្រជាពលរដ្ឋខ្មែរអ៊ិស្លាម នៅក្រុងកំពង់ចាម

ក្នុងឱកាសនោះ **ឯកឧត្តមប្រធានស្តីទី** បាននាំនូវប្រសាសន៍ផ្តាំផ្ញើសួរសុខទុក្ខនិងក្តីនឹករលឹកពីសំណាក់សម្តេចតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភានិង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ជូនដល់បងប្អូនប្រជាពលរដ្ឋទាំងអស់ ព្រមទាំងជម្រាបជូនពីសភាពការណ៍ដែលបាននិងកំពុងកើតមាននៅតាមបណ្តោយព្រំដែនកម្ពុជា-ថៃនិងបានសម្តែងនូវការគោរពដឹងគុណចំពោះវីរភាពដ៏អង់អាចក្លាហានរបស់វីរកងទ័ពជួរមុខកម្ពុជានៅតាមបណ្តោយព្រំប្រទល់កម្ពុជា-ថៃ



ឯកឧត្តម អ៊ុច បូររិទ្ធ អញ្ជើញថតរូបអនុស្សាវរីយ៍ ជាមួយរដ្ឋបាលខេត្តកំពង់ចាម

ដែលបានក្រាញ់ននៀល តស៊ូពុះពារគ្រប់បែបយ៉ាងក្នុងការការពារបូរណភាពទឹកដីកម្ពុជាពីការឈ្លានពានដ៏ព្រៃផ្សៃដោយកងទ័ពថៃ។ ឯកឧត្តមបានគូសបញ្ជាក់ថា ការឈឺចាប់របស់បងប្អូនប្រជាពលរដ្ឋនៅទូទាំងប្រទេសដែលបង្កឡើងដោយអំពើឈ្លានពាននេះ បានប្រែក្លាយជាកម្លាំងចលករជំរុញឱ្យកម្លាំងមហាសាមគ្គីនិងឯកភាពជាតិកាន់តែរឹងមាំខ្លាំងក្លាថែមទៀត រួបរួមគ្នាជុំវិញ **សម្តេចតេជោ** ប្រធានព្រឹទ្ធសភា និងសម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្រ្តីកម្ពុជា ក្នុងការចាត់វិធានការការពារបូរណភាពទឹកដី សុខសន្តិភាព និងការអភិវឌ្ឍប្រទេសជាតិ។

ទន្ទឹមនឹងការអបអរសាទរបុណ្យរ៉ាម៉ាឌន **ឯកឧត្តមប្រធានស្តីទីព្រឹទ្ធសភា** បានមានប្រសាសន៍ថា ទោះជាបងប្អូនមាននិន្នាការនយោបាយ ជំនឿសាសនាផ្សេងៗគ្នាយ៉ាងណាក៏ដោយ តែកុំភ្លេចថាខ្លួនយើងទាំងអស់គ្នាមានឈាមជ័រតែមួយគឺខ្មែរ ដែលចាំបាច់ត្រូវរក្សាឱ្យបាននូវស្មារតីសាមគ្គីភាពរួមគ្នាការពារជាតិមាតុភូមិ និងតម្កល់ខ្ពស់បំផុតនូវផលប្រយោជន៍ប្រទេសជាតិជាងអ្វីៗទាំងអស់។

**ឯកឧត្តមប្រធានស្តីទីព្រឹទ្ធសភា** បានអំពាវនាវឱ្យសិស្សានុសិស្សខ្មែរអ៊ិស្លាមទាំងអស់ខិតខំរៀនសូត្រ ដើម្បីយកចំណេះដឹងនិងមុខជំនាញ ចូលរួមចំណែកកសាងប្រទេសជាតិឱ្យកាន់តែរីកចម្រើន សមស្របតាមពាក្យស្លោកទំពាំងស្នងឫស្សីនិងជាអ្នកបន្តវេនសម្រាប់ប្រទេសជាតិនាពេលអនាគត។



*ឯកឧត្តម អ៊ុច បូរិទ្ធ អញ្ជើញសំណេះសំណាល និងចែកកញ្ចប់អាហារស្រាយបួសជូនប្រជាពលរដ្ឋខ្មែរអ៊ិស្លាម នៅស្រុកកងមាស*

ឆ្លៀតក្នុងឱកាសនោះដែរ **ឯកឧត្តមប្រធានស្តីទីព្រឹទ្ធសភា** បានរំឭកឱ្យបងប្អូនទាំងអស់មានការប្រុងប្រយ័ត្នចំពោះការឃោសនាអុជអាលបំបែកបំបាក់សង្គមជាតិ ពីសំណាក់ពួកជនអគតិមួយចំនួនតូច ដើម្បីផលប្រយោជន៍នយោបាយផ្ទាល់របស់ខ្លួន ដែលជាគ្រោះហានិភ័យចំពោះអនាគតប្រទេសជាតិ និងបានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះប្រជាពលរដ្ឋទាំងអស់ ដែលបានពួតដៃគ្នា ថែរក្សាសុខសន្តិភាព សុខដុមនីយកម្មជាតិសាសន៍ និងសាសនា ហើយមានជំនឿជឿជាក់លើការដឹកនាំ ប្រកបដោយគតិបណ្ឌិតរបស់សម្តេចតេជោ **ហ៊ុន សែន** និងសម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។

អត្ថបទ៖ ខុទ្ទកាល័យឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា

រូបភាព៖ នាយកដ្ឋានព័ត៌មាន



*ទិដ្ឋភាពក្នុងពិធីសំណេះសំណាល និងចែកកញ្ចប់អាហារស្រាយបួសជូនប្រជាពលរដ្ឋខ្មែរអ៊ិស្លាម នៅស្រុកកងមាស*

# ឯកឧត្តម អ៊ុច បូររិទ្ធ អញ្ជើញចុះជួបសំណេះសំណាលជាមួយសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ និងមន្ត្រីអាជ្ញាធរមូលដ្ឋានគ្រប់ជាន់ថ្នាក់ នៅទូទាំងក្រុង ស្រុកទាំង១០ ក្នុងខេត្តកំពង់ចាម

នាថ្ងៃទី១៧ ដល់ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២៦ ឯកឧត្តម **អ៊ុច បូររិទ្ធ** ប្រធានស្តីទីព្រឹទ្ធសភា



*ឯកឧត្តម អ៊ុច បូររិទ្ធ អញ្ជើញសំណេះសំណាលជាមួយសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ និងមន្ត្រីអាជ្ញាធរមូលដ្ឋាន សាលាខេត្តកំពង់ចាម*

និងជាប្រធានក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ បានដឹកនាំក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ អញ្ជើញចុះជួបសំណេះសំណាលជាមួយសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ និងមន្ត្រីអាជ្ញាធរមូលដ្ឋានគ្រប់ជាន់ថ្នាក់ នៅទូទាំងក្រុង ស្រុកទាំង១០ ក្នុងខេត្តកំពង់ចាម សរុបចំនួន២១២៩នាក់ ដើម្បីផ្សព្វផ្សាយអំពីសភាពការណ៍កម្ពុជានិងពិភពលោកនាពេលបច្ចុប្បន្ននិងសមិទ្ធផលនានា ក៏ដូចជាស្វែងយល់អំពីតម្រូវការនិងសំណូមពរផ្សេងៗនៅមូលដ្ឋាន។

បន្ទាប់ពីការធ្វើបទឧទ្ទេសនាមដោយ ឯកឧត្តម លោកជំទាវ សមាជិក សមាជិកា និងក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ ស្តីពីការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព ផែនការអភិវឌ្ឍន៍មូលដ្ឋាន និងការគ្រប់គ្រងថវិកាឃុំ សង្កាត់ ព្រមទាំងគោលនយោបាយវិមជ្ឈការនិងវិសហមជ្ឈការ **ឯកឧត្តមប្រធានស្តីទី** បាននាំនូវការផ្តាំផ្ញើសួរសុខទុក្ខ និងក្តីនឹករលឹកយ៉ាងជ្រាលជ្រៅបំផុតជូនដល់អង្គពិធីទាំងមូលពីសំណាក់ **សម្តេចតេជោ** ប្រធានព្រឹទ្ធសភា និងបានជម្រាបជូនអំពីមុខងារស្នូលសកម្មភាព និងសមិទ្ធផលសំខាន់ៗ ក្នុងសម័យប្រជុំលើកទី៤ ព្រឹទ្ធសភានីតិកាលទី៥ ព្រមទាំងបានគូសបញ្ជាក់អំពីគុណតម្លៃមិនអាចកាត់ថ្លៃបាននៃសន្តិភាព ដែលកម្ពុជាទទួលបានតាមរយៈនយោបាយឈ្នះ-ឈ្នះ ដែលមាន **សម្តេចតេជោ** ជាបិតាស្ថាបនិក និងជាអគ្គមគ្គុទ្ទេសក៍ឯកដែលជាលក្ខខណ្ឌមិនអាចខ្វះបាននៅក្នុងការលើកកម្ពស់សុខុមាលភាពប្រជាជននិងការអភិវឌ្ឍប្រទេសជាតិរីកចម្រើនរហូតមកដល់បច្ចុប្បន្ន។

ពាក់ព័ន្ធនឹងករណីជម្លោះព្រំដែនកម្ពុជា-ថៃ **ឯកឧត្តមប្រធានស្តីទី** បានរំឭកជូនអង្គពិធីអំពីប្រវត្តិសាវតារ នៃអាណាចក្រខ្មែរនិងជនជាតិសៀម ដោយឆ្លុះបញ្ចាំងអំពីឫសគល់បញ្ហា ជាពិសេសការបំភ្លៃសច្ចភាពប្រវត្តិសាស្ត្រ ការលួចចម្លងប្រពៃណី វប្បធម៌ និងអរិយធម៌ដ៏ឧត្តុង្គឧត្តមរបស់ប្រជាជាតិកម្ពុជា ដែលមានចារឹកទុកនៅលើទំព័រប្រវត្តិ-សាស្ត្រ និងសិលាចារឹកនៃប្រាង្គប្រាសាទនានាជាភស្តុតាង។

ជាមួយគ្នានោះ **ឯកឧត្តមប្រធានស្តីទី** បានគូសបញ្ជាក់អំពីសុច្ឆន្ទៈ និងគោលនយោបាយការបរទេសរបស់រាជរដ្ឋា-ភិបាលកម្ពុជាក្នុងការរួមរស់ដោយសន្តិសហវិជ្ជមាន ពង្រឹងពង្រីកចំណងមិត្តភាព និងកិច្ចសហប្រតិបត្តិការល្អប្រសើរជាមួយបណ្តាប្រទេសទាំងអស់ក្នុងពិភពលោក ដើម្បីជាគុណប្រយោជន៍ដល់សន្តិភាព និងការអភិវឌ្ឍក្នុងតំបន់និងពិភពលោក។ ឯកឧត្តមបានសង្កត់ធ្ងន់ថា ការគោរពច្បាប់អន្តរជាតិ គោលការណ៍ធម្មនុញ្ញអង្គការសហប្រជាជាតិ និងធម្មនុញ្ញអាស៊ាន ព្រមទាំងឯកសារគតិយុត្តពាក់ព័ន្ធទាំងអស់ដែលភាគីទាំងពីរព្រមព្រៀងគ្នា គឺជាមូលដ្ឋានគ្រឹះសំខាន់ណាស់ក្នុងការកសាងទំនុកចិត្ត និងជាលក្ខខណ្ឌមិនអាចខ្វះ



*ទិដ្ឋភាពក្នុងពិធីសំណេះសំណាល*

បានក្នុងការកសាងសន្តិភាពរឹងមាំពិតប្រាកដ ដើម្បីជាគុណប្រយោជន៍សម្រាប់ប្រជាជនទាំងពីរ។

**ឯកឧត្តមប្រធានស្តីទី** បានបន្ថែមថា ទោះក្នុងកាលៈទេសៈណាក៏ដោយ ប្រជាជននិងរាជរដ្ឋាភិបាលកម្ពុជានៅតែប្រកាន់ខ្ជាប់ជានិច្ចនូវការអត់ធ្មត់ជាអតិបរមា និងប្រកាន់ជំហរឥតងាករេខិតខំប្រឹងប្រែងរិះរកដំណោះស្រាយបញ្ហាតាមរយៈការចរចាដោយសន្តិវិធី នៅក្នុងក្របខ័ណ្ឌច្បាប់អន្តរជាតិ ធម្មនុញ្ញអង្គការសហប្រជាជាតិ និងធម្មនុញ្ញអាស៊ាន ប្រែក្លាយបន្ទាត់ព្រំដែនជាខ្សែបន្ទាត់សន្តិភាពនិងអភិវឌ្ឍន៍។

ទន្ទឹមនឹងនោះ **ឯកឧត្តមប្រធានស្តីទី** បានសម្តែងនូវមោទនភាពជាតិខ្ពស់បំផុត ចំពោះកម្លាំងរួបរួមសាមគ្គីឯកភាពជាតិជាធ្លុងមួយរឹងមាំរបស់បងប្អូនប្រជាពលរដ្ឋគ្រប់ស្រទាប់វណ្ណៈ គ្រប់និន្នាការនយោបាយ សាសនា ទាំងក្នុងនិងក្រៅប្រទេស គាំទ្រទាំងកម្លាំងកាយ ចិត្ត និងសម្ភារៈដល់វីរយុទ្ធជននៅសមរភូមិជួរមុខ និងបងប្អូនប្រជាជនភៀសសឹក នៅក្នុងដំណាក់កាលដែលប្រទេសជាតិទទួលរងនូវអំពើឈ្លានពានព្រៃផ្សៃ ព្រមទាំងសម្តែងនូវការគោរពដឹងគុណនិងកោតសរសើរចំពោះវីរភាពដ៏អង់អាចក្លាហានរបស់កងទ័ពជួរមុខកម្ពុជា នៅតាមបណ្តោយព្រំប្រទល់កម្ពុជា-ថៃ ដែលបានក្រាញ់ននៀល តស៊ូពុះពារគ្រប់បែបយ៉ាងក្នុងការការពារបូរណភាពទឹកដីកម្ពុជា។ ឯកឧត្តមបានអំពាវនាវដល់បងប្អូនបន្តជឿជាក់លើការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចតេជោ** ប្រធានព្រឹទ្ធសភា និង**សម្តេចធិបតី** នាយករដ្ឋមន្ត្រីកម្ពុជា ដែលជាប្រមុខដឹកនាំដ៏ឆ្នើម ក្នុងការការពារបូរណភាពទឹកដី សុខសន្តិភាព និងការអភិវឌ្ឍប្រទេសជាតិ។



*ឯកឧត្តម ស្លេះ ពុនយ៉ាម៉ីន អញ្ជើញមានមតិយោបល់ក្នុងអង្គពិធី*

ឆ្លៀតក្នុងឱកាសនោះ **ឯកឧត្តមប្រធានស្តីទី** ក៏បានលើកឡើងអំពីការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការទប់ស្កាត់តម្លៃប្រេងដែលកំពុងហក់ឡើង បង្កឡើងដោយសង្គ្រាមនៅមជ្ឈិមបូព៌ានិងអំពាវនាវដល់ថ្នាក់ដឹកនាំខេត្ត ក្រុង ស្រុក បន្តអនុវត្តអនុក្រឹត្យលេខ០៣ របស់រាជរដ្ឋាភិបាល ស្តីពីការគ្រប់គ្រងសន្តិសុខ សុវត្ថិភាពតាមទីតាំងរស់នៅប្រមូលផ្តុំ ដើម្បីបង្ការ ទប់ស្កាត់ បង្ក្រាបនិងបោសសម្អាតបទល្មើសនានា ជាពិសេសបទល្មើសឆបោកតាមប្រព័ន្ធអនឡាញ (Online Scams) និងបញ្ហាគ្រឿងញៀន។

ជាទីបញ្ចប់ **ឯកឧត្តមប្រធានស្តីទី** បានផ្តាំផ្ញើដល់បងប្អូនក្រុមប្រឹក្សាឃុំ សង្កាត់ទាំងអស់ ត្រូវជុសខាត់សមត្ថភាព និងរៀបចំខ្លួនឱ្យក្លាយជាមន្ត្រីសាធារណៈគំរូ សម្រាប់ត្រៀមការបោះឆ្នោតក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៦ នៅឆ្នាំ២០២៧ ខាងមុខ និងបានចែកជូនសម្ភារៈប្រើប្រាស់មួយចំនួនជូនគ្រប់សមាជិក សមាជិកា ចូលរួមក្នុងអង្គពិធីផងដែរ៕

អត្ថបទ៖ ខុទ្ទកាល័យឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា

រូបភាព៖ នាយកដ្ឋានព័ត៌មាន



*ឯកឧត្តម អ៊ុច បូរិទ្ធ អញ្ជើញសំណេះសំណាលជាមួយសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ និងមន្ត្រីអាជ្ញាធរមូលដ្ឋាន នៅស្រុកជើងព្រៃ ខេត្តកំពង់ចាម*

# ឯកឧត្តម អ៊ុច បូររិទ្ធ អនុញ្ញាតឱ្យអគ្គលេខាធិការរដ្ឋសភាហុងគ្រី ចូលជួបសម្តែងការគួរសម



*ឯកឧត្តម អ៊ុច បូររិទ្ធ ប្រធានស្តីទីព្រឹទ្ធសភា*



*ឯកឧត្តមបណ្ឌិត György Such អគ្គលេខាធិការរដ្ឋសភាហុងគ្រី*

នៅព្រឹកថ្ងៃទី១១ ខែមីនា ឆ្នាំ២០២៦ ឯកឧត្តម **អ៊ុច បូររិទ្ធ** ប្រធានស្តីទីព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា បានអនុញ្ញាតឱ្យ ឯកឧត្តមបណ្ឌិត György Such អគ្គលេខាធិការរដ្ឋសភាហុងគ្រី ចូលជួបសម្តែងការគួរសម នៅវិមានសាមគ្គីភាពនៃព្រឹទ្ធសភាកម្ពុជា។

**ឯកឧត្តមប្រធានស្តីទីព្រឹទ្ធសភា**និង**ឯកឧត្តមអគ្គលេខាធិការរដ្ឋសភាហុងគ្រី** បានវាយតម្លៃខ្ពស់ចំពោះទំនាក់ទំនងមិត្តភាពយូរអង្វែង និងកិច្ចសហប្រតិបត្តិការលើវិស័យជាច្រើនដែលបានផ្តល់ផលប្រយោជន៍ដល់ប្រទេសទាំងពីរ ព្រមទាំងបានរំលឹកអំពីការរីកចម្រើននៃទំនាក់ទំនងយ៉ាងជិតស្និទ្ធរវាងស្ថាប័ននីតិប្បញ្ញត្តិ ដែលឆ្លុះបញ្ចាំងតាមរយៈការផ្លាស់ប្តូរទស្សនកិច្ចជាន់ខ្ពស់ និងការរក្សាកិច្ចសន្ទនារវាងគ្នាទៅវិញទៅមក។ ភាគីទាំងពីរក៏បានពិភាក្សារិះរកមធ្យោបាយជំរុញសហប្រតិបត្តិការឱ្យកាន់តែមានភាពជាក់ស្តែងបន្ថែមទៀត ជាពិសេស ក្នុងបរិបទដែលស្ថានការណ៍អន្តរជាតិ បន្តវិវត្តយ៉ាងឆាប់រហ័សនិងបង្កជាបញ្ហាប្រឈម ដែលកំពុងកើនឡើងចំពោះសន្តិភាព សន្តិសុខ និងការអភិវឌ្ឍ។ ភាគីទាំងពីរក៏បានផ្លាស់ប្តូរទស្សនៈគ្នាផងដែរ ដោយបានផ្តោតសារៈសំខាន់លើការពង្រីកសហប្រតិបត្តិការលើវិស័យដែលផ្តល់ប្រយោជន៍រួម រួមមាន៖ ការទូត សេដ្ឋកិច្ច ថាមពល អប់រំ ទេសចរណ៍ និងទំនាក់ទំនងរវាងប្រជាជននិងប្រជាជនក៏ដូចជាលើបញ្ហាតំបន់ដែលជាកង្វល់រួម។

ក្រោយជំនួប **ឯកឧត្តមប្រធានស្តីទីព្រឹទ្ធសភា** បានធ្វើជាអធិបតីក្នុងពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់គ្នារវាងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាកម្ពុជា និងអគ្គលេខាធិការដ្ឋានរដ្ឋសភាហុងគ្រី។ គោលបំណងនៃការចុះអនុស្សរណៈខាងលើ គឺដើម្បីជំរុញកិច្ចសហប្រតិបត្តិការស្ថាប័នតាមរយៈការផ្លាស់ប្តូរបទពិសោធ ទស្សនកិច្ចសិក្សា កិច្ចសន្ទនាវិជ្ជាជីវៈ និងសកម្មភាពកសាងសមត្ថភាព ក្នុងគោលដៅបង្កើតផលប្រយោជន៍ជាក់ស្តែងសម្រាប់ស្ថាប័នទាំងពីរ និងរួមចំណែកដល់ការពង្រឹងទំនាក់ទំនងទ្វេភាគីឱ្យកាន់តែទូលំទូលាយ។

អត្ថបទ៖ ខុទ្ទកាល័យឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា

រូបភាព៖ នាយកដ្ឋានព័ត៌មាន



*ឯកឧត្តមអគ្គលេខាធិការរដ្ឋសភាហុងគ្រី ចុះ MoU ជាមួយ ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភាកម្ពុជា*

# ឯកឧត្តម អ៊ុច បូររិទ្ធ អនុញ្ញាតឱ្យឯកឧត្តមឯកអគ្គរដ្ឋទូត នៃសាធារណរដ្ឋកូរ៉េ ប្រចាំកម្ពុជា ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ

នៅព្រឹកថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២៦ នៅវិមានសាមគ្គីភាព នៃព្រឹទ្ធសភា ឯកឧត្តម **អ៊ុច បូររិទ្ធ** ប្រធានស្តីទីព្រឹទ្ធសភា បានអនុញ្ញាតឱ្យឯកឧត្តម KIM Chang Yong ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពនៃសាធារណរដ្ឋកូរ៉េ ប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ។

វិស័យរវាងកម្ពុជានិងសាធារណរដ្ឋកូរ៉េ រីកចម្រើនរហូតដល់បច្ចុប្បន្ន ក្នុងភាពជាដៃគូយុទ្ធសាស្ត្រ។

**ឯកឧត្តមប្រធានស្តីទីព្រឹទ្ធសភា** បានគូសបញ្ជាក់ថា កម្ពុជានិងសាធារណរដ្ឋកូរ៉េ មានចំណងមិត្តភាពរឹងមាំ និងមានសក្តានុពលធំធេងក្នុងការពង្រីកកិច្ចសហប្រតិបត្តិការថែមទៀត ទាំងក្នុងក្របខ័ណ្ឌទ្វេភាគី និងកម្រិតស្ថាប័ននីតិប្បញ្ញត្តិ។



*ឯកឧត្តម KIM Chang Yong និងឯកឧត្តម អ៊ុច បូររិទ្ធ*

ក្នុងជំនួបនោះ ឯកឧត្តម **អ៊ុច បូររិទ្ធ** បានសម្តែងការស្វាគមន៍យ៉ាងកក់ក្តៅចំពោះ**ឯកឧត្តមឯកអគ្គរដ្ឋទូត** និងបានវាយតម្លៃខ្ពស់ចំពោះទំនាក់ទំនងមិត្តភាព និងសហប្រតិបត្តិការដ៏ល្អប្រសើររវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋកូរ៉េ ដែលបាននិងកំពុងរីកចម្រើនជាបន្តបន្ទាប់លើគ្រប់វិស័យ។ ឯកឧត្តមបានគូសបញ្ជាក់ថា ផ្លែផ្កានៃទំនាក់ទំនងដ៏ល្អប្រសើរនេះ កើតចេញពីចក្ខុវិស័យនិងការខិតខំយ៉ាងសកម្មរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រមុខរដ្ឋស្តីទី ដែលជាស្ថាបនិកក្នុងការផ្សារភ្ជាប់ទំនាក់ទំនងការទូតរវាងប្រទេសទាំងពីរឡើងវិញនៅឆ្នាំ១៩៩៧ និងជំរុញទំនាក់ទំនងមិត្តភាព និងសហប្រតិបត្តិការលើគ្រប់

**ឯកឧត្តមប្រធានស្តីទីព្រឹទ្ធសភា** ក៏បានថ្លែងអំណរគុណចំពោះរដ្ឋាភិបាល និងប្រជាជនកូរ៉េ ដែលបានបន្តគាំទ្រដល់ការអភិវឌ្ឍកម្ពុជា តាមរយៈគម្រោងជាច្រើនក្រោមក្របខ័ណ្ឌ ODA, KOICA និង EDCF។ ជាមួយគ្នានេះ ឯកឧត្តមបានគូសបញ្ជាក់ពីសារៈសំខាន់នៃការទូតសភា ក្រោមការដឹកនាំរបស់ **សម្តេចតេជោ** ប្រមុខរដ្ឋស្តីទី ដើម្បីបន្តជំរុញកិច្ចសហប្រតិបត្តិការរវាងព្រឹទ្ធសភាកម្ពុជា និងរដ្ឋសភានៃសាធារណរដ្ឋកូរ៉េ តាមរយៈក្រុមមិត្តភាពសភា ការផ្លាស់ប្តូរទស្សនកិច្ច និងការពង្រឹងយន្តការសម្របសម្រួលរវាងស្ថាប័ននីតិប្បញ្ញត្តិនៃប្រទេសទាំងពីរ ឱ្យកាន់តែមានប្រសិទ្ធភាព និងផ្លែផ្កាបន្ថែមទៀត ហើយបានសម្តែងបំណងជំរុញ



*ទិដ្ឋភាពក្នុងជំនួបសម្តែងការគួរសមនិងពិភាក្សាការងារ*

ទំនាក់ទំនងកម្ពុជានិងសាធារណរដ្ឋកូរ៉េ ពីកម្រិត «ភាពជាដៃគូយុទ្ធសាស្ត្រ» ទៅកាន់ «ភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ»។

ជាកិច្ចឆ្លើយតប **ឯកឧត្តមឯកអគ្គរដ្ឋទូត** បានថ្លែងអំណរគុណចំពោះការទទួលស្វាគមន៍យ៉ាងកក់ក្តៅ និងបានវាយតម្លៃខ្ពស់ចំពោះតួនាទីដ៏សំខាន់របស់ **សម្តេចតេជោ** ប្រមុខរដ្ឋស្តីទី ក្នុងការពូនជ្រំ និងលើកកម្ពស់ទំនាក់ទំនងមិត្តភាពនិងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ។ ឯកឧត្តមបានគូសបញ្ជាក់ផងដែរថា ឆ្នាំ២០២៧ ដែលជាខួបលើកទី៣០ឆ្នាំ នៃការភ្ជាប់ទំនាក់ទំនងការទូតឡើងវិញរវាងកម្ពុជា និងសាធារណរដ្ឋកូរ៉េ គឺជាកាលានុវត្តភាពដ៏សំខាន់សម្រាប់លើកកម្ពស់ទំនាក់ទំនងទ្វេភាគីឱ្យឈានទៅកម្រិតថ្មីមួយទៀត។

ភាគីទាំងពីរ បានវាយតម្លៃខ្ពស់ចំពោះកិច្ចសហប្រតិបត្តិ-ការរវាងកម្ពុជានិងសាធារណរដ្ឋកូរ៉េ ក្នុងការប្រយុទ្ធប្រឆាំងនឹងបទល្មើសឆបោកតាមប្រព័ន្ធអនឡាញ ដែលកន្លងមកទទួលបានលទ្ធផលជាក់ស្តែងគួរឱ្យកត់សម្គាល់។ **ឯកឧត្តមប្រធានស្តីទីព្រឹទ្ធសភា** បានគូសបញ្ជាក់ថា កម្ពុជាបន្តគាំទ្រនិងយកចិត្តទុកដាក់ខ្ពស់ចំពោះកិច្ចសហប្រតិបត្តិការនេះ ដោយចាត់ទុកថា បទល្មើសឆបោកអនឡាញ គឺជាបញ្ហាសកល ដែលទាមទារឱ្យមានការសហការយ៉ាងជិតស្និទ្ធពីបណ្តាប្រទេសពាក់ព័ន្ធ។

ទន្ទឹមនឹងនោះ ភាគីទាំងពីរ ក៏បានផ្លាស់ប្តូរយោបល់អំពីការពង្រឹងទំនាក់ទំនងរវាងប្រជាជន ជាពិសេសតាមរយៈការអភិវឌ្ឍធនធានមនុស្ស ការបណ្តុះបណ្តាលជំនាញ ការផ្តល់អាហារូបករណ៍និងការបង្កើនឱកាសសិក្សា និងការងារដល់យុវជនកម្ពុជា។



*ទិដ្ឋភាពក្នុងជំនួបសម្តែងការគួរសមនិងពិភាក្សាការងារ*

នៅចុងបញ្ចប់ ភាគីទាំងពីរ បានសម្តែងការពេញចិត្តចំពោះវឌ្ឍនភាពនៃទំនាក់ទំនងកម្ពុជានិងសាធារណរដ្ឋកូរ៉េ និងបានឯកភាពបន្តពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការទ្វេភាគីឱ្យកាន់តែស៊ីជម្រៅ និងមានប្រសិទ្ធភាពខ្ពស់ថែមទៀត ដើម្បីផលប្រយោជន៍រួមនៃប្រជាជននិងប្រទេសទាំងពីរ៕

អត្ថបទ៖ ខុទ្ទកាល័យឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា

រូបភាព៖ នាយកដ្ឋានព័ត៌មាន

# ឯកឧត្តមបណ្ឌិត ធន់ វឌ្ឍនា ជំរុញការអភិវឌ្ឍ «កសិ-ទេសចរណ៍» និងលើកកម្ពស់ដំណាំយុទ្ធសាស្ត្រនៅភូមិភាគឦសាន

ក្នុងដំណើរទស្សនកិច្ចឈ្វេងយល់ពីសក្តានុពលកសិកម្ម នៅភូមិភាគឦសាន ពីថ្ងៃទី២៧ ខែកុម្ភៈ ដល់ថ្ងៃទី១ ខែមីនា ឆ្នាំ២០២៦ ឯកឧត្តមបណ្ឌិត **ធន់ វឌ្ឍនា** អនុប្រធានទី២ ព្រឹទ្ធសភា បានអញ្ជើញជួបសំណេះសំណាលជាមួយក្រុមប្រឹក្សាសង្កាត់សុខដុម ក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី ព្រមទាំងចុះទស្សនកិច្ចចម្ការកាកាវ នៅខេត្តរតនគិរី និងចម្ការកាហ្វេ PIDA ខេត្តមណ្ឌលគិរី ក្នុងគោលបំណងសំខាន់ គឺដើម្បីស្វែងយល់ពីសក្តានុពលវិស័យទេសចរណ៍ និងស្ថានភាពដំណាំកាកាវ និងដំណាំកាហ្វេ នៅក្នុងតំបន់ភូមិភាគឦសានទាំងមូល។




*ឯកឧត្តមបណ្ឌិត ធន់ វឌ្ឍនា អញ្ជើញធ្វើបទបាឋកថា ដល់សាស្ត្រាចារ្យ និងនិស្សិត នៃសាកលវិទ្យាល័យជាតិជាស៊ីមកំចាយមារ*

នៅក្នុងជំនួបជាមួយក្រុមប្រឹក្សាសង្កាត់សុខដុម **ឯកឧត្តមបណ្ឌិត**បានផ្តាំផ្ញើដល់អាជ្ញាធរមូលដ្ឋានឱ្យខិតខំប្រកួតប្រជែងប្រកបដោយភាពច្នៃប្រឌិតក្នុងការទាក់ទាញភ្ញៀវទេសចរ និងគាំទ្រអ្នកវិនិយោគ។ ជាក់ស្តែង ត្រូវជំរុញការលក់ម្ហូបអាហារក្នុងស្រុកដែលមានរសជាតិឆ្ងាញ់ពិសា ប្លែកពីគេ និងត្រូវយកចិត្តទុកដាក់ខ្ពស់លើអនាម័យ ព្រមទាំងកំណត់តម្លៃសមរម្យ។ ទន្ទឹមនឹងនេះ ការរៀបចំទីតាំងកម្សាន្ត និងទស្សនីយភាពថ្មីៗក៏ជាចំណុចសំខាន់ដើម្បីជំរុញសេដ្ឋកិច្ច និងលើកកម្ពស់ជីវភាពប្រជាពលរដ្ឋ។

**ឯកឧត្តមបណ្ឌិត** ក៏បានសង្កត់ធ្ងន់លើការសម្រួលគ្រប់បែបយ៉ាងដល់អាជីវករ ទេសចរ និងវិនិយោគិន ដើម្បីចូលរួមចំណែកក្នុងចក្ខុវិស័យកសាងកម្ពុជាឱ្យក្លាយជាប្រទេសមានចំណូលកម្រិតខ្ពស់នៅឆ្នាំ២០៥០។ ឯកឧត្តមបានលើកទឹកចិត្តអាជ្ញាធរមូលដ្ឋានបន្តថែរក្សាសុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ និងចូលរួមលុបបំបាត់បាតុភាពឆបោកតាមប្រព័ន្ធអនឡាញ ដើម្បីធានាបរិយាកាសល្អក្នុងមូលដ្ឋាន។

ក្នុងឱកាសអញ្ជើញទស្សនកិច្ចចម្ការកាកាវ នៅខេត្តរតនគិរី និងចម្ការកាហ្វេ PIDA នៅមណ្ឌលគិរី ឯកឧត្តមបណ្ឌិត **ធន់ វឌ្ឍនា** បានមានប្រសាសន៍ថា ការដាំដុះកាកាវនៅតំបន់ខ្ពង់រាបរួមមាន៖ ខេត្តរតនគិរី ខេត្តមណ្ឌលគិរី ខេត្តក្រចេះ និងខេត្តស្ទឹងត្រែង គឺផ្តល់ប្រាក់ចំណូលខ្ពស់ដល់កសិករ បើប្រៀបធៀបទៅនឹងការដាំដុះស្រូវ ដោយហេតុថាតំបន់នេះមានសណ្ឋានដីជាតំបន់ខ្ពស់ និងអាកាសធាតុត្រជាក់ ដែលអំណោយផលខ្ពស់ដល់ការលូតលាស់និងទិន្នផលកាកាវ ជាជាងការដាំដុះស្រូវ។ កាកាវ ជារុក្ខជាតិប្រភេទដំណាំងាយស្រួលក្នុងការដាំសម្រាប់លក្ខខណ្ឌអាកាសធាតុសមប្រកប ដោយត្រូវការអាកាសធាតុក្តៅហើយសើម





*ទិដ្ឋភាពក្នុងពិធីបទបាឋកថា ស្តីពី «ដំណើរឆ្ពោះទៅការផលិតទំនិញនៅកម្ពុជា»*




*ឯកឧត្តមបណ្ឌិត ធន់ វឌ្ឍនា អញ្ជើញចុះទស្សនកិច្ចចម្ការកាកាវ នៅខេត្តរតនគិរី*

ហើយដំណាំនេះមិនប្រកាន់រដូវ ដូចដំណាំមួយចំនួនទៀតទេ ប៉ុន្តែមិនអាចដាំបានក្នុងតំបន់ទំនាបដក់ទឹកបានឡើយ ព្រោះវាត្រូវការទឹកច្រើនក្នុងការស្រោចស្រព ព្រមទាំងការមើលថែទាំឱ្យបានដិតដល់។

ក្នុងពេលចុះពិនិត្យនៅចម្ការកាហ្វេ PIDA ដែលមានដើមកាហ្វេ៣៨.០០០ដើម លើផ្ទៃដី២០ហិកតា **ឯកឧត្តមបណ្ឌិត** បានបង្ហាញនូវទស្សនវិស័យវែងឆ្ងាយលើការអភិវឌ្ឍវិស័យកសិ-ឧស្សាហកម្ម កាហ្វេ និងកាកាវ ដោយសង្កត់ធ្ងន់លើចំណុចសំខាន់ៗដូចជា សក្តានុពលទីផ្សារក្នុងស្រុក ការពង្រឹងធនធានមនុស្ស និងបច្ចេកទេសពូជ។

**ឯកឧត្តមបណ្ឌិត** បានកត់សម្គាល់ថា បច្ចុប្បន្នផលិតកម្មកាហ្វេក្នុងខេត្តមណ្ឌលគិរី អាចឆ្លើយតបបានត្រឹមតែប្រមាណ ១០%ប៉ុណ្ណោះ នៃតម្រូវការទីផ្សារសរុបក្នុងប្រទេស។ នេះគឺជាសញ្ញាវិជ្ជមានដែលបង្ហាញពីកាលានុវត្តភាពដ៏ធំធេងសម្រាប់កសិករ និងវិនិយោគិន ក្នុងការបង្កើនផ្ទៃដីដាំដុះកាហ្វេនិងកាកាវ ដើម្បីកាត់បន្ថយការនាំចូល។ ដើម្បីដោះស្រាយបញ្ហានេះ, **ឯកឧត្តមបណ្ឌិត** បានលើកទឹកចិត្តឱ្យមានកិច្ចសហការរវាងវិទ្យាស្ថានជាតិកសិកម្មព្រែកលៀបនិងចម្ការ PIDA ក្នុងការបណ្តុះបណ្តាលបច្ចេកទេស និងស្រាវជ្រាវពូជកាហ្វេគុណភាពខ្ពស់ ក្នុងគោលដៅប្រែក្លាយភូមិភាគឦសានជា «ប៉ូលសេដ្ឋកិច្ចទី៤» និងតំបន់កសិ-ទេសចរណ៍បៃតង។ ក្នុងន័យនេះ កាហ្វេ និងកាកាវ គួរត្រូវបានបញ្ចូលជាដំណាំយុទ្ធសាស្ត្របន្ថែមលើដំណាំដែលមានស្រាប់ដូចជា៖ ចេក ស្វាយចន្ទី កៅស៊ូ និងដំឡូងមី។

ជាងនេះទៅទៀត ឯកឧត្តមបណ្ឌិត **ធន់ វឌ្ឍនា** បានបញ្ជាក់ថា មានតែសាមគ្គីភាពជាតិ សុខសន្តិភាព ការទាក់ទាញទេសចរ និងការទាក់ទាញវិនិយោគិន គឺជាអាទិភាពដែលប្រជាពលរដ្ឋយើងត្រូវការ និងជាមូលដ្ឋានគ្រឹះនៃវឌ្ឍនភាពជាតិ។ ជាពិសេស **ឯកឧត្តមបណ្ឌិត**បានជំរុញឱ្យមានការគាំទ្រផលិតផលខ្មែរ និងផលិតកម្មក្នុងស្រុកឱ្យបានគ្រប់ៗគ្នា តាមរយៈការជួយទិញ ជួយផ្សព្វផ្សាយ និងជួយបង្កើតផលិតផលថ្មីៗ ដើម្បីធានាបាននូវការផ្គត់ផ្គង់គ្រប់គ្រាន់ និងនិរន្តរភាពនៅលើទីផ្សារ៕

អត្ថបទ៖ ខុទ្ទកាល័យឯកឧត្តមអនុប្រធានទី២ព្រឹទ្ធសភា

រូបភាព៖ នាយកដ្ឋានព័ត៌មាន





*ឯកឧត្តមបណ្ឌិត ធន់ វឌ្ឍនា អញ្ជើញចុះទស្សនកិច្ចចម្ការកាហ្វេ PIDA នៅមណ្ឌលគិរី*

# ឯកឧត្តមបណ្ឌិត ឆន់ វឌ្ឍនា មានប្រសាសន៍ថា
# អាទិភាពសម្រាប់សេដ្ឋកិច្ចកម្ពុជាបច្ចុប្បន្ន គឺវិស័យទេសចរណ៍និងកម្មន្តសាល

ក្នុងពិធីសំណេះសំណាលជាមួយសមាជិក៤១នាក់ នៃក្រុមប្រឹក្សាសង្កាត់ទាំង៥ ក្នុងខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ នារសៀលថ្ងៃទី៥ ខែមីនា ឆ្នាំ២០២៦ នៅវិមានព្រឹទ្ធសភា ឯកឧត្តមបណ្ឌិត **ឆន់ វឌ្ឍនា** អនុប្រធានទី២ព្រឹទ្ធសភា និងជាប្រធានក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១ (ភ្នំពេញ) បានសង្កត់ធ្ងន់ថា វិស័យទេសចរណ៍ និងកម្មន្តសាល (សិប្បកម្ម/ផលិតកម្ម) គឺជាក្បាលម៉ាស៊ីនរុញច្រានសេដ្ឋកិច្ចដ៏សំខាន់នាពេលបច្ចុប្បន្ន និងអនាគត ដែលអាជ្ញាធរមូលដ្ឋានត្រូវយកចិត្តទុកដាក់ខ្ពស់។

**ឯកឧត្តមបណ្ឌិត** បានលើកទឹកចិត្តដល់អាជ្ញាធរមូលដ្ឋាន បង្កលក្ខណៈងាយស្រួលដល់ការវិនិយោគថ្មីៗ និងអាជីវកម្មដែលមានស្រាប់។ វិស័យកម្មន្តសាល ពិសេសសហគ្រាសធុនតូចនិងមធ្យមគួរត្រូវបានពង្រឹងបន្ថែមនៅគ្រប់មូលដ្ឋាន។ សិប្បកម្មត្បាញហូល ផាមួង (នៅកោះដាច់) ដែលជាផ្នែកមួយនៃកម្មន្តសាលបែបប្រពៃណី ត្រូវផ្សារភ្ជាប់ជាមួយទេសចរណ៍ ដើម្បីបង្កើតការងារ និងចំណូលដល់ប្រជាពលរដ្ឋរស់នៅលើកោះ។

ជាមួយគ្នានោះ **ឯកឧត្តមបណ្ឌិត** បានផ្តល់អនុសាសន៍ឱ្យគ្រប់មូលដ្ឋានក្នុងរាជធានីភ្នំពេញ ជាពិសេសខណ្ឌជ្រោយចង្វារ ត្រូវបង្កើនភាពប្រកួតប្រជែង ដើម្បីទាក់ទាញទេសចរ តាមរយៈការរៀបចំសណ្តាប់ធ្នាប់សាធារណៈ ពង្រឹងសន្តិសុខ និងសោភ័ណភាពតាមដងផ្លូវ, គាំទ្រការលក់ម្ហូបអាហារឆ្ងាញ់ប្លែក អនាម័យ និងតម្លៃសមរម្យ ដោយរួមបញ្ចូលទាំងការរៀបចំទីកន្លែងសម្រាប់ទស្សនាថ្មីៗ ព្រមទាំងអភិវឌ្ឍន៍តំបន់ដែលមានស្រាប់ ដូចជា វិមានឈ្នះៈឈ្នះ និងកោះដាច់ ឱ្យកាន់តែទាក់ទាញ។



*ឯកឧត្តមបណ្ឌិត ធន់ វឌ្ឍនា អនុប្រធានទី២ព្រឹទ្ធសភា*

ជាទីបញ្ចប់ ឯកឧត្តមបណ្ឌិត **ឆន់ វឌ្ឍនា** បានកោតសរសើរថ្នាក់ដឹកនាំសង្កាត់ និងខណ្ឌជ្រោយចង្វារ ដែលខិតខំបំពេញការងារបានយ៉ាងល្អនាពេលកន្លងមក ព្រមទាំងលើកទឹកចិត្តឱ្យអាជ្ញាធរទាំងអស់បន្តរួមគ្នារិះរកដំណោះស្រាយសមស្រប ដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈម និងសំណូមពររបស់បងប្អូនដែលលើកឡើងនៅតាមមូលដ្ឋាន៕

អត្ថបទ៖ ខុទ្ទកាល័យឯកឧត្តមអនុប្រធានទី២ព្រឹទ្ធសភា

រូបភាព៖ នាយកដ្ឋានព័ត៌មាន





*ទិដ្ឋភាពសំណេះសំណាលជាមួយក្រុមប្រឹក្សាសង្កាត់ ក្នុងខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ*

# ឯកឧត្តមបណ្ឌិត ធន់ វឌ្ឍនា ជំរុញយុទ្ធសាស្ត្រ «ដំណោះស្រាយដោយខ្មែរ» ដើម្បីពង្រឹងភាពធន់សេដ្ឋកិច្ច និងអធិបតេយ្យភាពជាតិ



*ឯកឧត្តមបណ្ឌិត ធន់ វឌ្ឍនា អញ្ជើញជាអធិបតីក្នុងពិធីបិទសិក្ខាសាលា*

នាព្រឹកថ្ងៃទី១២ ខែមីនា ឆ្នាំ២០២៦ នៅវិមានរដ្ឋសភា ឯកឧត្តមបណ្ឌិត **ធន់ វឌ្ឍនា** អនុប្រធានទី២ នៃព្រឹទ្ធសភា បានអញ្ជើញជាអធិបតីក្នុងពិធីបិទសិក្ខាសាលាស្តីពី «ភាពធន់និងកាលានុវត្តភាព នៃយុទ្ធសាស្ត្រវិទ្យាសាស្ត្រ បច្ចេកវិទ្យា នវានុវត្តន៍ ឧស្សាហកម្ម និងពាណិជ្ជកម្មកម្ពុជា» ការរក្សាលំនឹងក្នុងកាលៈទេសៈនៃសង្គ្រាមឈ្លានពានលើអធិបតេយ្យនិងបូរណភាពទឹកដីរបស់កម្ពុជា។

**ឯកឧត្តមបណ្ឌិត**បានលើកឡើងនូវចំណុចគន្លឹះសំខាន់ៗ ដើម្បីតម្រង់ទិសសេដ្ឋកិច្ចកម្ពុជាឱ្យកាន់តែរឹងមាំក្នុងបរិបទនៃវិបត្តិសកលនិងតំបន់។ ឯកឧត្តមបានសង្កត់ធ្ងន់ថា មិត្តភាព និងសន្តិភាព គឺជាគ្រឹះមិនអាចខ្វះបានក្នុងការកសាងវិបុលភាពសេដ្ឋកិច្ច។ ចំពោះបញ្ហាជម្លោះព្រំដែនកម្ពុជា-ថៃ **ឯកឧត្តមបណ្ឌិត**បានគាំទ្រនិងយល់ស្របជាមួយរាជរដ្ឋាភិបាល ក្នុងការដោះស្រាយតាមរយៈការចរចា និងយន្តការច្បាប់ ជៀសវាងការប្រើកម្លាំងយោធាដែលបង្កផលប៉ះពាល់ដល់ប្រជាជន។

ជាមួយគ្នានោះ ឯកឧត្តម ក៏បានវាយតម្លៃខ្ពស់ចំពោះមិត្តភាពរវាង កម្ពុជា-វៀតណាម-ឡាវ និងបណ្តាប្រទេសអាស៊ាន ដែលជាអ្នកភូមិផងរបងជាមួយ។

**ឯកឧត្តមបណ្ឌិត**បានជំរុញយុទ្ធសាស្ត្រ «ដំណោះ-ស្រាយដោយខ្មែរ (Khmer Solutions)» ដើម្បីពង្រឹងភាពធន់ សេដ្ឋកិច្ច និងអធិបតេយ្យភាពជាតិ។ ចំណុចនេះដែរ ឯកឧត្តមលើកឡើងពីការជំរុញឱ្យមានខ្សែច្រវាក់ផលិតកម្មក្នុងស្រុក «ខ្មែរដាំ ខ្មែរកែច្នៃ ខ្មែរហូប ខ្មែរលក់»។ ការប្រើប្រាស់បច្ចេកវិទ្យាបញ្ញាសិប្បនិម្មិត (AI) និងរ៉ូបូទិក ដើម្បីបង្កើនប្រសិទ្ធភាពការងារ និងការធ្វើពាណិជ្ជកម្ម ក៏ជាចំណុចគួរយកចិត្តទុកដាក់ផងដែរ។



*ឯកឧត្តមបណ្ឌិត ធន់ វឌ្ឍនា អញ្ជើញមានប្រសាសន៍បិទអង្គសិក្ខាសាលា*

ក្នុងឱកាសនោះដែរ **ឯកឧត្តមបណ្ឌិត**បានបញ្ជាក់ថា សហគ្រាសធុនមីក្រូតូច និងមធ្យម (MSMEs) គឺជាឆ្អឹងខ្នងនៃសេដ្ឋកិច្ចជាតិ។ ក្នុងស្ថានភាពដែលមានបញ្ហាព្រំដែន



*ទិដ្ឋភាពក្នុងពិធីបិទសិក្ខាសាលា*

កម្ពុជាមិនអាចរង់ចាំតែការវិនិយោគផ្ទាល់ពីបរទេស (FDI) នោះទេ ប៉ុន្តែត្រូវចាត់ទុកវិបត្តិនេះជា «ឱកាសមាស» ក្នុងការលើកទឹកចិត្ត និងគាំទ្រផលិតផលដែលខ្មែរជាម្ចាស់ និងជំរុញស្លាកសញ្ញា «Made in Cambodia» លើឆាកអន្តរជាតិ។

**ឯកឧត្តមបណ្ឌិត**បានរំលឹកដល់សមាជិកសភាអំពីមុខងារតាមដានការអនុវត្តច្បាប់និងគោលនយោបាយ ក៏ដូចជាមុខងារតំណាង។ យោងតាមការលើកទឹកចិត្តរបស់សម្តេចតេជោ **ហ៊ុន សែន** ឯកឧត្តមបានស្នើឱ្យសមាជិកព្រឹទ្ធសភានិងរដ្ឋសភា យកចិត្តទុកដាក់តាមដានរាល់កិច្ចការទាំងពួងដែលជាប្រយោជន៍របស់ប្រជាជននៅមូលដ្ឋាន។

មុននឹងបញ្ចប់ **ឯកឧត្តមបណ្ឌិត**បានដាក់ចេញនូវការអំពាវនាវសំខាន់ៗចំនួន៥ រួមមាន៖ **១**-គាំទ្រ MSMEs ផ្នែកហិរញ្ញវត្ថុពន្ធ និងបច្ចេកវិទ្យាកែច្នៃ និងវេចខ្ចប់ **២**-បង្កើនផលិតភាពធនធានដីនិងកិច្ចសហការអាជីវកម្មជាមួយប្រទេសយុទ្ធសាស្ត្រ **៣**-បង្កើនមូលនិធិស្រាវជ្រាវសម្រាប់គ្រឹះស្ថានឧត្តមសិក្សា **៤**-គ្រឹះស្ថានឧត្តមសិក្សាត្រូវរួមកម្លាំងគ្នា ជាជាងបង្កើតស្ថាប័នថ្មីបន្ថែម និង**៥**-ជំរុញសមត្ថភាពភាសាអង់គ្លេសរបស់ប្រជាជនខ្មែរ អ្នកជនបទចេះភាសាអង់គ្លេសប្រហែលអ្នកទីក្រុង នៅឆ្នាំ២០៥០។

ជាទីបញ្ចប់ ឯកឧត្តមបណ្ឌិត **ឆន់ ខ្ញៀនា** បានរំលឹកថា ការគាំទ្រផលិតផលខ្មែរ មិនត្រឹមតែជាកិច្ចការសេដ្ឋកិច្ចប៉ុណ្ណោះទេ ប៉ុន្តែគឺជាការសហការគ្នា ដើម្បីពង្រឹងអធិបតេយ្យ-ភាព និងភាពម្ចាស់ការលើវាសនាជាតិខ្លួនឯង៕

អត្ថបទ៖ ខុទ្ទកាល័យឯកឧត្តមអនុប្រធានទី២ព្រឹទ្ធសភា

រូបភាព៖ នាយកដ្ឋានព័ត៌មាន



*ឯកឧត្តមបណ្ឌិត ឆន់ ខ្ញៀនា អញ្ជើញថតរូបអនុស្សាវរីយ៍*

# កម្ពុជាប្តេជ្ញាលុបបំបាត់បទល្មើសឆបោកអនឡាញ និងជំរុញសេដ្ឋកិច្ចស្អាត ប្រកបដោយបរិយាបន្ន

ក្នុងជំនួបពិភាក្សាការងារជាមួយលោកសាស្ត្រាចារ្យ Lee Hyun-Hoon មកពីសាកលវិទ្យាល័យជាតិ Kangwon នៃសាធារណរដ្ឋកូរ៉េ កាលពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៦ ឯកឧត្តមបណ្ឌិត **ឆន់ ខឡូនា** អនុប្រធានទី២ នៃព្រឹទ្ធសភា បានបញ្ជាក់យ៉ាងច្បាស់ពីគោលជំហររបស់កម្ពុជា ក្នុងការសហការប្រកបដោយតម្លាភាពជាមួយសហគមន៍អន្តរជាតិ ដើម្បីលុបបំបាត់ការឆបោក ពិសេសការឆបោកអនឡាញ (Online Scams) ឱ្យបានត្រឹមខែមេសា ឆ្នាំ២០២៦។ ការប្តេជ្ញាចិត្តនេះ មិនត្រឹមតែធ្វើឡើងដើម្បីការពារសន្តិសុខសណ្តាប់ធ្នាប់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងដើម្បីការពារកេរ្តិ៍ឈ្មោះប្រទេសជាតិ និងបង្កើនទំនុកចិត្តដល់ភ្ញៀវទេសចរអន្តរជាតិមកកាន់កម្ពុជាផងដែរ។



ឯកឧត្តមបណ្ឌិត ឆន់ ខ្លូនា អនុប្រធានទី២ព្រឹទ្ធសភា

ទន្ទឹមនឹងការដោះស្រាយបញ្ហាការឆបោកអនឡាញ **ឯកឧត្តមបណ្ឌិត**បានលើកឡើងពីយុទ្ធសាស្ត្រពង្រឹង «សេដ្ឋកិច្ចពិត» ដែលផ្តោតលើការផលិតទំនិញនិងសេវាកម្មសម្រាប់ទីផ្សារ។ បន្ថែមពីលើនេះ **ឯកឧត្តមបណ្ឌិត**ក៏បានលើកឡើងថា កម្ពុជាចាំបាច់ត្រូវមាន «សេដ្ឋកិច្ចស្អាត ប្រកបដោយបរិយាបន្ន» ដែលរាល់សកម្មភាពសេដ្ឋកិច្ចត្រូវគិតគូរដល់បរិស្ថាន និងប្រជាជនដែលមានចំណូលទាប ពិសេសជនងាយរងគ្រោះ។

ឆ្លើយតបនឹងសំណួររបស់**លោកសាស្ត្រាចារ្យ** អំពីការឡើងថ្លៃប្រេងលើពិភពលោក ដោយសារសង្គ្រាមអ៊ីរ៉ង់ **ឯកឧត្តមបណ្ឌិត**បានឆ្លើយតបថា កម្ពុជាពិតជារងផលប៉ះពាល់ដូចប្រទេសផ្សេងៗទៀតដែរ ប៉ុន្តែការជំរុញថាមពលកកើតឡើងវិញដូចជា វារីអគ្គិសនី និងថាមពលពន្លឺព្រះអាទិត្យ ព្រមទាំងកំពុងអភិវឌ្ឍថាមពលខ្យល់ បានជួយកម្ពុជាជៀសផុតពីផលប៉ះពាល់អវិជ្ជមានបានមួយកម្រិត។ **ឯកឧត្តមបណ្ឌិត**បានលើកឡើងថា ដោយសារសោហ៊ុយដឹកជញ្ជូនខ្ពស់ យុទ្ធសាស្ត្រកសិកម្មកម្ពុជា គឺងាកទៅរកដំណាំមានតម្លៃខ្ពស់ ដូចជា កាហ្វេនិងកាកាវ និងជំរុញការកែច្នៃក្នុងស្រុក។

**លោកសាស្ត្រាចារ្យ**បានលើកឡើងអំពីសៀវភៅ ដែលលោកគឺជាអ្នកនិពន្ធផ្ទាល់ ដែលក្នុងសៀវភៅនោះនិយាយអំពីទស្សនទាននៃការអភិវឌ្ឍ ដោយផ្តោតលើសេដ្ឋកិច្ចបៃតង និងបរិយាបន្ន៕

ខ្លឹមសារ៖ ខុទ្ទកាល័យឯកឧត្តមអនុប្រធានទី២ព្រឹទ្ធសភា

រូបភាព៖ នាយកដ្ឋានព័ត៌មាន



ឯកឧត្តមបណ្ឌិត ឆន់ ខ្លូនា ជួបពិភាក្សាការងារជាមួយលោកសាស្ត្រាចារ្យ Lee Hyun-Hoon

# សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភាចូលរួមពិធីផ្សេងៗ

❈នាថ្ងៃសុក្រ ទី២៧ ខែកុម្ភៈ ឆ្នាំ២០២៦ នៅអាកាសយានដ្ឋានអន្តរជាតិតេជោ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុនសែន** អញ្ជើញថ្វាយព្រះរាជដំណើរព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចព្រះមហាក្សត្រី **នរោត្តម មុនិនាថ សីហនុ** យាងទៅទីក្រុងប៉េកាំង ប្រទេសចិន ដើម្បីពិនិត្យព្រះរាជសុខភាព។





❈នាព្រឹកថ្ងៃទី២២ ខែមីនា ឆ្នាំ២០២៦ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រមុខរដ្ឋស្តីទី នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញសួរសុខទុក្ខនាយ**ទ្រិន** ដែលកំពុងសម្រាកព្យាបាលជំងឺនៅមន្ទីរពេទ្យកាល់ម៉ែត។

❈នារសៀលថ្ងៃទី២ ខែមីនា ឆ្នាំ២០២៦ ឯកឧត្តមបណ្ឌិត **ឆន់ វឌ្ឍនា** អនុប្រធានទី២ព្រឹទ្ធសភា បានអញ្ជើញដឹកនាំកិច្ចប្រជុំប្រចាំខែជាមួយប្រធានគណៈកម្មការទាំង១០ ប្រធានក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទាំង៨ ប្រធានក្រុមសមាជិកា និងប្រធានគណៈកម្មការក្រមសីលធម៌សភារបស់សមាជិកព្រឹទ្ធសភា នៅសាលប្រជុំពិសេស៣ព្រឹទ្ធសភា។





❈នារសៀលថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២៦ ឯកឧត្តមបណ្ឌិត **ឆន់ វឌ្ឍនា** អនុប្រធានទី២ព្រឹទ្ធសភា បានអញ្ជើញចូលរួមពិធីបុណ្យសព លោក **ទេព ថាវរិទ្ធ** អតីតមន្ត្រី នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលបានទទួលមរណភាព ក្នុងជន្មាយុ ៥៤ឆ្នាំ ដោយរោគាពាធ នៅគេហដ្ឋានស្ថិតក្នុងខណ្ឌបឹងកេងកង រាជធានីភ្នំពេញ។

❈នារសៀលថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២៦ ឯកឧត្តមបណ្ឌិត **ឆន់ វឌ្ឍនា** អនុប្រធានទី២ព្រឹទ្ធសភា បានអញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មការពិសេស ដើម្បីត្រៀមការពារសេចក្តីស្នើច្បាប់ស្តីពី វិសោធនកម្មច្បាប់បោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នៅវិមានសាមគ្គីភាពនៃព្រឹទ្ធសភា៕



# គណៈកម្មការទី១ព្រឹទ្ធសភាជួបពិភាក្សាការងារ ជាមួយថ្នាក់ដឹកនាំក្រសួងអធិការកិច្ច



*គណៈប្រតិភូគណៈកម្មការទី១ព្រឹទ្ធសភា អញ្ជើញជួបពិភាក្សាការងារជាមួយថ្នាក់ដឹកនាំក្រសួងអធិការកិច្ច*

នាព្រឹកថ្ងៃព្រហស្បតិ៍ ទី៥ ខែមីនា ឆ្នាំ២០២៦ គណៈកម្មការសិទ្ធិមនុស្ស ទទួលពាក្យបណ្តឹងនិងអង្កេត នៃព្រឹទ្ធសភា (គណៈកម្មការទី១) ដឹកនាំដោយឯកឧត្តម **ឌី ច័ន្ទផល** ប្រធានគណៈកម្មការ បានអញ្ជើញទទួលជួបពិភាក្សាការងារជាមួយថ្នាក់ដឹកនាំក្រសួងអធិការកិច្ច ដឹកនាំដោយឯកឧត្តម **សុខ សូកេន** រដ្ឋមន្ត្រីក្រសួងអធិការកិច្ច ដើម្បីឈ្វេងយល់អំពីវឌ្ឍនភាពការងាររបស់ក្រសួង និងកិច្ចសហការការងារ នៅសាលប្រជុំពិសេស៣ វិមានព្រឹទ្ធសភា។

ក្នុងឱកាសនោះ ឯកឧត្តម **ឌី ច័ន្ទផល** បាននាំយកនូវបណ្តាំផ្ញើសួរសុខទុក្ខ ប្រកបដោយសេចក្តីនឹករលឹកពីសំណាក់ថ្នាក់ដឹកនាំព្រឹទ្ធសភា ជូនដល់**ឯកឧត្តមរដ្ឋមន្ត្រី** ថ្នាក់ដឹកនាំក្រសួងអធិការកិច្ចនិងសហការី។ ឯកឧត្តមក៏បានជម្រាបជូនអំពីសាវតារ រចនាសម្ព័ន្ធ តួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ព្រឹទ្ធសភា ក៏ដូចជាគណៈកម្មការផងដែរ។ ជាមួយនេះ **ឯកឧត្តមប្រធាន**បានរំលេចអំពីការងារស្នូលរបស់គណៈកម្មការ គឺការងារសិទ្ធិមនុស្ស និងការងារទទួលពាក្យបណ្តឹង ដែលជាកិច្ចការមួយពាក់ព័ន្ធនឹងការងាររបស់ក្រសួង ដែលត្រូវមានកិច្ចសហការគ្នា ដើម្បីដោះស្រាយឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋ។ លើសពីនេះ ឯកឧត្តមក៏



*ទិដ្ឋភាពក្នុងជំនួបពិភាក្សាការងារ*

បានគូសបញ្ជាក់អំពីអាទិភាពការងារចម្បងចំនួន២ របស់ព្រឹទ្ធសភានីតិកាលទី៥ គឺការលើកកម្ពស់ការទូតសភានិងការរួមប្រាស្រ័យឱ្យកាន់តែជិតស្និទ្ធជាមួយអង្គបោះឆ្នោតពិសេសក្រុមប្រឹក្សាឃុំសង្កាត់ ដែលជាតំណាងប្រជាពលរដ្ឋនៅមូលដ្ឋាន។



ទិដ្ឋភាពក្នុងជំនួបពិភាក្សាការងារ

ក្នុងនាមថ្នាក់ដឹកនាំក្រសួងអធិការកិច្ច ដែលជាសេនាធិការរបស់រាជរដ្ឋាភិបាល **ឯកឧត្តមរដ្ឋមន្ត្រី**បានគោរពថ្លែងអំណរគុណចំពោះ**សម្តេចតេជោ** ប្រធានព្រឹទ្ធសភា ក៏ដូចជា**ឯកឧត្តមប្រធានគណៈកម្មការទី១ព្រឹទ្ធសភា** ដែលបានផ្តល់ឱកាស និងកិត្តិយសដល់ថ្នាក់ដឹកនាំក្រសួងបានមកជួបពិភាក្សាការងារនិងបង្ហាញពីវឌ្ឍនភាពនិងសមិទ្ធផលសំខាន់ៗរបស់ក្រសួងអធិការកិច្ចក្នុងនីតិកាលទី៧ នៃរដ្ឋសភាគិតត្រឹមឆ្នាំ២០២៥ ព្រមទាំងទិសដៅការងារ និងគំនិតផ្តួចផ្តើមជាយុទ្ធសាស្ត្រ។ ក្នុងជំនួបពិភាក្សានោះ **ឯកឧត្តមរដ្ឋមន្ត្រី** បានបង្ហាញពីក្របខ័ណ្ឌគោលនយោបាយ យុទ្ធសាស្ត្រ លិខិតបទដ្ឋានគតិយុត្ត និងគោលការណ៍ណែនាំ វឌ្ឍនភាព និងសមិទ្ធផលសំខាន់ៗ បញ្ហាប្រឈម ទិសដៅការងារ និងគំនិតផ្តួចផ្តើមជាយុទ្ធសាស្ត្រ។

ជាចុងបញ្ចប់ **ឯកឧត្តមប្រធានគណៈកម្មការ** បានវាយតម្លៃខ្ពស់ និងកោតសរសើរចំពោះការដឹកនាំរបស់ **ឯកឧត្តមរដ្ឋមន្ត្រី** ដែលបានខិតខំបំពេញការងារទោះបីមានបញ្ហាប្រឈមមួយចំនួន ក៏ក្រសួងអាចសម្រេចបានសមិទ្ធផលសំខាន់ៗ និងគំនិតផ្តួចផ្តើមជាយុទ្ធសាស្ត្រដែលអាចធានាបាននូវប្រសិទ្ធភាពក្នុងការដឹកនាំនិងគ្រប់គ្រងវិស័យអធិការកិច្ចនៃព្រះរាជាណាចក្រកម្ពុជា។

ឆ្លៀតក្នុងឱកាសនោះដែរ **ឯកឧត្តមប្រធានគណៈកម្មការ** ក៏បានជូនបាច់ផ្កាដល់លោកជំទាវ លោកស្រីនិងសហការីជានារី នៃក្រសួងអធិការកិច្ច ដើម្បីអបអរសាទរខួបលើកទី១១៥ ទិវាអន្តរជាតិនារី ៨មីនា។

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន



ឯកឧត្តម ង៉ី ច័ន្ទផល ប្រគល់វត្ថុអនុស្សាវរីយ៍ និងថតរូបអនុស្សាវរីយ៍ជាមួយថ្នាក់ដឹកនាំក្រសួងអធិការកិច្ច

# គណៈប្រតិភូគណៈកម្មការទី៣ព្រឹទ្ធសភា អញ្ជើញជួបពិភាក្សាការងារ ជាមួយរដ្ឋបាលខេត្តកំពត

នាព្រឹកថ្ងៃចន្ទ ទី៩ ខែមីនា ឆ្នាំ២០២៦ គណៈប្រតិភូគណៈកម្មការផែនការ វិនិយោគ កសិកម្ម រុក្ខាប្រមាញ់ នេសាទ អភិវឌ្ឍន៍ជនបទ បរិស្ថាន ធនធានទឹក និងឧតុនិយម (គណៈកម្មការទី៣) នៃព្រឹទ្ធសភា ដឹកនាំដោយឯកឧត្តមបណ្ឌិត **ម៉ុង ឫទ្ធី** ប្រធានគណៈកម្មការ បានអញ្ជើញជួបពិភាក្សាការងារជាមួយរដ្ឋបាលខេត្តកំពត ដឹកនាំដោយឯកឧត្តម **ម៉ៅ ធនិន** អភិបាលនៃគណៈអភិបាលខេត្តកំពត ដោយមានការអញ្ជើញចូលរួមពីប្រធានក្រុមប្រឹក្សាខេត្ត ថ្នាក់ដឹកនាំខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ មន្ទីរពាក់ព័ន្ធ និងមន្ត្រីជំនាញ នៅសាលាខេត្តកំពត។



*គណៈប្រតិភូគណៈកម្មការទី៣ព្រឹទ្ធសភា អញ្ជើញជួបពិភាក្សាការងារជាមួយរដ្ឋបាលខេត្តកំពត*

ក្នុងឱកាសនោះ ឯកឧត្តមបណ្ឌិត **ម៉ុង ឫទ្ធី** បានជម្រាបអំពីមុខងារសំខាន់ៗរបស់ព្រឹទ្ធសភា រួមមាន៖ មុខងារនីតិកម្ម, មុខងារតាមដានការអនុវត្តច្បាប់, មុខងារតំណាង, មុខងារសហប្រតិបត្តិការអន្តរជាតិ និងមុខងារអភិវឌ្ឍន៍ស្ថាប័ន ដែលមានគណៈកម្មការទាំង១០របស់ព្រឹទ្ធសភា ជាយន្តការស្នូលជួយទ្រទ្រង់ដល់ដំណើរការអនុវត្តមុខងារនីតិកម្ម មុខងារតាមដានការអនុវត្តច្បាប់ និងមុខងារផ្តល់ព័ត៌មាន។

**ឯកឧត្តមបណ្ឌិត**បានបញ្ជាក់ថា គោលបំណងនៃដំណើរបេសកកម្មរបស់គណៈប្រតិភូគណៈកម្មការទី៣ ដើម្បីសិក្សាស្វែងយល់និងប្រមូលព័ត៌មានពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការនៅក្នុងខេត្តកំពត មានដូចជា **១**-ការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលនិងវឌ្ឍនភាពការងាររបស់ខេត្ត។ **២**-ការងារ និងលទ្ធផលតាមវិស័យដែលពាក់ព័ន្ធទៅនឹងសមត្ថកិច្ចរបស់គណៈកម្មការ ដូចជា៖ ផែនការ វិនិយោគ កសិកម្ម ធនធានទឹក អភិវឌ្ឍន៍ជនបទ និងបរិស្ថាន។ **៣**-បញ្ហាប្រឈមនិងសំណូមពររបស់ឃុំ សង្កាត់ ទាក់ទងនឹងវិស័យកសិកម្ម ធនធានទឹក អភិវឌ្ឍន៍ជនបទ បរិស្ថាន និងភូមិ ឃុំ សង្កាត់មានសុវត្ថិភាព។ **៤**-ការផ្សព្វផ្សាយច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ដែលពាក់-ព័ន្ធទៅនឹងការពង្រឹងវិស័យនីតិរដ្ឋនៅកម្ពុជា។ **៥**-ស្វែងយល់អំពីប្រតិបត្តិការវិស័យឯកជន និងបញ្ហាប្រឈមនានា។

ឯកឧត្តម **ម៉ៅ ធនិន** អភិបាលនៃគណៈអភិបាលខេត្តកំពត បានស្វាគមន៍ និងជម្រាបជូនអំពីវឌ្ឍនភាពនៃ



*ទិដ្ឋភាពក្នុងជំនួបពិភាក្សាការងារ*

ខេត្តកំពត ដែលកំពុងមានការរីកចម្រើនគួរឱ្យកត់សម្គាល់ ដោយបានប្រែក្លាយខ្លួនជាប៉ូលទេសចរណ៍ដ៏សំខាន់តាមរយៈការអភិវឌ្ឍរមណីយដ្ឋាននិងឆ្នេរកម្សាន្តថ្មីៗ ព្រមទាំងពង្រឹងហេដ្ឋារចនាសម្ព័ន្ធយុទ្ធសាស្ត្រដូចជា កំពង់ផែពហុបំណង និងកំពង់ផែទេសចរណ៍អន្តរជាតិ ដែលជំរុញវិស័យដឹកជញ្ជូន និងទាក់ទាញភ្ញៀវទេសចរ។ ទន្ទឹមនឹងនេះ ខេត្តកំពតនៅតែរក្សាបាននូវតួនាទីជាមជ្ឈមណ្ឌលផលិតស៊ីម៉ងត៍ដ៏ធំបំផុតរបស់ប្រទេសនិងជាមោទនភាពនៃកសិផល GI ល្បីឈ្មោះដូចជា ម្រេច និងទុរេន ដែលរួមចំណែកបង្កើនចំណូលសេដ្ឋកិច្ចគ្រួសារ។ ជារួម ខេត្តកំពតកំពុងវិវត្តប្រកបដោយតុល្យភាព ពីខេត្តកសិកម្មទៅជាខេត្តដែលរួមបញ្ចូលគ្នារវាងឧស្សាហកម្មធុនធ្ងន់ និងសេវាកម្មទេសចរណ៍កម្រិតខ្ពស់។



*ទិដ្ឋភាពក្នុងជំនួបពិភាក្សាការងារ*



*ឯកឧត្តមបណ្ឌិត ម៉ុង ឫទ្ធី ប្រគល់វត្ថុអនុស្សាវរីយ៍ជូនរដ្ឋបាលខេត្តកំពត*

ជាចុងបញ្ចប់ ឯកឧត្តមបណ្ឌិត **ម៉ុង ឫទ្ធី** បានកោតសរសើរចំពោះការដឹកនាំរបស់**ឯកឧត្តមអភិបាលខេត្ត** ព្រមទាំងផ្តល់អនុសាសន៍មួយចំនួន ដើម្បីចូលរួមចំណែកក្នុងការអភិវឌ្ឍខេត្តឱ្យកាន់តែប្រសើរឡើងថែមទៀត ជាពិសេសការបន្តដោះស្រាយទំនាស់ក្រៅប្រព័ន្ធតុលាការតែម្តង។ ជាមួយគ្នានេះ **ឯកឧត្តមបណ្ឌិត**ក៏បានជូនសាច់ក្រកចម្រុះចំនួន១០កេស ស្មើនឹង១០០គីឡូក្រាម សៀវភៅស្តីពីវិថីក្រាលមាសចំនួន៥ក្បាល និងវត្ថុអនុស្សាវរីយ៍ចំនួន១ផងដែរ៕

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន

# សន្តិភាពមិនមែនជាការចៃដន្យនោះទេ ប៉ុន្តែគឺជាផលនៃឆន្ទៈរួម និងការលះបង់ដ៏ខ្ពង់ខ្ពស់របស់យើងទាំងអស់គ្នា




*ឯកឧត្តមបណ្ឌិត នាង ផាត អញ្ជើញជាអធិបតីក្នុងពិធីសំណេះសំណាលជាមួយ ថ្នាក់ដឹកនាំខេត្ត ក្រុង ស្រុក ក្រុមប្រឹក្សាឃុំ សង្កាត់ នៅខេត្តក្រចេះ*

សន្តិភាពមិនមែនជាការចៃដន្យនោះទេ ប៉ុន្តែគឺជាផលនៃឆន្ទៈរួម និងការលះបង់ដ៏ខ្ពង់ខ្ពស់របស់យើងទាំងអស់គ្នា។ នេះជាការលើកឡើងរបស់ ឯកឧត្តមបណ្ឌិត **នាង ផាត** ប្រធានគណៈកម្មការទី៤ព្រឹទ្ធសភានិងជាប្រធានក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨ (ខេត្តកំពង់ធំ ខេត្តព្រះវិហារ ខេត្តក្រចេះ ខេត្តស្ទឹងត្រែង ខេត្តរតនគិរី និងខេត្តមណ្ឌលគិរី) ក្នុងឱកាសដែលឯកឧត្តមដឹកនាំគណៈកម្មការទី៤ព្រឹទ្ធសភា និងក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨ អញ្ជើញជួបសំណេះសំណាលជាមួយថ្នាក់ដឹកនាំ ខេត្ត ក្រុង ស្រុក ក្រុមប្រឹក្សាឃុំ សង្កាត់ នៃខេត្តក្រចេះ សរុបចំនួន៣៧៥នាក់ នៅសាលមហោស្រពខេត្តក្រចេះ នាព្រឹកថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៦។



*ឯកឧត្តមបណ្ឌិត នាង ផាត អញ្ជើញមានប្រសាសន៍ក្នុងអង្គពិធី*

ក្នុងឱកាសនោះ **ឯកឧត្តមបណ្ឌិត**បាននាំនូវប្រសាសន៍ផ្តាំផ្ញើសួរសុខទុក្ខពីសំណាក់សម្តេចតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា ជូនដល់ថ្នាក់ដឹកនាំនិងប្រជាពលរដ្ឋក្នុងខេត្តក្រចេះ ព្រមទាំងសម្តែងនូវការគោរពចំពោះវិញ្ញាណក្ខន្ធវីរយុទ្ធជនដែលបានពលីក្នុងបុព្វហេតុការពារជាតិ មាតុភូមិ និងសូមចូលរួមចំណែកលើកទឹកចិត្តដល់កងទ័ពកម្ពុជាទាំងអស់ រួមទាំងប្រជាពលរដ្ឋរស់នៅតាមតំបន់ជម្លោះ ដែលកំពុងជួបប្រទះនូវការលំបាកដោយសារការឈ្លានពានពីប្រទេសថៃ។

**ឯកឧត្តមបណ្ឌិត**បានជម្រាបអំពីតួនាទីរបស់ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨និងគណៈកម្មការទី៤ព្រឹទ្ធសភា ដែលជាយន្តការមួយរបស់ព្រឹទ្ធសភាក្នុងការការពារសិទ្ធិ ផលប្រយោជន៍ក្រុមប្រឹក្សាឃុំ សង្កាត់ និងប្រជាពលរដ្ឋក្នុងភូមិភាគរបស់ខ្លួន។ ផ្តើមចេញពីតួនាទីដ៏មានសារៈសំខាន់នេះ ក្រុមសមាជិកព្រឹទ្ធសភាតែងតែចុះជួបផ្ទាល់ជាមួយថ្នាក់ដឹកនាំខេត្ត ក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីឈ្វេងយល់ពីបញ្ហាប្រឈម ការអភិវឌ្ឍមូលដ្ឋាន ដំណោះស្រាយ សំណូមពរ និងកៀរគរប្រជាពលរដ្ឋ ឱ្យចូលរួមក្នុងការអភិវឌ្ឍមូលដ្ឋាន ស្របតាមអាទិភាពចម្បងរបស់ព្រឹទ្ធសភានីតិកាលទី៥ ដែលផ្តោតលើការធ្វើការយ៉ាងជិតស្និទ្ធជាមួយអង្គបោះឆ្នោត ជាពិសេសជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ ដែលជាតំណាងឱ្យប្រជាពលរដ្ឋនៅមូលដ្ឋាន។



*ឯកឧត្តម ប៉ុល លឹម អនុប្រធានគណៈកម្មការទី៤ព្រឹទ្ធសភា អញ្ជើញមានមតិយោបល់ក្នុងអង្គពិធី*



*លោកជំទាវ យួន យុនឌី អនុប្រធានក្រុមភូមិភាគទី៨ អញ្ជើញមានមតិយោបល់ក្នុងអង្គពិធី*

ឆ្លងតាមការធ្វើបទបង្ហាញស្តីពី តួនាទី ភារកិច្ចនិងសមត្ថកិច្ចរបស់ព្រឹទ្ធសភា, ការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ, ការចូលរួមមតិយោបល់របស់ក្រុមប្រឹក្សាឃុំ សង្កាត់ ការស្រាយបំភ្លឺពីឯកឧត្តមអភិបាលខេត្ត និងការចែករំលែកបទពិសោធល្អៗពីសំណាក់ ឯកឧត្តមលោកជំទាវក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨ និងគណៈប្រតិភូគណៈកម្មការទី៤ព្រឹទ្ធសភា រួចមក ឯកឧត្តមបណ្ឌិត **នាង ផាត** បានវាយតម្លៃខ្ពស់ចំពោះការខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ ដែលសម្រេចបាននូវសមិទ្ធផលជាច្រើន ក្នុងការបម្រើប្រជាពលរដ្ឋក្នុងមូលដ្ឋានកន្លងទៅ។ ឯកឧត្តមបានគូសបញ្ជាក់ថា ព្រឹទ្ធសភាតែងតែផ្តល់តម្លៃខ្ពស់រាល់មតិយោបល់ និងធាតុចូលរបស់បងប្អូន និងត្រៀមខ្លួនជាស្រេចក្នុងការគាំទ្ររាល់កិច្ចប្រឹងប្រែងទាំងឡាយណា ដែលបង្កើនគុណភាពនិងប្រសិទ្ធភាពនៃសេវាសាធារណៈថ្នាក់ក្រោមជាតិ។ រាល់មតិយោបល់និងធាតុចូលដែលទទួលបាននាថ្ងៃនេះ នឹងត្រូវចងក្រងយ៉ាងហ្មត់ចត់ ដើម្បីរាយការណ៍ជូនថ្នាក់ដឹកនាំព្រឹទ្ធសភា និងស្ថាប័នពាក់ព័ន្ធដោះស្រាយតាមសមត្ថកិច្ចរៀងៗខ្លួន។

ក្នុងឱកាសនោះផងដែរ **ឯកឧត្តមបណ្ឌិត**បានជម្រាបជូនអំពីសភាពការណ៍អន្តរជាតិ និងរំឭកអំពីសមិទ្ធផលជាប្រវត្តិសាស្ត្ររបស់កម្ពុជា ដែលបានទាមទារមកវិញនូវទឹកដីដែលប្រទេសថៃបានទន្ទ្រានយក។ ទន្ទឹមនឹងនេះ ឯកឧត្តមបានថ្លែងអំណរគុណចំពោះវីរភាពដឹកនាំប្រកបដោយមនសិការស្នេហាជាតិនិងវាងវៃបំផុតរបស់សម្តេចតេជោ **ហ៊ុន សែន** និងសម្តេចធិបតី **ហ៊ុន ម៉ាណែត** រួមទាំងថ្នាក់ដឹកនាំរាជរដ្ឋាភិបាលគ្រប់ជាន់ថ្នាក់ ដែលមានភាពប៉ិនប្រសប់ក្នុងការដឹកនាំ និងគ្រប់គ្រងស្ថានការណ៍របស់ប្រទេសជាតិ ជុំវិញជម្លោះព្រំដែនកម្ពុជា-ថៃ ដោយឈរលើគោលការណ៍សន្តិភាពនិយម ការពារផលប្រយោជន៍របស់ជាតិ។



*ទិដ្ឋភាពក្នុងពិធីសំណេះសំណាល*

**ឯកឧត្តមបណ្ឌិត**បានអំពាវនាវដល់អាជ្ញាធរគ្រប់ជាន់ថ្នាក់ និងបងប្អូនប្រជាពលរដ្ឋ បន្តរក្សា និងជំរុញស្មារតីសាមគ្គីភាព ឯកភាពជាតិជាធ្លុងមួយ ក្នុងការការពារសន្តិភាព ដែលបានមកដោយលំបាក តាមរយៈពលិកម្មរបស់សម្តេចតេជោ **ហ៊ុន សែន** ដែលជាកត្តាមិនអាចខ្វះបានក្នុងកិច្ចការពារឯករាជ្យភាព អធិបតេយ្យជាតិ បូរណភាពទឹកដី វិបុលភាព និងការអភិវឌ្ឍជាតិមាតុភូមិកម្ពុជា ឱ្យមានការរីកចម្រើនលើគ្រប់វិស័យ៕

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន

# ឯកឧត្តមបណ្ឌិត ឈីវ យីស៊ាង វាយតម្លៃខ្ពស់ចំពោះសមិទ្ធផលនិងទិសដៅការងាររបស់ក្រសួងព័ត៌មាន ដែលជាបច្ច័យយ៉ាងសំខាន់ក្នុងការបន្តការពារផលប្រយោជន៍ជាតិនិងប្រជាជន



*ឯកឧត្តមបណ្ឌិត ឈីវ យីស៊ាង ប្រធានគណៈកម្មការទី៥ព្រឹទ្ធសភា*



*ឯកឧត្តម នេត្រ ភក្ត្រា រដ្ឋមន្ត្រីក្រសួងព័ត៌មាន*

នៅព្រឹកថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២៦ ឯកឧត្តមបណ្ឌិត **ឈីវ យីស៊ាង** ប្រធានគណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ និងព័ត៌មាន នៃព្រឹទ្ធសភា (គណៈកម្មការទី៥) បានជួបប្រជុំពិភាក្សាការងារជាមួយ ឯកឧត្តម **នេត្រ ភក្ត្រា** រដ្ឋមន្ត្រីក្រសួងព័ត៌មាន និងថ្នាក់ដឹកនាំក្រសួងព័ត៌មាន នៅវិមានព្រឹទ្ធសភា រាជធានីភ្នំពេញ។

បន្ទាប់ពីបានសម្តែងស្វាគមន៍យ៉ាងកក់ក្តៅចំពោះ **ឯកឧត្តមរដ្ឋមន្ត្រី** និងថ្នាក់ដឹកនាំក្រសួងព័ត៌មាន **ឯកឧត្តមបណ្ឌិតប្រធានគណៈកម្មការទី៥** បានគូសបញ្ជាក់ថា ជំនួបពិភាក្សាការងារនេះ មានគោលបំណងឈ្វេងយល់អំពីវឌ្ឍនភាពការងារនិងសមិទ្ធផលនានា ដែលក្រសួងព័ត៌មានសម្រេចបានក្នុងឆ្នាំ២០២៥ និងទិសដៅនៃការអនុវត្តការងារឆ្នាំ២០២៦ ព្រមទាំងការអនុវត្តមុខងារសំខាន់បីនៃព្រឹទ្ធសភា (មុខងារនីតិកម្ម មុខងារតាមដានការអនុវត្តច្បាប់ និងមុខងារតំណាង) និងការអនុវត្តតួនាទី ភារកិច្ចរបស់គណៈកម្មការទី៥។

**ឯកឧត្តមរដ្ឋមន្ត្រី**ក្រសួងព័ត៌មាន បានបង្ហាញជូនអង្គប្រជុំនូវសមិទ្ធផលសំខាន់ជាច្រើនដែលក្រសួងព័ត៌មានសម្រេចបាននៅឆ្នាំ២០២៥ តាមរយៈការងារអាទិភាពចម្បងៗរួមមាន៖ (១)ការធ្វើទំនើបកម្មស្ថាប័ននិងធនធានមនុស្ស និងការពង្រឹងអភិបាលកិច្ច ជាពិសេសការកែទម្រង់ពង្រឹង



*ទិដ្ឋភាពក្នុងជំនួបពិភាក្សាការងារ*

សមត្ថភាព ប្រសិទ្ធភាព និងគុណភាពការងារ (២)ការធ្វើបច្ចុប្បន្នភាពច្បាប់និងបទដ្ឋានបច្ចេកទេស, ការគ្រប់គ្រងសណ្តាប់ធ្នាប់សារព័ត៌មាន និងសាធារណៈមតិ, ការប្រយុទ្ធប្រឆាំងព័ត៌មានក្លែងក្លាយ និងការអនុវត្តការទូតព័ត៌មានដោយផ្អែកលើអភិក្រម «ថ្មី ពិត លឿន និងទូលំទូលាយ ប្រកបដោយជំនឿទុកចិត្តនិងវិជ្ជាជីវៈ ដើម្បីផ្សារភ្ជាប់គ្រប់មជ្ឈដ្ឋាន»។ **ឯកឧត្តមរដ្ឋមន្ត្រី**ក្រសួងព័ត៌មានក៏បានបង្ហាញអំពីទិន្នន័យបច្ចុប្បន្នភាពនៃប្រព័ន្ធផ្សព្វផ្សាយរបស់កម្ពុជាក្នុងឆ្នាំ២០២៥ ដែលមានចំនួនសរុប១.៥៥២អង្គភាព ក្នុងនោះមានប្រព័ន្ធផ្សព្វផ្សាយបែបបុរាណ (វិទ្យុ ទូរទស្សន៍ និងពុម្ពកាសែតនិងទស្សនាវដ្តី) ចំនួន៦៧៤ និងប្រព័ន្ធផ្សព្វផ្សាយបែបថ្មី (គេហទំព័រ ទូរទស្សន៍ឌីជីថល និងតាមអនឡាញ) ចំនួន៨៧៨។ យោងតាមទិន្នន័យប្រៀបធៀបនឹងឆ្នាំ២០២៤ ចំនួនប្រព័ន្ធផ្សព្វផ្សាយបែបថ្មីមានការកើនឡើង ប៉ុន្តែបែបបុរាណមានការធ្លាក់ចុះចំនួន៦៨អង្គភាព។

ទន្ទឹមនឹងនេះដែរ ក្រសួងព័ត៌មានបានអនុវត្តការងារអាទិភាពបី រួមមាន៖ **១**-សិទ្ធិទទួលបានព័ត៌មានរបស់ប្រជាពលរដ្ឋ **២**-គុណភាពព័ត៌មាននិងសុវត្ថិភាពព័ត៌មានក្នុងបរិបទនៃការរីកចម្រើនប្រព័ន្ធផ្សព្វផ្សាយបែបថ្មីតាមបណ្តាញទំនាក់ទំនងសង្គម ប្រព័ន្ធឌីជីថល **៣**-ការកើនឡើងនៃព័ត៌មានក្លែងក្លាយច្រើន...។ល។ **ឯកឧត្តមរដ្ឋមន្ត្រី**ក្រសួងព័ត៌មានក៏បានផ្តោតសំខាន់លើការដឹកនាំ គ្រប់គ្រងទំនាក់ទំនងសាធារណៈជាមួយក្រសួងស្ថាប័នពាក់ព័ន្ធទាំងអស់ វឌ្ឍនភាពនៃការកសាងភាពធន់នៃវិស័យព័ត៌មាន និងប្រឈមមុខនឹងវិបត្តិនានាដែលកំពុងកើតមានឡើង។

សម្រាប់ទិសដៅការងារឆ្នាំ២០២៦ ក្រសួងព័ត៌មាននឹងបន្តជំរុញការអភិវឌ្ឍស្ថាប័ន លើកកម្ពស់សណ្តាប់ធ្នាប់សារព័ត៌មានឱ្យបានកាន់តែប្រសើរ បន្តលើកកម្ពស់គុណភាព និងប្រសិទ្ធភាពព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយ វិជ្ជាជីវៈនៃអ្នកសារព័ត៌មាន ការពង្រឹងការអនុវត្តច្បាប់នានាស្តីពី វិស័យព័ត៌មាននិងធម្មនុញ្ញវិជ្ជាជីវៈសារព័ត៌មាន, ការវាយតម្លៃស្ថានភាពសេរីភាពសារព័ត៌មានកម្ពុជា, ការអភិវឌ្ឍមូលធនមនុស្ស ជាពិសេសភាពចាំបាច់នៃការបណ្តុះបណ្តាលមន្ត្រីបច្ចេកទេសក្នុងវិជ្ជាជីវៈសារព័ត៌មានសម្រាប់រយៈពេល១០ឆ្នាំខាងមុខ។

នាឱកាសជំនួបពិភាក្សានោះ ឯកឧត្តម លោកជំទាវ ប្រធាន អនុប្រធាន និងលេខាធិការ នៃគណៈកម្មការទាំង១០ព្រឹទ្ធសភា ក៏បានផ្លាស់ប្តូរយោបល់យ៉ាងផុលផុសជាមួយ **ឯកឧត្តមរដ្ឋមន្ត្រី**ក្រសួងព័ត៌មាន លើទិដ្ឋភាពនៃសារៈសំខាន់ក្នុងការពង្រឹងសមត្ថភាពមូលធនមនុស្សលើវិស័យព័ត៌មាន, ការជំរុញផ្សព្វផ្សាយអប់រំវប្បធម៌ និងអក្ខរកម្មឌីជីថលក្នុងបរិបទនៃបញ្ញាសិប្បនិម្មិត, ការអនុម័តសេចក្តីព្រាងច្បាប់ព្រមទាំងសេវាព័ត៌មានលើកទឹកចិត្ត។ កិច្ចពិភាក្សា ក៏បានផ្តោតសំខាន់លើយុទ្ធសាស្ត្រនៃគមនាគមន៍ ក្នុងគ្រាមានវិបត្តិ សុខភាព សន្តិសុខ និងបរិស្ថាន ជាពិសេសសង្គ្រាមឈ្លានពានពីសំណាក់ប្រទេសជិតខាងនិងសារៈសំខាន់នៃតួនាទី និងការគាំទ្ររបស់សភាដល់ក្រសួង និងវិស័យព័ត៌មានផងដែរ។

នៅចុងបញ្ចប់ **ឯកឧត្តមប្រធានគណៈកម្មការទី៥** បានវាយតម្លៃខ្ពស់ចំពោះបទអន្តរាគមន៍ ការឆ្លើយបំភ្លឺ និងការផ្លាស់ប្តូរទស្សនៈលើវិស័យព័ត៌មានជាយុទ្ធសាស្ត្ររបស់ **ឯកឧត្តមរដ្ឋមន្ត្រី** ជាមួយនឹងសមិទ្ធផលជាផ្លែផ្កាដែលសម្រេចបានក្នុងឆ្នាំ២០២៥និងការដាក់ចេញនូវទិសដៅការងារឆ្នាំ២០២៦ ដែលជាកិច្ចខិតខំប្រឹងប្រែងប្រកបដោយស្មារតីទទួលខុសត្រូវនិងបុរេសកម្ម និងជាបច្ច័យយ៉ាងសំខាន់ក្នុងការបន្តការពារផលប្រយោជន៍ជាតិនិងប្រជាជន៕

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន



*ឯកឧត្តមបណ្ឌិត ឈឹម យីស៊ាង អញ្ជើញថតរូបអនុស្សាវរីយ៍ជាមួយ ថ្នាក់ដឹកនាំក្រសួងព័ត៌មាន*

# គណៈកម្មការទី៦ព្រឹទ្ធសភា ចុះឈ្វេងយល់ការងារពាក់ព័ន្ធនឹងវិស័យ ជាសមត្ថកិច្ចរបស់ខ្លួន នៅខេត្តកំពង់ស្ពឺ និងខេត្តកោះកុង

គណៈប្រតិភូគណៈកម្មការនីតិកម្ម និងយុត្តិធម៌ នៃព្រឹទ្ធសភា (គណៈកម្មការទី៦) ដឹកនាំដោយ លោកជំទាវបណ្ឌិត **ចាន់ សុខុន្ធារី** ប្រធានគណៈកម្មការ បានអញ្ជើញចុះឈ្វេងយល់ការងារពាក់ព័ន្ធនឹងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការ នៅខេត្តកំពង់ស្ពឺ និងខេត្តកោះកុង ពីថ្ងៃទី១ ដល់ថ្ងៃទី៥ ខែមីនា ឆ្នាំ២០២៦។

ក្នុងដំណើរបំពេញបេសកកម្មនៅលើទឹកដីខេត្តទាំងពីរ គណៈប្រតិភូគណៈកម្មការទី៦ព្រឹទ្ធសភាបានអញ្ជើញជួបពិភាក្សាការងារជាមួយនឹងសាលាដំបូងនិងអយ្យការអមសាលាដំបូងខេត្ត ដើម្បីឈ្វេងយល់ និងប្រមូលព័ត៌មានពាក់ព័ន្ធទៅនឹងការអនុវត្តច្បាប់ និងការផ្តល់សេវាយុត្តិធម៌ជូនប្រជាពលរដ្ឋ និងបញ្ហាប្រឈមនានា ដែលសាលាដំបូងនិងអយ្យការអមសាលាដំបូងជួបប្រទះ។

ដោយឡែកនៅខេត្តកោះកុង បានរៀបចំសិក្ខាសាលាស្តីពី «អត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម» ជាមួយសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ ស្មៀន នាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ-សង្កាត់ និងមន្ត្រីដែលមានសមត្ថកិច្ចពាក់ព័ន្ធ មកពីស្រុកមណ្ឌលសីមា, ក្រុងខេមរភូមិន្ទ និងស្រុកកោះកុង ដោយមានការចូលរួមប្រមាណ១៥០រូប។ បន្ទាប់មក គណៈប្រតិភូបន្តជួបពិភាក្សាការងារជាមួយរដ្ឋបាលខេត្តកោះកុង ដើម្បីឈ្វេងយល់ អំពីស្ថានភាពនៃការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា ដែលអាជ្ញាធរខេត្ត និងមន្ទីរអង្គភាពជំនាញពាក់ព័ន្ធមានកាតព្វកិច្ចអនុវត្តស្របតាមសមត្ថកិច្ច ដែលបានកំណត់ដោយច្បាប់ទាក់ទងនឹងការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ។

នៅគ្រប់ពិធី **លោកជំទាវបណ្ឌិត** បាននាំនូវប្រសាសន៍ផ្តាំផ្ញើសួរសុខទុក្ខ ប្រកបដោយសេចក្តីនឹករឭកពីសំណាក់ថ្នាក់ដឹកនាំព្រឹទ្ធសភា ជូនអាជ្ញាធរគ្រប់ជាន់ថ្នាក់ និងប្រជាពលរដ្ឋ ព្រមទាំងបានជម្រាបអំពីគោលបំណងនៃដំណើរបំពេញបេសកកម្មរបស់គណៈកម្មការ និងតួនាទីភារកិច្ចរបស់គណៈកម្មការ និងព្រឹទ្ធសភា ដើម្បីឈ្វេងយល់ និងប្រមូលព័ត៌មានពាក់ព័ន្ធទៅនឹងការអនុវត្តច្បាប់ និងការផ្តល់សេវាយុត្តិធម៌ជូនប្រជាពលរដ្ឋ ដែលស្ថិតនៅក្នុងដែនសមត្ថកិច្ច នៃតុលាការខេត្តទាំងពីរ ព្រមទាំងពង្រឹងតួនាទីភារកិច្ចនិងសមត្ថកិច្ចរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ និងអាជ្ញាធរមានសមត្ថកិច្ច ស្របតាមបទប្បញ្ញត្តិច្បាប់ពាក់ព័ន្ធនឹងការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ។





*គណៈប្រតិភូគណៈកម្មការទី៦ព្រឹទ្ធសភា អញ្ជើញជួបពិភាក្សាការងារ ជាមួយសាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តកំពង់ស្ពឺ*



*គណៈប្រតិភូគណៈកម្មការទី៦ព្រឹទ្ធសភា អញ្ជើញជួបពិភាក្សាការងារជាមួយ ក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀន នាយប៉ុស្តិ៍នគរបាលរដ្ឋបាល នៅខេត្តកោះកុង*

**លោកជំទាវបណ្ឌិត**បានមានប្រសាសន៍បកស្រាយយ៉ាងក្បោះក្បាយ និងច្បាស់លាស់ ដោយផ្តោតលើចំណុច





*គណៈប្រតិភូគណៈកម្មការទី៦ព្រឹទ្ធសភា អញ្ជើញជួបពិភាក្សាការងារជាមួយរដ្ឋបាលខេត្តកោះកុង*

សំខាន់ៗ អំពីខ្លឹមសារនិងនីតិវិធីច្បាប់ ដើម្បីជាប្រយោជន៍ក្នុងការធានាការអនុវត្តប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព ទាក់ទងនឹងការផ្តល់សេវាចុះបញ្ជីអត្រានុកូលដ្ឋាន រួមមាន៖ ការចុះបញ្ជីកំណើត ការចុះបញ្ជីមរណភាព និងការចុះបញ្ជីអាពាហ៍ពិពាហ៍ ដែលជាសេវាសាធារណៈមូលដ្ឋានដ៏មានសារៈសំខាន់ ផ្សារភ្ជាប់ផ្ទាល់ចំពោះស្ថានភាពផ្លូវច្បាប់ និងការរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ។ អំពីស្ថានភាពនៃការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តនានា ដែលអាជ្ញាធរខេត្ត និងមន្ទីរអង្គភាពជំនាញពាក់ព័ន្ធមានកាតព្វកិច្ចអនុវត្ត ស្របតាមសមត្ថកិច្ចដែលបានកំណត់ដោយច្បាប់ ទាក់ទងនឹងការផ្តល់សេវាសាធារណៈផ្សេងៗទៀតជូនប្រជាពលរដ្ឋ ដែលស្ថិតក្រោមសមត្ថកិច្ច និងការទទួលខុសត្រូវរបស់មន្ត្រីមានសមត្ថកិច្ចនីមួយៗ។

ទន្ទឹមនឹងនេះ **លោកជំទាវបណ្ឌិត**បានគូសបញ្ជាក់អំពីទស្សនវិស័យ និងទិសដៅយុទ្ធសាស្ត្ររបស់ព្រឹទ្ធសភា នីតិកាលទី៥ ក្រោមការដឹកនាំដ៏ឈ្លាសវៃនិងទស្សនវិស័យវែងឆ្ងាយប្រកបដោយគតិបណ្ឌិតខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ដែល**សម្តេចប្រធាន** តែងតែផ្តោតការយកចិត្តទុកដាក់ខ្ពស់លើសុខុមាលភាព តម្រូវការ និងផលប្រយោជន៍ស្របច្បាប់របស់ប្រជាពលរដ្ឋជាចម្បង ហើយបានណែនាំជាបន្តបន្ទាប់ដល់មន្ត្រីគ្រប់លំដាប់ថ្នាក់ ឱ្យអនុវត្តភារកិច្ចតាមតួនាទី និងសមត្ថកិច្ចរបស់ខ្លួន ដោយគោរពយ៉ាងម៉ឺងម៉ាត់តាមគោលការណ៍នីតិរដ្ឋ តម្លាភាព គណនេយ្យភាព និងភាពស្មោះត្រង់ខ្ពស់បំផុត ក្នុងការបម្រើប្រជាពលរដ្ឋ និងការពារផលប្រយោជន៍សាធារណៈ។

នៅក្នុងជំនួបនោះ ក៏មានលើកឡើងនូវសំណូមពរមួយចំនួន តាមរយៈគណៈកម្មការទី៦ព្រឹទ្ធសភាផងដែរ ព្រមទាំងបានសម្តែងនូវអំណរគុណ និងកោតសរសើរខ្ពស់ចំពោះខ្លឹមសារ និងសារៈសំខាន់នៃកិច្ចពិភាក្សា ដែលមានលក្ខណៈស្ថាបនាប្រកបដោយវិជ្ជាជីវៈ ដែលជាការឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែង និងភាពចាំបាច់ក្នុងការពង្រឹងប្រសិទ្ធភាពនៃការអនុវត្តច្បាប់ក្នុងការផ្តល់សេវាយុត្តិធម៌ជូនប្រជាពលរដ្ឋ។

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន





*គណៈប្រតិភូគណៈកម្មការទី៦ព្រឹទ្ធសភា ជួបពិភាក្សាការងារនិងថតរូបអនុស្សាវរីយ៍ជាមួយថ្នាក់ដឹកនាំសាលាដំបូង និងអយ្យការអមសាលាដំបូងខេត្តកោះកុង*

# គណៈប្រតិភូគណៈកម្មការទី៧ព្រឹទ្ធសភា អញ្ជើញជួបពិភាក្សាការងារជាមួយ ថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា

នាព្រឹកថ្ងៃអង្គារ ទី២៤ ខែមីនា ឆ្នាំ២០២៦ គណៈប្រតិភូគណៈកម្មការអប់រំ យុវជន កីឡា ធម្មការ សាសនា វប្បធម៌ វិចិត្រសិល្បៈ និងទេសចរណ៍ នៃព្រឹទ្ធសភា (គណៈកម្មការទី៧) ដឹកនាំដោយ ឯកឧត្តម **ឈិត សុខុន** ប្រធានគណៈកម្មការ បាន អញ្ជើញជួបពិភាក្សាការងារជាមួយថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា ដឹកនាំដោយឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ដើម្បីឈ្វេងយល់អំពីវឌ្ឍនភាពការងារ បញ្ហាប្រឈម វិធានការដោះស្រាយ និងទិសដៅបន្តនៃ ការអនុវត្តគោលនយោបាយអប់រំនៅបឋមសិក្សា នៅទីស្តីការ ក្រសួងអប់រំ យុវជន និងកីឡា។



*គណៈប្រតិភូគណៈកម្មការទី៧ព្រឹទ្ធសភា អញ្ជើញជួបពិភាក្សាការងារជាមួយថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា*

ក្នុងជំនួបពិភាក្សាការងារនោះ **ឯកឧត្តមរដ្ឋមន្ត្រី** បាន ស្វាគមន៍ និងជម្រាបជូនគណៈប្រតិភូ អំពីសមិទ្ធផលការងារ សំខាន់ៗ ដែលក្រសួងអប់រំ យុវជន និងកីឡា សម្រេចបាន ក្នុងរយៈពេលជាង១០ឆ្នាំកន្លងមក ដោយបានរំលេចពី សមិទ្ធផលសំខាន់ៗរួមមាន៖ **១**-សមិទ្ធផលអប់រំ យុវជន និងកីឡា **២**-កំណែទម្រង់សាលារៀន **៣**-កំណែទម្រង់គ្រឹះស្ថានសិក្សា **៤**-កំណែទម្រង់គ្រឹះស្ថានអប់រំគ្រូ និង**៥**-ទិសដៅ អនាគត។ បច្ចុប្បន្នក្រសួងអប់រំ យុវជន និងកីឡា បាននិង កំពុងយកចិត្តទុកដាក់បន្តអនុវត្តយ៉ាងសកម្មនូវយុទ្ធសាស្ត្រ បញ្ចកោណ ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល ដែល ផ្តោតលើ «ការអភិវឌ្ឍមូលធនមនុស្ស» ជាអាទិភាពខ្ពស់បំផុត ដោយបានដាក់ចេញនូវការងារអាទិភាពសំខាន់ៗចំនួន៨។

ក្រោយពីបានស្តាប់បទបង្ហាញដោយយកចិត្តទុកដាក់ រួចមក គណៈប្រតិភូបានលើកជាសំណូមពរ សំណួរ និង ពិភាក្សាគ្នាយ៉ាងផុលផុសដោយស្មារតីទទួលខុសត្រូវខ្ពស់ ប្រមូលបានធាតុចូលដ៏សំខាន់ក្នុងការរួបរួមគ្នាកំណែទម្រង់ វិស័យអប់រំ យុវជន និងកីឡា ឱ្យកាន់តែល្អប្រសើរថែមទៀត ដើម្បីជាឧត្តមប្រយោជន៍ជាតិ ឆ្ពោះទៅសម្រេចបានចក្ខុវិស័យ អភិវឌ្ឍមូលធនមនុស្សដែលមានជំនាញខ្ពស់និងការអភិវឌ្ឍ ប្រកបដោយចីរភាព។

ក្នុងឱកាសនោះ ឯកឧត្តម **ឈិត សុខុន** បានវាយតម្លៃ ខ្ពស់ និងថ្លែងកោតសរសើរចំពោះការដឹកនាំរបស់**ឯកឧត្តម រដ្ឋមន្ត្រី** ដែលបានខិតខំបំពេញការងារយ៉ាងសកម្មសម្រេច បានសមិទ្ធផលសំខាន់ៗជាច្រើន និងមានគំនិតផ្តួចផ្តើមជា យុទ្ធសាស្ត្រដែលធានានូវប្រសិទ្ធភាព ក្នុងការដឹកនាំ គ្រប់គ្រង ការងារអប់រំ យុវជន និងកីឡា និងបានផ្តល់នូវមតិមួយចំនួន



*ទិដ្ឋភាពជំនួបពិភាក្សាការងារ*

រួមមាន៖

-បន្តលើកកម្ពស់ការអភិវឌ្ឍវិស័យអប់រំ ដែលជាវិស័យអាទិភាព ដើម្បីលើកស្ទួយសេដ្ឋកិច្ច-សង្គម ចំណេះដឹង សមត្ថភាពនិងគុណធម៌ ដើម្បីចូលរួមអភិវឌ្ឍន៍ប្រទេសជាតិ និងយកចិត្តទុកដាក់កែលម្អ ហេដ្ឋារចនាសម្ព័ន្ធ ការបំពាក់សម្ភារៈឧបទ្ទេសតាមបន្ទប់មុខវិជ្ជាសំខាន់ៗ ព្រមទាំងធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់សហគមន៍ និងមាតាបិតាសិស្ស ក្នុងការបញ្ជូនកូនចៅគ្រប់អាយុបានចូលរៀននៅកម្រិតបឋមសិក្សា។

-បន្តយកចិត្តទុកដាក់លើសុខភាពសិក្សា តាមរយៈកម្មវិធីផ្តល់អាហារូបត្ថម្ភដល់កុមារនិងការត្រួតពិនិត្យគុណភាពចំណីអាហារនៅតាមសាលារៀន ដោយមានការចូលរួមរបស់មាតាបិតា អាណាព្យាបាល និងសហគមន៍ ក្នុងការអប់រំស្របតាមពាក្យស្លោក «ភាពជាដៃគូរដ្ឋ និងសហគមន៍ដើម្បីអប់រំ»។

-បន្តអនុវត្តកំណែទម្រង់គ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀន សំដៅលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន ឱ្យស្របតាមស្តង់ដាវិជ្ជាជីវៈ និងកម្មវិធីអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំដល់គណៈគ្រប់គ្រងសាលា និងគ្រូបង្រៀន ជាពិសេសការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាននិងបញ្ញាសិប្បនិម្មិត។

-បន្តពង្រឹងការគ្រប់គ្រងតាមសាលារៀន ដើម្បីឈានទៅសម្រេចបានស្តង់ដាសាលារៀនគំរូ ដោយពង្រឹងវិន័យសីលធម៌ គុណធម៌ និងអាកប្បកិរិយាវិជ្ជមានរបស់អ្នកផ្តល់សេវាអប់រំ និងសិស្សានុសិស្ស។

-លើកទឹកចិត្តបន្តការសិក្សាស្រាវជ្រាវគោលនយោបាយអប់រំទាំងក្នុងតំបន់និងសកលលោក សម្រាប់បម្រើឱ្យកម្មវិធីកំណែទម្រង់ និងការរៀបចំគោលនយោបាយ ដើម្បីឱ្យឆ្លើយតបទៅនឹងការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម។



*ឯកឧត្តម ឈិត សុខុន អញ្ជើញប្រគល់វត្ថុអនុស្សាវរីយ៍ ជូនឯកឧត្តមរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា*

មុននឹងបញ្ចប់ **ឯកឧត្តមប្រធានគណៈប្រតិភូ** បានប្រសិទ្ធពរជ័យជូន ឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងសហការី នាឱកាសចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរខាងមុខ សូមសមប្រកបនឹងសុខភាពល្អ សេចក្តីសុខ សេចក្តីចម្រើន និងទទួលបានជោគជ័យគ្រប់ភារកិច្ច៕

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន

# គណៈប្រតិភូគណៈកម្មការទី៩ព្រឹទ្ធសភា អញ្ជើញចុះឈ្វេងយល់វិស័យពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់ខ្លួន នៅខេត្តកំពត និងខេត្តស្វាយរៀង




*គណៈប្រតិភូគណៈកម្មការទី៩ព្រឹទ្ធសភា ជួបពិភាក្សាការងារជាមួយអាជ្ញាធរខេត្តកំពត*

គណៈប្រតិភូគណៈកម្មការសាធារណការ ដឹកជញ្ជូន អាកាសចរណ៍ស៊ីវិល ប្រៃសណីយ៍ ទូរគមនាគមន៍ ឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា នវានុវត្តន៍ រ៉ែ ថាមពល ពាណិជ្ជកម្ម រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ នៃព្រឹទ្ធសភា (គណៈកម្មការទី៩) ដឹកនាំដោយឯកឧត្តម **អ៊ុំ សារឹទ្ធ** ប្រធានគណៈកម្មការ បានអញ្ជើញចុះបំពេញបេសកកម្មឈ្វេងយល់តាមវិស័យជាសមត្ថកិច្ចរបស់ខ្លួន នៅខេត្តកំពត ពីថ្ងៃទី២ ដល់ថ្ងៃទី៤ ខែមីនា និងនៅខេត្តស្វាយរៀង ពីថ្ងៃទី៩ ដល់ថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៦។

ក្នុងដំណើរបេសកកម្មនេះ គណៈប្រតិភូ បានអញ្ជើញជួបពិភាក្សាការងារជាមួយអាជ្ញាធរខេត្ត ក្រុមប្រឹក្សាខេត្ត និងមន្ទីរជំនាញពាក់ព័ន្ធ ដោយនៅខេត្តកំពត ដឹកនាំដោយឯកឧត្តម **ខៀវ រិទ្ធិភ័ណ្ឌ** អភិបាលរងខេត្ត និងនៅខេត្តស្វាយរៀង ដឹកនាំដោយលោក **សរ សុជានី** អភិបាល-រងខេត្ត។ កិច្ចប្រជុំទាំងនេះមានគោលបំណងឈ្វេងយល់អំពីវឌ្ឍនភាពការងារដែលអាជ្ញាធរខេត្តសម្រេចបាន បញ្ហាប្រឈម ការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ទិសដៅអភិវឌ្ឍន៍ និងការរំពឹងទុកនាពេលអនាគត ព្រមទាំងការអភិវឌ្ឍឃុំ សង្កាត់ប្រកបដោយសុវត្ថិភាព។

ក្នុងនាមប្រធានគណៈប្រតិភូ ឯកឧត្តម បាននាំយកនូវការផ្តាំផ្ញើសួរសុខទុក្ខ និងជូនពរសព្ទសាធុការពីសំណាក់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា ឯកឧត្តម **អ៊ុច បូររិទ្ធ** អនុប្រធានទី១ និងឯកឧត្តមបណ្ឌិត **ធន់ វឌ្ឍនា** អនុប្រធានទី២ព្រឹទ្ធសភា ជូនដល់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់ជាន់ថ្នាក់នៅខេត្តទាំងពីរ ព្រមទាំងបានជម្រាបអំពីតួនាទី និងភារកិច្ចរបស់គណៈកម្មការ ដែលត្រូវបំពេញមុខងារស្នូលទាំងបីរបស់ព្រឹទ្ធសភា រួមមាន មុខងារនីតិកម្ម មុខងារតាមដានការអនុវត្ត





*គណៈប្រតិភូគណៈកម្មការទី៩ព្រឹទ្ធសភា ជួបពិភាក្សាការងារជាមួយអាជ្ញាធរខេត្តស្វាយរៀង*






*គណៈប្រតិភូគណៈកម្មការទី៩ព្រឹទ្ធសភា អញ្ជើញទស្សនកិច្ចកំពង់ផែពហុបំណងកំពត*

ច្បាប់ និងមុខងារប្រមូលព័ត៌មាន ដើម្បីជាយោបល់ចូលរួមចំណែកជាមួយរាជរដ្ឋាភិបាលក្នុងការអនុវត្តគោលនយោបាយអភិវឌ្ឍន៍ និងរក្សាសុខសន្តិភាព ស្ថិរភាព និងវឌ្ឍនភាពជាតិ។

ក្រោយពីអាជ្ញាធរខេត្ត បានទទួលស្វាគមន៍យ៉ាងកក់ក្តៅ និងធ្វើសេចក្តីរាយការណ៍ជូនគណៈប្រតិភូអំពីស្ថានភាពភូមិសាស្ត្រ លទ្ធផលការងារដែលសម្រេចបាន បញ្ហាប្រឈម និងទិសដៅអភិវឌ្ឍន៍នាពេលខាងមុខ ព្រមទាំងលទ្ធផលការងារពាក់ព័ន្ធវិស័យ និងអនុវិស័យក្នុងដែនសមត្ថកិច្ចរបស់គណៈកម្មការទី៩ព្រឹទ្ធសភា រួចមកឯកឧត្តម **អ៊ុំ សារឹទ្ធ** ប្រធានគណៈកម្មការទី៩ព្រឹទ្ធសភា បានថ្លែងកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះថ្នាក់ដឹកនាំ និងអាជ្ញាធរខេត្តទាំងពីរ ដែលបានខិតខំអនុវត្តភារកិច្ចដោយស្មារតីទទួលខុសត្រូវខ្ពស់ ឈរលើគោលការណ៍នីតិរដ្ឋ និងអភិបាលកិច្ចល្អ ដោយសម្រេចបានលទ្ធផលល្អប្រសើរ។ ទន្ទឹមនឹងនេះ ឯកឧត្តម ក៏បានលើកទឹកចិត្តឱ្យបន្តថែរក្សា សាមគ្គីភាព និងឯកភាពផ្ទៃក្នុង ដើម្បីរួមការអនុវត្តការងារឱ្យបានកាន់តែមានប្រសិទ្ធភាពថែមទៀត ក្នុងនោះដែលសំខាន់គឺ មនុស្ស ទឹក ភ្លើង និងបច្ចេកវិទ្យា ស្របតាមក្របខ័ណ្ឌគោលនយោ-បាយ និងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា។

ក្រៅពីជំនួបពិភាក្សាការងារជាមួយនឹងអាជ្ញាធរខេត្តទាំងពីរ គណៈប្រតិភូបានអញ្ជើញចុះទស្សនកិច្ចជាក់ស្តែងនៅកំពង់ផែពហុបំណងកំពត និងកំពង់ផែទេសចរណ៍អន្តរជាតិកំពត ដើម្បីសិក្សាពីសកម្មភាពកំពង់ផែទាំងពីរ បញ្ហាប្រឈម និងទិសដៅអភិវឌ្ឍន៍នាពេលអនាគត និងអញ្ជើញទស្សនកិច្ចតំបន់សេដ្ឋកិច្ចពិសេសមេនហាតធានក្រុងបាវិត ដើម្បីពិនិត្យសកម្មភាពផលិតកម្ម និងស្ថានភាពជីវភាពកម្មករ ព្រមទាំងការថែទាំសុខភាពដែលក្រុមហ៊ុនបាននិងកំពុងយកចិត្តទុកដាក់ដោយស្មារតីទទួលខុសត្រូវខ្ពស់តាមច្បាប់ជាធរមាន បញ្ហាប្រឈម និងទិសដៅអភិវឌ្ឍន៍បន្តសម្រាប់ពេលអនាគតរបស់ក្រុមហ៊ុន៕

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន





*គណៈប្រតិភូគណៈកម្មការទី៩ព្រឹទ្ធសភា អញ្ជើញទស្សនកិច្ចតំបន់សេដ្ឋកិច្ចពិសេសក្រុងបាវិត ខេត្តស្វាយរៀង*

# ឯកឧត្តម ប៉ុល លឹម លើកទឹកចិត្តដល់រដ្ឋបាលស្រុកនិងក្រុមប្រឹក្សាឃុំទាំងអស់ បន្តខិតខំ លើកកម្ពស់ការបំពេញតួនាទី និងភារកិច្ចរបស់ខ្លួន ប្រកបដោយការទទួលខុសត្រូវខ្ពស់

ក្នុងឱកាស**ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៤** (ខេត្តបាត់ដំបង បន្ទាយមានជ័យ សៀមរាប ឧត្តរមានជ័យ និងខេត្តប៉ៃលិន) ដឹកនាំដោយឯកឧត្តម **ប៉ុល លឹម** ប្រធានក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៤ អញ្ជើញជួបសំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំ ស្មៀន និងនាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ និងអាជ្ញាធរស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ ចំនួន១៨០នាក់ នាព្រឹកថ្ងៃសុក្រ ទី២០ ខែមីនា ឆ្នាំ២០២៦ ឯកឧត្តម **ប៉ុល លឹម** បានលើកទឹកចិត្តដល់រដ្ឋបាលស្រុក និងក្រុមប្រឹក្សាឃុំទាំងអស់ ឱ្យបន្តខិតខំលើកកម្ពស់ការបំពេញតួនាទី ភារកិច្ចរបស់ខ្លួន ប្រកបដោយការទទួលខុសត្រូវខ្ពស់ ស្របតាមច្បាប់ បទដ្ឋានគតិយុត្តនានា និងសេចក្តីណែនាំរបស់ក្រសួងមហាផ្ទៃ ព្រមទាំងលើកកម្ពស់ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋប្រកបដោយតម្លាភាព និងគណនេយ្យភាព។

ជាកិច្ចចាប់ផ្តើម អង្គពិធីបានគោរពវិញ្ញាណក្ខន្ធវីរកងកម្លាំងប្រដាប់អាវុធនិងដឹងគុណមិនអាចកាត់ថ្លៃបានចំពោះពលិកម្មគ្រប់បែបយ៉ាងរបស់វីរយុទ្ធជន ក្នុងបុព្វហេតុការពារជាតិ មាតុភូមិ ពីការឈ្លានពានរបស់ថៃ។

ក្នុងឱកាសនោះ ឯកឧត្តម **ប៉ុល លឹម** បាននាំប្រសាសន៍ផ្តាំផ្ញើសួរសុខទុក្ខពីសំណាក់ថ្នាក់ដឹកនាំព្រឹទ្ធសភា ជូនដល់អ្នកចូលរួមក្នុងអង្គពិធី និងសម្តែងនូវការគោរពអរគុណចំពោះបងប្អូនប្រជាពលរដ្ឋក្នុងខេត្តបន្ទាយមានជ័យ ដែលបានសាមគ្គីគ្នាជាធ្លុងមួយ ជម្នះរាល់ការលំបាកពីការឈ្លានពានរបស់ថៃ។ ឯកឧត្តមបានអំពាវនាវដល់អ្នកចូលរួមពិធីផ្សព្វផ្សាយដល់បងប្អូនប្រជាពលរដ្ឋ បន្តជឿជាក់លើការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់**សម្តេចតេជោ** និង**សម្តេចធិបតី** ក្នុងការការពារបូរណភាពទឹកដី សុខសន្តិភាព និងការអភិវឌ្ឍប្រទេសជាតិ។



*ឯកឧត្តម ប៉ុល លឹម ប្រធានក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៤*

**ឯកឧត្តមប្រធានក្រុម** ក៏បានជម្រាបអំពីគោលបំណងនៃពិធីសំណេះសំណាលនាព្រឹកនោះ ដើម្បីឈ្វេងយល់និងផ្តល់ឱកាសជូនសមាជិកក្រុមប្រឹក្សាឃុំ ស្មៀន និងនាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ លើកឡើងអំពីបញ្ហាប្រឈម កង្វល់ តម្រូវការ និងសំណូមពរ ជុំវិញការអនុវត្តតួនាទី ភារកិច្ចក្នុងការអនុវត្តច្បាប់ ដោយផ្តោតលើការងារស្ថិតិប្រជាពលរដ្ឋ



*ថ្នាក់ដឹកនាំ និងអាជ្ញាធរខេត្ត ព្រមទាំងក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៤ ក្នុងពិធីសំណេះសំណាលនៅស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ*



*ឯកឧត្តម ងី ច័ន្ទ្រផល អនុប្រធានក្រុមភូមិភាគទី៤ អញ្ជើញមានមតិយោបល់ក្នុងពិធីសំណេះសំណាល*



*ឯកឧត្តម លេង វី សមាជិកក្រុមភូមិភាគទី៤ អញ្ជើញមានមតិយោបល់ក្នុងពិធីសំណេះសំណាល*

(សៀវភៅស្នាក់នៅ សៀវភៅគ្រួសារ) ការផ្លាស់ចេញ-ចូល ការងារអត្រានុកូលដ្ឋាន និងការកែតម្រូវអក្ខរាវិរុទ្ធ ការងារធ្វើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ការងារមូលនិធិអភិវឌ្ឍន៍ឃុំ សង្កាត់ និងការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព៧ចំណុច។

តាមរយៈការឡើងរាយការណ៍របស់**លោកអភិបាលរងខេត្ត** មតិយោបល់របស់ក្រុមប្រឹក្សាឃុំ នាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ អំពីបញ្ហាប្រឈមនិងសំណូមពរ ការចែករំលែកបទពិសោធល្អៗ ពីសំណាក់**ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៤** រួចមក ឯកឧត្តម **ប៉ុល លឹម** បានវាយតម្លៃខ្ពស់ចំពោះការខិតខំបំពេញការងាររបស់ថ្នាក់ដឹកនាំស្រុក ក្រុមប្រឹក្សាឃុំ និងអាជ្ញាធរគ្រប់ជាន់ថ្នាក់ ជាពិសេសការងារដែលពាក់ព័ន្ធនឹងការងារផ្តល់សេវារដ្ឋបាល អត្រានុកូលដ្ឋាន ការធ្វើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ការអភិវឌ្ឍឃុំ និងការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព។

**ឯកឧត្តមប្រធានក្រុម** បានអរគុណចំពោះក្រុមប្រឹក្សាឃុំ ស្នឿន នាយប៉ុស្តិ៍នគរបាលឃុំ ដែលលើកឡើងនូវបញ្ហាប្រឈម សំណូមពរ និងចំណុចល្អៗជាច្រើន ដែលបានឆ្លុះបញ្ចាំងអំពីការយកចិត្តទុកដាក់ខ្ពស់ក្នុងការរួមគ្នាប្រមូលគំនិត មតិយោបល់ បទពិសោធល្អៗដ៏មានតម្លៃ សម្រាប់ជាគុណប្រយោជន៍ក្នុងការបំពេញការងាររបស់យើងឱ្យកាន់តែល្អប្រសើរថែមទៀត។

ចំពោះបញ្ហាប្រឈម និងសំណូមពរនានាដែលអាជ្ញាធរស្រុក ក្រុមប្រឹក្សាឃុំ ស្នឿន និងនាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំបានលើកឡើង **ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៤**



*ឯកឧត្តម សត ណាឌី សមាជិកក្រុមភូមិភាគទី៤ អញ្ជើញមានមតិយោបល់ក្នុងពិធីសំណេះសំណាល*



*ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៤ ថតរូបអនុស្សាវរីយ៍ជាមួយអាជ្ញាធរស្រុកភ្នំស្រុក ខេត្តបន្ទាយមានជ័យ*

នឹងរាយការណ៍ជូនថ្នាក់ដឹកនាំព្រឹទ្ធសភា និងគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ដើម្បីលើកជាអនុសាសន៍ជម្រាបដល់ក្រសួង ស្ថាប័នពាក់ព័ន្ធធ្វើការដោះស្រាយ៕

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន

# ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៦ អញ្ជើញចុះជួបសំណេះសំណាលជាមួយ ក្រុមប្រឹក្សាឃុំ នៅខេត្តព្រៃវែង និងខេត្តស្វាយរៀង



*លោកជំទាវ មាន សំអាន សំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំ នៅស្រុកពារាំង ខេត្តព្រៃវែង*



*លោកជំទាវ មាន សំអាន សំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំ នៅស្រុកស៊ីធរកណ្ដាល ខេត្តព្រៃវែង*

ដើម្បីស្ដាប់អំពីវឌ្ឍនភាពការងារ បញ្ហាប្រឈម សំណូមពរ តម្រូវការជាអាទិភាព ទិសដៅនិងការប្ដេជ្ញាចិត្តក្នុងការអនុវត្តគោលនយោបាយអភិវឌ្ឍន៍ឃុំ សង្កាត់ ឆ្នាំ២០២២-២០២៧ ដែលឃុំសង្កាត់នីមួយៗបានដាក់ចេញកន្លងទៅ និងការអភិវឌ្ឍក្នុងមូលដ្ឋាន ដើម្បីរួមគ្នារិះរកវិធីដោះស្រាយតាមសមត្ថកិច្ចរៀងៗខ្លួនឱ្យមានប្រសិទ្ធភាពជូនប្រជាពលរដ្ឋ ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៦ (ខេត្តព្រៃវែង និងខេត្តស្វាយរៀង) បានអញ្ជើញចុះជួបសំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំ និងអាជ្ញាធរមូលដ្ឋានក្នុងស្រុកនៃខេត្តព្រៃវែង និងខេត្តស្វាយរៀង។

កម្មវិធីសំណេះសំណាលនៅខេត្តទាំងពីរ ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៦ បានបែងចែកជាពីរក្រុម ក្រុមទី១ ដឹកនាំដោយលោកជំទាវ **មាន សំអាន** ប្រធានក្រុម រួមដំណើរដោយឯកឧត្តម **ឈួន ឡេង** លេខាធិការក្រុម និងឯកឧត្តម **ហេង ហាលីម** សមាជិកក្រុម អញ្ជើញចុះទៅកាន់ស្រុកពារាំង ស្រុកស៊ីធរកណ្ដាល ស្រុកស្វាយអន្ទរ ស្រុកកញ្ជ្រៀច និងស្រុកកំចាយមារ ខេត្តព្រៃវែង ពីថ្ងៃទី១១



*ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៦ ថតរូបអនុស្សាវរីយ៍ជាមួយក្រុមប្រឹក្សាឃុំ នៅស្រុកកញ្ជ្រៀច ខេត្តព្រៃវែង*



*ឯកឧត្តម ឈួន ឡេង លេខាធិការក្រុមភូមិភាគទី៦ មានមតិយោបល់ក្នុងពិធីសំណេះសំណាល នៅស្រុកកំចាយមារ ខេត្តព្រៃវែង*



*ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៦ ជួបសំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំ នៅស្រុកស្វាយអន្ទរ ខេត្តព្រៃវែង*



*ឯកឧត្តម អ៊ុំ សារឹទ្ធ សំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំ នៅស្រុករំដួល ខេត្តស្វាយរៀង*

ដល់ថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៦ មានអ្នកចូលរួមចំនួន ៣៦៦នាក់ និងក្រុមទី២ ដឹកនាំដោយឯកឧត្តម **អ៊ុំ សារឹទ្ធ** អនុប្រធានក្រុម រួមដំណើរដោយឯកឧត្តម **គឹម ឆា** ឯកឧត្តម **ម៉ែន-ស៊ីផាន់** និងឯកឧត្តម **គង់ មុនីកា** សមាជិកក្រុម អញ្ជើញចុះទៅកាន់ស្រុករំដួល ស្រុករមាសហែក និងស្រុកស្វាយទាប ខេត្តស្វាយរៀង នៅថ្ងៃទី១៨ និងទី១៩ ខែមីនា ឆ្នាំ២០២៦ មានអ្នកចូលរួមចំនួន២២៨នាក់។

នៅគ្រប់ជំនួប ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៦ បានជម្រាបជូនអង្គពិធីអំពីមុខងាររបស់ព្រឹទ្ធសភា និងការងារអាទិភាពចម្បងចំនួន២ ដែលសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នីតិកាលទី៥ បានដាក់ចេញ គឺការលើកកម្ពស់ការទូតសភា និងការផ្សារភ្ជាប់ជាមួយអង្គបោះឆ្នោតនៅថ្នាក់មូលដ្ឋាន ជាពិសេសតាមរយៈគោលនយោបាយឈ្នះ-ឈ្នះរបស់**សម្តេចតេជោ** ផលលាភនៃសន្តិភាព បាននិងកំពុងផ្តល់ឧត្តមប្រយោជន៍សម្រាប់វឌ្ឍនភាពផ្នែកសេដ្ឋកិច្ច និងសង្គម ដែលប្រទេសកម្ពុជាសម្រេចបានសមិទ្ធផលដ៏ថ្លៃថ្លាបំផុតលើគ្រប់វិស័យ ទាំងវិស័យនយោបាយ សន្តិសុខ សណ្តាប់ធ្នាប់សង្គម និងទាំងខាងការអភិវឌ្ឍសង្គម សេដ្ឋកិច្ច ធ្វើឱ្យប្រជាជាតិខ្មែរទាំងមូលបានរស់នៅយ៉ាងសុខសាន្តប្រកបដោយកិត្តិយសនិងសេចក្តីថ្លៃថ្នូរក្នុងសន្តិភាព សេរីភាព អធិបតេយ្យ បូរណភាពទឹកដីរបស់ខ្លួន។

ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៦ បានវាយតម្លៃខ្ពស់ចំពោះលទ្ធផលវិជ្ជមានរបស់អាជ្ញាធរស្រុក និងក្រុមប្រឹក្សាឃុំ ដែលបានបំពេញភារកិច្ចយ៉ាងល្អប្រសើរ និងផ្តាំផ្ញើដល់សមាជិកក្រុមប្រឹក្សាឃុំ ត្រូវចូលរួមពិនិត្យនិងអនុវត្តឱ្យបាន ១០០% លើផែនការអភិវឌ្ឍន៍ឃុំ ដែលបានដាក់ចេញនាពេលកន្លងទៅ ដោយធានាឱ្យមានប្រសិទ្ធភាព ដើម្បីឆ្លើយតបបានទាន់ពេលវេលាតាមតម្រូវការរបស់ប្រជាពលរដ្ឋ និងត្រូវយកចិត្តទុកដាក់ក្នុងការបង្ក្រាបឱ្យបានម៉ឺងម៉ាត់រាល់បទល្មើសប្រឈមក្នុងសង្គម ជាពិសេសបន្តគាំពារនិងផ្តល់ជំនួយគាំទ្រជូនពលរដ្ឋភៀសសឹក។ ចំពោះបញ្ហាព្រំដែន ក្រុមភូមិភាគទី៦ បានអំពាវនាវឱ្យប្រជាពលរដ្ឋមានការស្ងប់ចិត្ត ជឿជាក់លើរាជរដ្ឋាភិបាល និងកងកម្លាំងប្រដាប់អាវុធ ក្នុងការដោះស្រាយតាមរយៈការចរចាដោយសន្តិវិធី ជៀសវាងការប្រើកម្លាំង និងបន្តគាំទ្រកងកម្លាំងនៅតាមព្រំដែន ព្រមទាំងជំរុញការប្រើប្រាស់ និងគាំទ្រផលិតផលក្នុងស្រុក។



*ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៦ សំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំ នៅស្រុករមាសហែក ខេត្តស្វាយរៀង*



*ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៦ សំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំ នៅស្រុកស្វាយទាប ខេត្តស្វាយរៀង*

ចំណែកសំណើ និងសំណូមពរនានា ដែលលើសពីសមត្ថកិច្ចមូលដ្ឋាន ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៦ នឹងដកស្រង់ធ្វើរបាយការណ៍ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា និងស្នើសុំគោលការណ៍ឯកភាពពីថ្នាក់ដឹកនាំព្រឹទ្ធសភា ដើម្បីធ្វើសំណើទៅក្រសួង ស្ថាប័នពាក់ព័ន្ធនានា ដើម្បីជួយដោះស្រាយទៅតាមជំនាញនីមួយៗ៕

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន

# ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៧ អញ្ជើញជួបសំណេះសំណាលជាមួយអាជ្ញាធរមូលដ្ឋានខេត្តកំពង់ស្ពឺ



*ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៧ ជួបសំណេះសំណាលជាមួយអាជ្ញាធរមូលដ្ឋាន ខេត្តកំពង់ស្ពឺ*

នាព្រឹកថ្ងៃសុក្រ ទី២០ ខែមីនា ឆ្នាំ២០២៦ ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៧ ដឹកនាំដោយឯកឧត្តមបណ្ឌិត **ម៉ុង ឫទ្ធី** ប្រធានក្រុម និងជាប្រធានគណៈកម្មការទី៣ព្រឹទ្ធសភា បានអញ្ជើញជួបសំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ និងនាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ ក្នុងខេត្តកំពង់ស្ពឺ សរុបចំនួន៣៤០នាក់ នៅសាលាខេត្តកំពង់ស្ពឺ។

ពិធីនេះរៀបចំឡើងក្នុងគោលបំណងដើម្បីផ្សារភ្ជាប់ និងរួមប្រាស្រ័យទំនាក់ទំនងឱ្យកាន់តែជិតស្និទ្ធជាមួយ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងការពង្រឹងការអនុវត្តតួនាទីភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ការអភិវឌ្ឍមូលដ្ឋាន ការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព និងការផ្តល់សេវាសាធារណៈ ដើម្បីចូលរួមដោះស្រាយ និងនាំយកយោបល់ បញ្ហាប្រឈម និងសំណូមពររបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា និងព្រឹទ្ធសភា។

ក្នុងឱកាសនោះ ឯកឧត្តមបណ្ឌិត **ម៉ុង ឫទ្ធី** ប្រធានក្រុម បានសម្តែងនូវការដឹងគុណចំពោះវីរភាពដឹកនាំប្រកបដោយមនសិការស្នេហាជាតិនិងភាពវាងវៃដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និងសម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី ក្នុងការដឹកនាំប្រទេសជាតិ។ **ឯកឧត្តមប្រធានក្រុម** បានគូសបញ្ជាក់អំពីការខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំទាំងពីរ ក្នុងការគ្រប់គ្រងស្ថានការណ៍ជាតិដោយឈរលើគោលការណ៍សាមគ្គីភាព និងសន្តិភាពនិយម ព្រមទាំងការខិតខំប្រឹងប្រែងរហូតសម្រេចបាននូវកិច្ចព្រមព្រៀងបទឈប់បាញ់ជុំវិញជម្លោះព្រំប្រទល់រវាងកម្ពុជា-ថៃ ដែលជាសក្ខីភាពបង្ហាញពីភាពមោះមុតរបស់កម្ពុជាលើឆាកអន្តរជាតិក្នុងការស្វែងរកសន្តិភាព។


*ឯកឧត្តមបណ្ឌិត ម៉ុង ឫទ្ធី អញ្ជើញមានប្រសាសន៍ក្នុងអង្គពិធី*

**ឯកឧត្តមប្រធានក្រុម** បានជម្រាបជូនអង្គពិធីអំពីមុខងារនិងអាទិភាពចម្បងរបស់ព្រឹទ្ធសភា នីតិកាលទី៥ ដែលផ្តោតលើការលើកកម្ពស់ការទូតសភា និងការពង្រឹងទំនាក់ទំនងជាមួយអង្គបោះឆ្នោត ជាពិសេសជាមួយក្រុមប្រឹក្សាឃុំសង្កាត់ ដែលជាប្រតិបត្តិករជួរមុខនៅមូលដ្ឋាន។

ជាមួយគ្នានេះ **ឯកឧត្តមប្រធានក្រុម**ក៏បានបញ្ជាក់ថា រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា បានបន្តយុទ្ធនាការ



ឯកឧត្តម ហន ភក្តី អភិបាលស្តីទីខេត្តកំពង់ស្ពឺ ឡើងរាយការណ៍



ឯកឧត្តម អាយ ខន សមាជិកក្រុមភូមិភាគទី៧ ឡើងមានមតិជូនអង្គពិធី

ពង្រឹងសន្តិភាព និងស្ថិរភាពនយោបាយ ដែលជាបុរេលក្ខខណ្ឌចាំបាច់សម្រាប់ការអភិវឌ្ឍប្រទេសជាតិ ដោយផ្តោតលើការទប់ស្កាត់និងបង្ក្រាបបទល្មើសគ្រប់ប្រភេទ រួមមាន៖ ការប្រយុទ្ធប្រឆាំងភេរវកម្ម ឧក្រិដ្ឋកម្មឆ្លងដែន អំពើជួញដូរមនុស្ស អាជីវកម្មផ្លូវភេទ ការជួញដូរ និងប្រើប្រាស់គ្រឿងញៀនខុសច្បាប់ ល្បែងស៊ីសងខុសច្បាប់ ព្រមទាំងការពង្រឹងការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព។

បន្ទាប់ពីបានស្តាប់ការរាយការណ៍និងការបកស្រាយពីឯកឧត្តម **ហន ភក្តី** អភិបាលស្តីទីខេត្តកំពង់ស្ពឺ អំពីបញ្ហាប្រឈម និងសំណូមពរនានាពីមូលដ្ឋានរួចមក ឯកឧត្តម **អាយ ខន** សមាជិកក្រុម បានបញ្ជាក់ជូនអង្គពិធីថា សំណូមពរដែលក្រុមប្រឹក្សាឃុំ សង្កាត់ បានស្នើសុំនាពេលមុន គឺរាជរដ្ឋាភិបាលគ្រោងពិចារណាផ្តល់ប្រាក់សោធននិវត្តន៍ដល់ក្រុមប្រឹក្សាឃុំ សង្កាត់នៅឆ្នាំ២០២៧ និងពន្លឿនការចេញប័ណ្ណកម្មសិទ្ធិដីធ្លីជូនប្រជាពលរដ្ឋផងដែរ។

**ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៧** បានវាយតម្លៃខ្ពស់ចំពោះការខិតខំប្រឹងប្រែងរបស់អាជ្ញាធរមូលដ្ឋាន ដែលបានបំពេញតួនាទី ភារកិច្ច ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ និងសម្រេចបានសមិទ្ធផលគួរជាទីមោទនៈជាច្រើន ហើយពិធីនេះ ក៏ជាឱកាសផ្លាស់ប្តូរនូវបទពិសោធ ដើម្បីពង្រឹងប្រសិទ្ធភាពការងារនៅមូលដ្ឋាន ក៏ដូចជាការបង្កើនសមត្ថភាព គុណភាពសេវាកម្ម និងជំរុញការអភិវឌ្ឍមូលដ្ឋាន ដើម្បីធានានូវសុខសុវត្ថិភាពជូនប្រជាពលរដ្ឋក្នុងមូលដ្ឋាន។

នាឱកាសនោះ **ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៧** បានជូនក្រូចលឿងដល់សមាជិកទាំងអស់ដែលបានអញ្ជើញ



ទិដ្ឋភាពក្នុងពិធីសំណេះសំណាល

ចូលរួមក្នុងពិធី សរុបចំនួន៣៤០កេស ព្រមទាំងជូនថវិកាដល់ក្រុមប្រឹក្សាឃុំសង្កាត់ និងនាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ចំនួន២៦៤នាក់ សរុបចំនួន១៣.២០០.០០០ រៀល៕

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន



ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៧ អញ្ជើញថតរូបអនុស្សាវរីយ៍

# ឯកឧត្តម ឈួន ឆាម៖ ពិធីសំណេះសំណាលនឹងផ្តល់នូវធាតុចូលជាគុណតម្លៃដ៏ល្អប្រសើរជូនអាជ្ញាធរពាក់ព័ន្ធជំរុញការអនុវត្តការងារនៅថ្នាក់ក្រោមជាតិ




*ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥ ជួបសំណេះសំណាលជាមួយអាជ្ញាធរស្រុកអង្គរជ័យ ខេត្តកំពត*

ឯកឧត្តម **ឈួន ឆាម** ប្រធានស្តីទីក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥ មានជំនឿយ៉ាងមុតមាំថា ពិធីជួបសំណេះសំណាលនេះ នឹងផ្តល់នូវធាតុចូលដែលជាគុណតម្លៃដ៏ល្អប្រសើរបន្ថែមជូនដល់ថ្នាក់ដឹកនាំស្រុក អាជ្ញាធរពាក់ព័ន្ធ ជាពិសេសសមាជិកក្រុមប្រឹក្សាឃុំ ដែលជាអង្គបោះឆ្នោតក្នុងការបំពេញតួនាទី ភារកិច្ចរបស់ខ្លួន ដើម្បីរួមចំណែកដល់ការជំរុញអនុវត្តគោលនយោបាយវិមជ្ឈការ វិសហមជ្ឈការ ការលើកកម្ពស់គុណភាព និងប្រសិទ្ធភាពសេវាសាធារណៈនៅថ្នាក់ក្រោមជាតិឱ្យកាន់តែប្រសើរឡើង។

ការលើកឡើងបែបនេះ ធ្វើឡើងក្នុងឱកាសដែលក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥ (ខេត្តកំពត ខេត្តតាកែវ និងខេត្តកែប) អញ្ជើញចុះជួបសំណេះសំណាលជាបន្តបន្ទាប់ជាមួយថ្នាក់ដឹកនាំស្រុក អាជ្ញាធរពាក់ព័ន្ធ និងក្រុមប្រឹក្សាឃុំ សង្កាត់ នៅស្រុកអង្គរជ័យ ខេត្តកំពត និងនៅស្រុកបូរីជលសារ និងក្រុងដូនកែវ ខេត្តតាកែវ កាលពីថ្ងៃទី២៧ ខែកុម្ភៈ និងថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២៦ ដោយមានអ្នកចូលរួមសរុបចំនួន៣០៤នាក់។

ក្នុងឱកាសនោះ **ឯកឧត្តមប្រធានស្តីទី** បាននាំនូវការផ្តាំផ្ញើសួរសុខទុក្ខពីថ្នាក់ដឹកនាំព្រឹទ្ធសភា ជូនដល់ចំពោះថ្នាក់ដឹកនាំ មន្ត្រីរាជការ កងកម្លាំងនៅមូលដ្ឋានគ្រប់លំដាប់ថ្នាក់ និងប្រជាពលរដ្ឋនៅមូលដ្ឋាន ព្រមទាំងបានជម្រាបជូនអង្គពិធីអំពីរចនាសម្ព័ន្ធ តួនាទី និងភារកិច្ចរបស់ព្រឹទ្ធសភានីតិកាលទី៥ ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា បានដាក់ចេញនូវការងារអាទិភាពចម្បងចំនួនពីរ គឺការលើកកម្ពស់ការទូតសភានិងការធ្វើការយ៉ាងជិតស្និទ្ធជាមួយអង្គបោះឆ្នោត ជាពិសេសសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដែលជាតំណាងឱ្យប្រជាពលរដ្ឋនៅមូលដ្ឋានបន្ថែមពីលើមុខងារស្នូលទាំងបីរបស់ព្រឹទ្ធសភា។




*ឯកឧត្តម ឈួន ឆាម ប្រធានស្តីទីក្រុម (កណ្តាល)*



*ទិដ្ឋភាពពិធីសំណេះសំណាលជាមួយអាជ្ញាធរ និងក្រុមប្រឹក្សាឃុំ នៅស្រុកបូរីជលសារ ខេត្តតាកែវ*



*ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥ ជួបសំណេះសំណាលជាមួយអាជ្ញាធរនិងក្រុមប្រឹក្សាសង្កាត់ នៅក្រុងដូនកែវ ខេត្តតាកែវ*

បន្ថែមពីនេះ ឯកឧត្តមក៏បានជម្រាបអំពីការខិតខំប្រឹងប្រែងអនុវត្តតួនាទី ភារកិច្ចរបស់ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥ ដោយទទួលបានសមិទ្ធផលសំខាន់ៗជាច្រើនដូចជា ការរៀបចំពិធីសំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ និងអាជ្ញាធរពាក់ព័ន្ធក្នុងភូមិភាគទី៥ សរុបចំនួន១៤លើក មានអ្នកចូលរួមសរុបចំនួន១.៣៧៩នាក់ និងបានដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្តចុះពិនិត្យព្យាបាលជំងឺជូនប្រជាពលរដ្ឋដោយមិនយកកម្រៃចំនួន៣លើក មានប្រជាពលរដ្ឋមកទទួលសេវាព្យាបាលចំនួន៨៧០នាក់។ ក្រៅពីនេះ ក្រុមភូមិភាគទី៥ បានកសាងជីកស្តារស្រះទឹកចំនួន៣៨ស្រះទឹកគិតចាប់តាំងពីឆ្នាំ២០១៦មក ហើយគិតត្រឹមឆ្នាំ២០២៤ ដល់ឆ្នាំ២០២៦នេះ បានបន្តជីកស្រះទឹកថ្មីចំនួន៥បន្ថែមទៀត។

ឯកឧត្តមបានបញ្ជាក់ថា គោលបំណងនៃពិធីសំណេះសំណាល គឺដើម្បីផ្សារភ្ជាប់ទំនាក់ទំនងឱ្យកាន់តែជិតស្និតជាមួយអាជ្ញាធរមូលដ្ឋាន ឈ្វេងយល់ការរីកចម្រើនគ្រប់វិស័យរបស់មូលដ្ឋាន អំពីបញ្ហាប្រឈមដំណោះស្រាយផ្សេងៗ និងសំណូមពរពាក់ព័ន្ធនឹងការលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ ការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព ការងារអត្តសញ្ញាណកម្មនិងអត្រានុកូលដ្ឋាន ការងារលទ្ធកម្មមូលដ្ឋាន ការងារហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន ព្រមទាំងការអនុវត្តគោលនយោបាយនិងយុទ្ធសាស្ត្រដទៃទៀតរបស់រាជរដ្ឋាភិបាល នឹងនាំយកបញ្ហាប្រឈម សំណូមពរទាំងអស់នេះ គោរពរាយការណ៍ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ដើម្បីលើកជាអនុសាសន៍ជូនក្រសួង ស្ថាប័នពាក់ព័ន្ធធ្វើការដោះស្រាយ។

**ឯកឧត្តមប្រធានស្តីទី** បានផ្តាំផ្ញើដល់ថ្នាក់ដឹកនាំក្រុង ស្រុក ក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀន និងនាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ សូមបន្តយកចិត្តទុកដាក់អនុវត្តឱ្យបានខ្ជាប់ខ្ជួននូវកិច្ចការថែរក្សាការពារសន្តិភាពក្នុងមូលដ្ឋាន បន្តបម្រើនិងផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋក្នុងមូលដ្ឋាន ឃុំ សង្កាត់របស់ខ្លួនប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព។



*ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥ ចុះពិនិត្យមើលវឌ្ឍនភាពស្រះទឹកទន្លេនាម នៅឃុំចំប៉ី ស្រុកអង្គរជ័យ ខេត្តកំពត*

ក្រៅពីជួបសំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំ ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥ បានអញ្ជើញចុះពិនិត្យមើលវឌ្ឍនភាពស្រះទឹកទន្លេនាម ស្ថិតក្នុងឃុំចំប៉ី ស្រុកអង្គរជ័យ ខេត្តកំពត ដែលជាគំនិតផ្តួចផ្តើមរបស់ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥។ នាពេលខាងមុខ ស្រះទឹកនេះគ្រោងនឹងកសាងផ្លូវបេតុងជុំវិញស្រះ ដាក់អំពូលភ្លើងសូឡា ដាំកូនឈើ និងកសាងជណ្តើរសម្រាប់ប្រជាពលរដ្ឋងាយស្រួលចុះដងទឹកយកមកប្រើប្រាស់៕

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន

# ឯកឧត្តម យស ផានីត្តា ធ្វើបទបង្ហាញជូនសាស្ត្រាចារ្យ និងនិស្សិត នៃសាកលវិទ្យាល័យ អាម៉េរិកកាំងភ្នំពេញ ក្នុងឱកាសទស្សនកិច្ចសិក្សាស្វែងយល់អំពីព្រឹទ្ធសភា



ឯកឧត្តម យស ផានីត្តា ប្រធានគណៈកម្មការទី២ព្រឹទ្ធសភា

នៅថ្ងៃសុក្រ ទី៦ ខែមីនា ឆ្នាំ២០២៦ សាស្ត្រាចារ្យ និងនិស្សិត នៃសាកលវិទ្យាល័យអាម៉េរិកកាំងភ្នំពេញចំនួន៨០នាក់ បានអញ្ជើញទស្សនកិច្ចសិក្សាស្វែងយល់អំពីព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា នៅវិមានព្រឹទ្ធសភា។ ក្នុងឱកាសមកទស្សនកិច្ចនោះ សាស្ត្រាចារ្យ និងនិស្សិត បានអញ្ជើញស្តាប់នូវការធ្វើបទបង្ហាញរបស់ឯកឧត្តម **យស ផានីត្តា** ប្រធានគណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម នៃព្រឹទ្ធសភា (គណៈកម្មការទី២) និងជាលេខាធិការក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៨ ស្តីពី សាវតារនៃការបង្កើតព្រឹទ្ធសភា រចនាសម្ព័ន្ធគ្រប់គ្រង និងដឹកនាំ តួនាទីនិងភារកិច្ចរបស់ព្រឹទ្ធសភា ព្រមទាំងការងារអាទិភាពសំខាន់ៗ របស់ព្រឹទ្ធសភានីតិកាលទី៥ ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា។

ឯកឧត្តមបានមានប្រសាសន៍អំពីសាវតាររបស់ព្រឹទ្ធសភា តាំងពីនីតិកាលទី១ ដល់នីតិកាលទី៥ ដោយនីតិកាលនីមួយៗ មានរយៈពេល៦ឆ្នាំ សមាជិកព្រឹទ្ធសភាត្រូវចាត់តាំងខ្លះ និងត្រូវជ្រើសតាំងខ្លះ ដោយការបោះឆ្នោតអសកល។ សមាជិកព្រឹទ្ធសភាមានចំនួនយ៉ាងច្រើនស្មើពាក់កណ្តាល នៃចំនួនសមាជិករដ្ឋសភា ហើយប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានអាយុយ៉ាងតិច៤០ឆ្នាំ អាចឈរឈ្មោះឱ្យគេបោះឆ្នោតជ្រើសតាំងជាសមាជិកព្រឹទ្ធសភា។ ចំពោះ ព្រឹទ្ធសភានីតិកាលទី៥នេះ ព្រឹទ្ធសភាមានសមាជិកចំនួន៦២រូប ក្នុងនោះ៥៨រូប ត្រូវបានបោះឆ្នោតជាអសកល, ២រូបត្រូវបានចាត់តាំងដោយព្រះមហាក្សត្រ និង២រូបទៀត ត្រូវបានជ្រើសតាំងដោយរដ្ឋសភា តាមមតិភាគច្រើនដោយប្រៀប។



ឯកឧត្តម យស ផានីត្តា អញ្ជើញសំណេះសំណាល និងធ្វើបទបង្ហាញ ជូននិស្សិត នៃសាកលវិទ្យាល័យអាម៉េរិកកាំងភ្នំពេញ

ឯកឧត្តមបានជម្រាបបន្ថែមថា ព្រឹទ្ធសភានីតិកាលទី៥ មានសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ជាប្រធានព្រឹទ្ធសភា ឯកឧត្តម **ប្រាក់ សុខុន** អនុប្រធានទី១ និងឯកឧត្តម **អ៊ុច បូរិទ្ធ** អនុប្រធានទី២។ ដោយមានភាពចាំបាច់ឯកឧត្តម **ប្រាក់ សុខុន** អនុប្រធានទី១ព្រឹទ្ធសភា បានផ្ទេរទៅបំពេញភារកិច្ចថ្មី ព្រឹទ្ធសភាបានបោះឆ្នោតជ្រើសរើស ឯកឧត្តម **អ៊ុច បូរិទ្ធ** ជាអនុប្រធានទី១និងឯកឧត្តមបណ្ឌិត **ធន់ វឌ្ឍនា** ជាអនុប្រធានទី២ព្រឹទ្ធសភា។

ព្រឹទ្ធសភានីតិកាលទី៥ មានថ្នាក់ដឹកនាំព្រឹទ្ធសភា គណៈកម្មាធិការអចិន្ត្រៃយ៍ គណៈកម្មការជំនាញទាំង១០ ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទាំង៨ ក្រុមសមាជិកាព្រឹទ្ធសភា ក្រុមសមាជិកព្រឹទ្ធសភា (ក្រុមនយោបាយ/ក្រុមពិភាក្សា) ក្រុមបង្គោលប្រឆាំងអំពើពុករលួយ គណៈកម្មការក្រុមសីលធម៌របស់សមាជិកព្រឹទ្ធសភា ក្រុមមិត្តភាពទ្វេភាគី និងពហុភាគី។

ព្រឹទ្ធសភាមានតួនាទីនយោបាយដ៏សំខាន់ក្នុងប្រទេស ដោយសម្របសម្រួលការងាររវាងរដ្ឋសភានិងរាជរដ្ឋាភិបាល ដើម្បីដោះស្រាយរាល់វិបត្តិនយោបាយដែលអាចកើតមានជាយថាហេតុ ទទួលខុសត្រូវខ្ពស់ក្នុងការធ្វើជាតំណាង និងការពារផលប្រយោជន៍របស់ក្រុមប្រឹក្សាឃុំសង្កាត់ និងប្រជាជនខ្មែរ។

ព្រឹទ្ធសភាមានមុខងារស្នូលចំនួន៣គឺ មុខងារនីតិកម្ម មុខងារតំណាង និងមុខងារតាមដានការអនុវត្តច្បាប់។ ក្រៅពីនេះ ព្រឹទ្ធសភាមានមុខងារគាំទ្រចំនួន២ទៀត គឺ មុខងារសហប្រតិបត្តិការអន្តរជាតិ និងមុខងារអភិវឌ្ឍន៍ស្ថាប័ន។

មុននឹងបញ្ចប់ **ឯកឧត្តមប្រធាន** បានមានមតិផ្តាំផ្ញើឱ្យនិស្សិតទាំងអស់ខិតខំសិក្សា និងយកចិត្តទុកក្នុងការដាក់ពង្រឹងសមត្ថភាពជាប្រចាំ ដើម្បីជាជំហរដ៏រឹងមាំសម្រាប់ខ្លួនឯង គ្រួសារ និងប្រទេសជាតិនាពេលអនាគត។

បន្ទាប់ពីបានស្តាប់នូវបទបង្ហាញរួចមក សាស្ត្រាចារ្យនិងនិស្សិត បានអញ្ជើញទស្សនាសាលប្រជុំពេញអង្គព្រឹទ្ធសភា និងអគារប្រវត្តិសាស្ត្រនានា នៅក្នុងបរិវេណវិមានព្រឹទ្ធសភា ព្រមទាំងថតរូបអនុស្សាវរីយ៍៕

អត្ថបទ និងរូបភាព៖ នាយកដ្ឋានព័ត៌មាន







*ទិដ្ឋភាពនិស្សិត នៃសាកលវិទ្យាល័យអាម៉េរិកកាំង ស្តាប់បទបង្ហាញ*



*ឯកឧត្តម យស ផានីត្ថា អញ្ជើញថតរូបអនុស្សាវរីយ៍*



*ទិដ្ឋភាពនិស្សិត នៃសាកលវិទ្យាល័យអាម៉េរិកកាំងទស្សនាសាលប្រជុំព្រឹទ្ធសភា*

# កិច្ចប្រជុំគណៈកម្មការទាំង១០ ក្រុមភូមិភាគ និងក្រុមនានានៃព្រឹទ្ធសភា

### ❋កិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការទី១ព្រឹទ្ធសភា ចំនួន១លើក

នាថ្ងៃទី៥ ខែមីនា ឆ្នាំ២០២៦ ឯកឧត្តម **ឌី ច័ន្ទ្រផល** ប្រធានគណៈកម្មការ បានដឹកនាំកិច្ចប្រជុំពិនិត្យពិភាក្សា



លើរបាយការណ៍ប្រចាំខែកុម្ភៈនិងទិសដៅការងារសម្រាប់ខែមីនា ឆ្នាំ២០២៦ ព្រមទាំងជួបសំណេះសំណាលជាមួយមន្ត្រីជំនួយការគណៈកម្មការទី១ ដើម្បីអបអរសាទរខួបលើកទី១១៥ ទិវាអន្តរជាតិនារី ៨មីនា ឆ្នាំ២០២៦ និងបញ្ហាផ្សេងៗ។

### ❋គណៈកម្មការទី២ព្រឹទ្ធសភា ជួបភ្ញៀវជាតិ ចំនួន១លើក



នាព្រឹកថ្ងៃចន្ទ ទី៩ ខែមីនា ឆ្នាំ២០២៦ ឯកឧត្តម **យស ផានីត្ថា** ប្រធានគណៈកម្មការ បានអនុញ្ញាតឱ្យឯកឧត្តម **ជាម សុផលមករា** អគ្គនាយក នៃអគ្គនាយកដ្ឋានព័ត៌មាន និងទំនាក់ទំនងសាធារណៈ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភានិងសហការី ចូលជួបពិភាក្សាការងារ និងទទួលអនុសាសន៍ជុំវិញការផ្តល់សេវារបស់អគ្គនាយកដ្ឋាន និងតម្រូវការរបស់គណៈកម្មការ។

### ❋កិច្ចប្រជុំផ្ទៃក្នុងក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៧ ចំនួន១លើក



នាព្រឹកថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៦ ឯកឧត្តមបណ្ឌិត **ម៉ុង ឫទ្ធី** ប្រធានក្រុម បានដឹកនាំកិច្ចប្រជុំពិភាក្សាលើការរៀបចំពិធីសំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ និងនាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ នៅក្នុងខេត្តកំពង់ស្ពឺ និងបញ្ហាផ្សេងៗ។

### ❋កិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការទី៥ព្រឹទ្ធសភា ចំនួន២លើក៖

ឯកឧត្តមបណ្ឌិត **ឈីម យីសាំង** ប្រធានគណៈកម្មការ បានដឹកនាំកិច្ចប្រជុំដូចខាងក្រោម៖



-នាព្រឹកថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២៦ ពិនិត្យនិងពិភាក្សាលើការបូកសរុបរបាយការណ៍សកម្មភាពការងារប្រចាំខែកុម្ភៈ ឆ្នាំ២០២៦ និងទិសដៅបន្ត ការត្រៀមជំនួបពិភាក្សាការងារ

ជាមួយក្រសួងព័ត៌មាន និងបញ្ហាផ្សេងៗ។



-នារសៀលថ្ងៃទី១១ ខែមីនា ឆ្នាំ២០២៦ ពិនិត្យពិភាក្សា និងស្តាប់បទបង្ហាញរបស់អគ្គនាយកដ្ឋានស្រាវជ្រាវស្តីពីឯកសារជំនួយស្មារតី និងការងាររៀបចំជំនួបពិភាក្សាជាមួយឯកឧត្តមរដ្ឋមន្ត្រីក្រសួងព័ត៌មាន កម្រងសំណួរ និងបញ្ហាផ្សេងៗ។

### ❋គណៈកម្មការទី៥ព្រឹទ្ធសភា ជួបភ្ញៀវអន្តរជាតិ ចំនួន១លើក

នាថ្ងៃចន្ទ ទី៩ ខែមីនា ឆ្នាំ២០២៦ ឯកឧត្តមបណ្ឌិត **ឈីវ យីស៊ាង** ប្រធានគណៈកម្មការ បានទទួលជួបពិភាក្សាការងារជាមួយឯកឧត្តម Yoon Ju-Duk សមាជិករដ្ឋសភាកូរ៉េ និងជាប្រធានក្រុមមិត្តភាពសភាកូរ៉េ-កម្ពុជា។

### ❋កិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការទី៦ព្រឹទ្ធសភា ចំនួន១លើក



នាព្រឹកថ្ងៃទី៦ ខែមីនា ឆ្នាំ២០២៦ លោកជំទាវបណ្ឌិត **ចាន់ សុន្ធារី** ប្រធានគណៈកម្មការ បានដឹកនាំកិច្ចប្រជុំពិនិត្យនិងពិភាក្សាលើរបាយការណ៍ស្តីពី លទ្ធផលចុះបំពេញបេសកកម្មរបស់គណៈកម្មការ ចន្លោះសម័យប្រជុំលើកទី៤ និងលើកទី៥ ព្រឹទ្ធសភានីតិកាលទី៥ និងបញ្ហាផ្សេងៗ។

### ❋កិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការទី៨ព្រឹទ្ធសភា ចំនួន១លើក

នាព្រឹកថ្ងៃពុធ ទី២៥ ខែកុម្ភៈ ឆ្នាំ២០២៦ លោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការ បានដឹកនាំកិច្ចប្រជុំពិនិត្យពិភាក្សាត្រៀមរៀបចំពិធីចុះសួរសុខទុក្ខ និងនាំយកអំណោយប្រគល់ជូនកងពលតូចអន្តរាគមន៍លេខ៩ តំបន់ប្រតិបត្តិការសឹករងព្រះវិហារ-កំពង់ធំ និងមន្ទីរពេទ្យបង្អែកជាំក្សាន្ត ខេត្តព្រះវិហារ និងបញ្ហាផ្សេងៗ។

### ❋កិច្ចប្រជុំផ្ទៃក្នុងក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៦ ចំនួន១លើក



នាព្រឹកថ្ងៃសុក្រ ទី៦ ខែមីនា ឆ្នាំ២០២៦ លោកជំទាវ **មាន សំអាន** ប្រធានក្រុម បានដឹកនាំកិច្ចប្រជុំពិនិត្យពិភាក្សានិងស្តាប់បទបង្ហាញរបស់នាយកដ្ឋានភូមិភាគ និងសមូហភាពដែនដី អំពីការចុះសិក្សាស្រាវជ្រាវប្រមូលព័ត៌មានអំពីបញ្ហាប្រឈម សំណូមពរ និងការអនុវត្តផែនការអភិវឌ្ឍន៍៥ឆ្នាំរបស់ឃុំ សង្កាត់ នៅក្នុងខេត្តព្រៃវែង និងខេត្តស្វាយរៀង និងបញ្ហាផ្សេងៗ។

### ❋កិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការទី៩ព្រឹទ្ធសភា ចំនួន២លើកៈ

ឯកឧត្តម **អ៊ុំ សារឹទ្ធ** ប្រធានគណៈកម្មការ បានដឹកនាំកិច្ចប្រជុំដូចខាងក្រោមៈ

-នាព្រឹកថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២៦ ពិនិត្យពិភាក្សាការងារការបែងចែកភារកិច្ចទទួលខុសត្រូវត្រៀមរៀបចំ



សិក្ខាសាលា ដែលរៀបចំដោយគណៈកម្មការទី៩រដ្ឋសភា ព្រឹទ្ធសភា និងក្រសួងពាក់ព័ន្ធ និងបញ្ហាផ្សេងៗ។



-នាព្រឹកថ្ងៃទី៥ ខែមីនា ឆ្នាំ២០២៦ ពិនិត្យពិភាក្សាការងារ៖ **១**-ត្រៀមចុះបេសកកម្មរបស់គណៈកម្មការទៅខេត្តស្វាយរៀង **២**-ត្រៀមចូលរួមសិក្ខាសាលា ដែលរៀបចំដោយគណៈកម្មការទី៩រដ្ឋសភា ព្រឹទ្ធសភា និងក្រសួងពាក់ព័ន្ធ នៅថ្ងៃទី១២ ខែមីនា ឆ្នាំ២០២៦ នៅវិមានរដ្ឋសភា និង**៣**-បញ្ហាផ្សេងៗ។

### ❈កិច្ចប្រជុំផ្ទៃក្នុងគណៈកម្មការទី១០ព្រឹទ្ធសភា ចំនួន១លើក



នាព្រឹកថ្ងៃចន្ទ ទី១៦ ខែមីនា ឆ្នាំ២០២៦ ឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការ បានដឹកនាំកិច្ចប្រជុំពិនិត្យសម្រេចលើសេចក្តីព្រាងរបាយការណ៍ស្តីពី សកម្មភាពលទ្ធផលការងារប្រចាំខែមីនានិងលើកទិសដៅការងារបន្ត។

### ❈កិច្ចប្រជុំផ្ទៃក្នុងក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៥ ចំនួន១លើក

នាថ្ងៃទី៥ ខែមីនា ឆ្នាំ២០២៦ ឯកឧត្តម **ឈួន ឆាម** ប្រធានស្តីទីក្រុម បានដឹកនាំកិច្ចប្រជុំពិនិត្យពិភាក្សាលើគម្រោងជួបសំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀន នាយប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ សង្កាត់ នៃក្រុងដូនកែវ និងស្រុកបូរីជលសារ ខេត្តតាកែវ នាពេលខាងមុខ និងបញ្ហាផ្សេងៗ៕

## ការទទួលពាក្យបណ្តឹង

❈ក្នុងខែមីនា ឆ្នាំ២០២៦ គណៈកម្មការទី១ព្រឹទ្ធសភា បានទទួលពាក្យបណ្តឹងចូលចំនួន៤បណ្តឹង បញ្ជូនពាក្យបណ្តឹងចេញទៅក្រសួង ខេត្ត និងស្ថាប័នពាក់ព័ន្ធចំនួន៩បណ្តឹង កំពុងពិនិត្យសិក្សាចំនួន២បណ្តឹង (សល់ពីឆ្នាំ២០២៥ ២បណ្តឹង ខែមករា ៥បណ្តឹង, ក្នុងខែកុម្ភៈ ៤បណ្តឹង) តម្កល់ទុកមិនចាត់ការចំនួន២បណ្តឹង ទទួលឯកសារជូនជ្រាបពីក្រសួងស្ថាប័នពាក់ព័ន្ធចម្លងជូនមកគណៈកម្មការចំនួន២បណ្តឹង៕

# សមាជិក សមាជិកាព្រឹទ្ធសភាបំពេញការងារនៅតាមបណ្តាភូមិភាគទាំង៨

❋ឯកឧត្តម **យស ផានីត្ថា** ប្រធានគណៈកម្មការទី២ព្រឹទ្ធសភា បានអញ្ជើញដឹកនាំប្រតិភូគណៈកម្មការព្រឹទ្ធសភា ជួបពិភាក្សាការងារជាមួយៈ



-ថ្នាក់ដឹកនាំនិយ័តករមូលបត្រកម្ពុជា ដឹកនាំដោយ ឯកឧត្តម **ស៊ូ សុជាតិ** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃនិយ័តករមូលបត្រកម្ពុជា (ន.ម.ក.) ក្នុងគោលបំណងឈ្វេងយល់អំពី វឌ្ឍនភាពការងារក្នុងវិស័យមូលបត្រកម្ពុជា ឱកាស បញ្ហាប្រឈម និងផែនការនាពេលអនាគតរបស់និយ័តករមូលបត្រកម្ពុជាទាំងរយៈពេលខ្លី និងរយៈពេលវែង នៅទីស្តីការគណៈកម្មការមូលបត្រកម្ពុជា នាព្រឹកថ្ងៃទី៣ ខែមីនា ឆ្នាំ២០២៦។

-នាយកដ្ឋានគយនិងរដ្ឋាករផែស្ងួត ដឹកនាំដោយ លោក **ភួង ណុច** ប្រធាននាយកដ្ឋាន ក្នុងគោលបំណងឈ្វេងយល់



អំពីវឌ្ឍនភាពការងាររបស់នាយកដ្ឋានគយនិងរដ្ឋាករផែស្ងួត ក្នុងឆ្នាំ២០២៥ និងដើមឆ្នាំ២០២៦ ការប្រមូលចំណូលរបស់ការិយាល័យគយនិងរដ្ឋាករផែស្ងួត **ហុង ឡេងហួរ** ក្នុងឆ្នាំ២០២៥ និងដើមឆ្នាំ២០២៦ ទិដ្ឋភាពសេដ្ឋកិច្ច សក្តានុពល បញ្ហាប្រឈមនៃការប្រមូលចំណូលក្នុងផែស្ងួត និងប្រតិបត្តិ-ការសំខាន់ៗក្នុងផែស្ងួត នៅការិយាល័យគយនិងរដ្ឋាករផែស្ងួត **ហុង ឡេងហួរ** រាជធានីភ្នំពេញ នាព្រឹកថ្ងៃទី៥ ខែមីនា ឆ្នាំ២០២៦។

-ថ្នាក់ដឹកនាំកំពង់ផែស្វយ័តភ្នំពេញ ដឹកនាំដោយ ឯកឧត្តម



**ហ៊ី ចាទី** ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជាប្រធានអគ្គនាយកដ្ឋានកំពង់ផែស្វយ័តភ្នំពេញ ក្នុងគោលបំណងឈ្វេងយល់អំពី វឌ្ឍនភាពការងាររបស់កំពង់ផែស្វយ័តភ្នំពេញ សក្តានុពល ចក្ខុវិស័យ និងផែនការអនាគត ការប្រមូលចំណូលរបស់ការិយាល័យគយនិងរដ្ឋាករប្រចាំកំពង់ផែ ក្នុងឆ្នាំ២០២៥ និងដើមឆ្នាំ២០២៦ និងទិដ្ឋភាពសេដ្ឋកិច្ចក្នុងវិស័យជាសមត្ថកិច្ចរបស់គណៈកម្មការទី២ នៅស្រុកកៀន-ស្វាយ ខេត្តកណ្តាល នាព្រឹកថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៦។

❋ឯកឧត្តមបណ្ឌិត **ម៉ុង ឫទ្ធី** ប្រធានគណៈកម្មការទី៣ព្រឹទ្ធសភា បានអញ្ជើញៈ



-ដឹកនាំក្រុមការងារបច្ចេកទេសសំណង់និងកសិកម្ម ចុះពិនិត្យក្រុមគ្រឿងចក្រដែលកំពុងសម្រុកសាងសង់គ្រឹះផ្លូវតភ្ជាប់ពីភូមិសំរោងជើងភ្នំ ឆ្ពោះទៅកាន់ភូមិមហាលំពាំងទី១ និងបន្តពិនិត្យមើលសកម្មភាពការងារសាងសង់រោងចក្រផលិតជីធម្មជាតិ ព្រមទាំងពិនិត្យមើលវត្ថុធាតុដើមសម្រាប់ផលិតជី ដែលបានដឹកជញ្ជូនចូលមកស្តុកទុកជាបន្តបន្ទាប់

នៅភូមិសំរោងជើងភ្នំ ឃុំសែនជី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៦។

-ឧបត្ថម្ភធុងដាក់ទឹកចំណុះ១.០០០លីត្រចំនួន១០ធុង និងបាយប្រអប់ចំនួន៥០កេសជូនដល់យោធាភូមិភាគទី៤



មានចំនួនពីរគោលដៅ គឺគោលដៅទី១ នៅទីចាត់ការឃោសនាព័ត៌មាន និងគោលដៅទី២ នៅបញ្ជាការដ្ឋានការពារអាកាសអគ្គបញ្ជាការ នាថ្ងៃទី៣ ខែមីនា ឆ្នាំ២០២៦។



-ទទួលដំណើរទស្សនកិច្ចរបស់អនុសាខាសមាគមនារីកម្ពុជាដើម្បីសន្តិភាព និងអភិវឌ្ឍន៍ក្រុងព្រះសីហនុ សិស្ស-និស្សិតមកពីសាលា CAM-ASEAN ចំនួន៤៥០នាក់ វិទ្យាល័យទឹកល្អក់ រាជធានីភ្នំពេញ ចំនួន១២៣នាក់ សាលា American Intercon School (AIS) ចំនួន៧០០នាក់ និងក្រុមគ្រូពេទ្យស្ម័គ្រចិត្ត ឯកឧត្តម **ហ៊ុន ម៉ានី** នៅក្នុងតំបន់រមណីយដ្ឋានអភិវឌ្ឍន៍កសិ-ទេសចរណ៍ ម៉ុង ឫទ្ធី សែនជ័យ ភូមិសំរោងជើងភ្នំ ឃុំសែនជី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាថ្ងៃទី៧ ទី៨ ទី១៣ និងថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២៦។

-ជួបសំណេះសំណាលនិងសួរសុខទុក្ខកសិករមានវ័យចំណាស់ ដែលបាននាំគ្នាទៅថែទាំនិងប្រមូលផលផ្លែត្របែក និងផ្លែដូងក្រអូប នៅក្នុងចម្ការនៃតំបន់រមណីយដ្ឋានអភិវឌ្ឍន៍កសិ-ទេសចរណ៍ ម៉ុង ឫទ្ធី សែនជ័យ នៅភូមិសំរោងជើងភ្នំ ឃុំសែនជី ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ នាថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២៦។

❈លោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការទី៨ព្រឹទ្ធសភា បានអញ្ជើញ៖



-ជួបសំណេះសំណាលជាមួយលោកគ្រូ អ្នកគ្រូ និងពិនិត្យទីតាំងអគារសិក្សាមួយកន្លែង នៅសាលាបឋមសិក្សាអំពិលក្រៅដែលមានសភាពចាស់ទ្រុឌទ្រោមខ្លាំង ដើម្បីត្រៀមរៀបចំសាងសង់ថ្មី នៅភូមិអំពិលក្រៅ ឃុំអំពិលក្រៅ ស្រុកស៊ីធរ-កណ្ដាល ខេត្តព្រៃវែង នាថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៦។

-ចុះសួរសុខទុក្ខតាមខ្នងផ្ទះប្រជាពលរដ្ឋនៅភូមិពានា និងភូមិស្វាយទាប ឃុំអំពិលក្រៅ ស្រុកស៊ីធរកណ្ដាល ខេត្តព្រៃវែង នាព្រឹកថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៦។

-ចុះសួរសុខទុក្ខតាមខ្នងផ្ទះប្រជាពលរដ្ឋចាស់ជរានិងស្ត្រីមេម៉ាយនៅភូមិអំពិលក្រៅ ឃុំអំពិលក្រៅ ស្រុកស៊ីធរកណ្ដាល ខេត្តព្រៃវែង នាថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២៦។

❈នាថ្ងៃទី៤ ខែមីនា ឆ្នាំ២០២៦ ឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការទី១០ព្រឹទ្ធសភា ឯកឧត្តម **ប្រាក់ ចំរើន** អនុប្រធានគណៈកម្មការទី៨ព្រឹទ្ធសភា និងលោកជំទាវ **សួស សារ៉ាម** សមាជិកាព្រឹទ្ធសភា បានអញ្ជើញចូលរួមជាភ្ញៀវកិត្តិយសក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការអគារមន្ទីរពេទ្យបង្អែកជ័យជំនះ ក្រុងតាខ្មៅ ខេត្តកណ្ដាល។

❈នាថ្ងៃទី១ ខែមីនា ឆ្នាំ២០២៦ ឯកឧត្តម **ឈួន ឡេង** អនុប្រធានគណៈកម្មការទី២ព្រឹទ្ធសភា បានអញ្ជើញចូលរួមប្រជុំការងាររដ្ឋបាលខេត្ត និងសម្ពោធសមិទ្ធផលជាអគាររដ្ឋបាល ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្ដេចក្រឡាហោម **ស ខេង** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា នៅខេត្តព្រៃវែង។



❈នាថ្ងៃព្រហស្បតិ៍ ទី២៦ ខែកុម្ភៈ ឆ្នាំ២០២៦ ឯកឧត្តម **ម៉ាន់ ឈឿន** អនុប្រធានគណៈកម្មការទី៧ព្រឹទ្ធសភា និងលោកជំទាវ **មុំ សណ្ដាប់** សមាជិកាគណៈកម្មការទី៦ព្រឹទ្ធសភា បានអញ្ជើញចុះពិនិត្យអគារសិក្សា១ខ្នង ដែលមានសភាពចាស់ទ្រុឌទ្រោមនិងជួបពិភាក្សាជាមួយអាជ្ញាធរមូលដ្ឋាននិងគណៈកម្មការគ្រប់គ្រងសាលារៀន គណៈនាយក លោកគ្រូ អ្នកគ្រូ នៃសាលាបឋមសិក្សាកោះដាច់ ដើម្បីពិនិត្យលទ្ធភាពជួសជុលអគារសិក្សានេះ ឬត្រូវសាងសង់ថ្មីឡើងវិញ ព្រមទាំងពិភាក្សាអំពី នីតិវិធីដែលត្រូវធ្វើបន្ត នៅភូមិកោះដាច់ សង្កាត់កោះដាច់ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។

❈ឯកឧត្តម **ម៉ាន់ ឈឿន** អនុប្រធានគណៈកម្មការទី៧ព្រឹទ្ធសភា បានអញ្ជើញ៖



-ចូលរួមប្រជុំជាមួយគណៈបញ្ជាការឯកភាពសង្កាត់ មេភូមិទាំង១៣ ដើម្បីត្រួតពិនិត្យវាយតម្លៃការអនុវត្តជាក់ស្តែង ទីតាំងដែលបានកំណត់ ក្នុងយុទ្ធនាការប្រយុទ្ធប្រឆាំងបទល្មើសឆបោកតាមប្រព័ន្ធអនឡាញ (Online Scams) ស្ថិតនៅសង្កាត់ទឹកល្អក់ទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ នាថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៦។

-ចូលរួមពិធីបុណ្យបញ្ចុះខណ្ឌសីមា និងអភិសេកព្រះពុទ្ធរូប ស្ថិតនៅវត្តចំបក់ ជើងភ្នំគិរីរម្យ ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ



នាថ្ងៃទី៧ ខែមីនា ឆ្នាំ២០២៦។



-ចូលរួមទិវាអំណានជាតិលើកទី១១ ក្រោមប្រធានបទ «សំណេរនិងអំណានក្នុងបរិបទថ្មី» ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា រាជធានីភ្នំពេញ នាថ្ងៃទី១១ ខែមីនា ឆ្នាំ២០២៦។

❈ឯកឧត្តម **គិន ណែត** លេខាធិការគណៈកម្មការទី២ព្រឹទ្ធសភា បានអញ្ជើញ៖

-ចូលរួមក្នុងកិច្ចប្រជុំផ្សព្វផ្សាយ អំពីសភាពការណ៍ទូទៅរបស់ប្រទេសជាតិ នៅសាលាខេត្តតាកែវ នាព្រឹកថ្ងៃទី១ ខែមីនា ឆ្នាំ២០២៦។

-ចូលរួមក្នុងពិធីសម្ពោធសាលាបឋមសិក្សា១ខ្នង៥បន្ទប់ និងសមិទ្ធផលនានាក្នុងវត្តឃុំឋិការនែ នៅស្រុកកោះអណ្តែត ខេត្តតាកែវ។



-ចូលរួមពិធីអបអរសាទរទិវាអន្តរជាតិនារី ៨មីនា ខួបលើកទី១១៥ ក្រោមប្រធានបទ «សន្តិភាពនិងសន្តិសុខសម្រាប់ស្ត្រី និងគ្រួសារ» នៅខេត្តតាកែវ នាព្រឹកថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៦។

-ជាអធិបតីក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងាររបស់រដ្ឋបាលឃុំក្រពុំឈូក នៅសាលាឃុំក្រពុំឈូក ខេត្តតាកែវ នាព្រឹកថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២៦។

❈ឯកឧត្តម **លេខ ទី** លេខាធិការគណៈកម្មការទី៣ ព្រឹទ្ធសភា បានអញ្ជើញ៖

-ដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាឃុំ ប្រធានភូមិ និងក្រុមការងារចុះជួយឃុំ ដើម្បីបូកសរុបលទ្ធផលការងារឆ្នាំ២០២៥និងលើកទិសដៅការងារឆ្នាំ២០២៦ នៅឃុំបវេល ស្រុកបវេល ខេត្តបាត់ដំបង នារសៀលថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០២៦។

-ចូលរួមក្នុងកិច្ចប្រជុំផ្សព្វផ្សាយសភាពការណ៍ទូទៅ និងការងារឆ្នាំ២០២៥ ព្រមទាំងលើកទិសដៅការងារឆ្នាំ២០២៦ នៅស្រុកបវេល ខេត្តបាត់ដំបង នាព្រឹកថ្ងៃទី៧ ខែមីនា ឆ្នាំ២០២៦។

❈នាថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៦ ឯកឧត្តម **លេខ ទី** លេខាធិការគណៈកម្មការទី៣ព្រឹទ្ធសភានិងឯកឧត្តមបណ្ឌិត **អ៊ុក គង់** សមាជិកគណៈកម្មការទី៦ព្រឹទ្ធសភា បានអញ្ជើញចូលរួមកិច្ចប្រជុំផ្សព្វផ្សាយសភាពការណ៍ទូទៅឆ្នាំ២០២៥ និងទិសដៅភារកិច្ចឆ្នាំ២០២៦ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម **ស ខេង** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា នៅក្រុងបាត់ដំបង ខេត្តបាត់ដំបង។

❈ឯកឧត្តម **ឆាយ ឋណ្ណា** លេខាធិការគណៈកម្មការទី៥ព្រឹទ្ធសភា បានអញ្ជើញ៖



-ចុះសួរសុខទុក្ខនិងនាំយកអំណោយចែកជូនបងប្អូនសាសនិកអ៊ិស្លាម ព្រមទាំងជួបសំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំ ស្មៀន និងនាយប៉ុស្តិ៍នគរបាលរដ្ឋបាល នៅភូមិពោធិ៍ឥន្ទឃុំកោងកាង ស្រុកពញាក្រែក ខេត្តត្បូងឃ្មុំ នាព្រឹកថ្ងៃទី៦ ខែមីនា ឆ្នាំ២០២៦។



-ចុះសួរសុខទុក្ខលោកគ្រូនិងសិស្ស នៅសាលា Sulaimanyyah ព្រមទាំងស្រាយបួសជាមួយលោកនាយកសាលា និងលោកគ្រូ នាល្ងាចថ្ងៃទី១២ ខែមីនា ឆ្នាំ២០២៦។

❈ឯកឧត្តមបណ្ឌិត **គឹម ឆា** លេខាធិការគណៈកម្មការទី៦ព្រឹទ្ធសភា បានអញ្ជើញ៖



-ជាអធិបតីក្នុងពិធីអបអរសាទរទិវាអន្តរជាតិនារី ៨មីនា ខួបលើកទី១១៥ ឆ្នាំ២០២៦ ក្រោមប្រធានបទ «សន្តិភាពនិងសន្តិសុខសម្រាប់ស្ត្រី និងគ្រួសារ» នៅសាលាបឋមសិក្សាកន្ទុយវែ ស្ថិតក្នុងភូមិចំបក់ សង្កាត់ចេក ក្រុងស្វាយរៀង ខេត្តស្វាយរៀង នាថ្ងៃទី៨ ខែមីនា ឆ្នាំ២០២៦។



-ចូលរួមជាមួយអង្គការមូលនិធិរ៉ូតថារី នៅកម្ពុជា ដែលដឹកនាំដោយក្រុមគ្រូពេទ្យសប្បុរសធម៌ប៉ាយសួយឡាវយិន នៅកម្ពុជា ចុះពិនិត្យព្យាបាលជំងឺទូទៅជូនប្រជាពលរដ្ឋចំនួន១.៥០០នាក់ នៅស្រុករំដួល ខេត្តស្វាយរៀង នាថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២៦។



❈នាថ្ងៃសៅរ៍ ទី២៨ ខែកុម្ភៈ ឆ្នាំ២០២៦ ឯកឧត្តម **ឈើយ ចាន់ណា** លេខាធិការគណៈកម្មការទី៧ព្រឹទ្ធសភា ឯកឧត្តម **អន ស៊ុំ** សមាជិកព្រឹទ្ធសភា បានអញ្ជើញចូលរួមពិធីសំណេះសំណាលសួរសុខទុក្ខនិងចែកគ្រឿងឧបភោគ បរិភោគ ព្រមទាំងឧបត្ថម្ភថវិកាមួយចំនួនជូនប្រជាពលរដ្ឋភៀសសឹកចំនួន១.៦៨៦គ្រួសារ ដែលរងផលប៉ះពាល់ដោយការឈ្លានពានតាមបណ្តោយព្រំដែនកម្ពុជា-ថៃ ពីសំណាក់យោធាថៃ នៅវត្តកណ្តោល ឃុំគោករមៀត ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ។

❈នាព្រឹកថ្ងៃសុក្រ ទី១៣ ខែមីនា ឆ្នាំ២០២៦ ឯកឧត្តម **ឈើយ ចាន់ណា** លេខាធិការគណៈកម្មការទី៧ព្រឹទ្ធសភា បានអញ្ជើញចូលរួមពិធីសំណេះសំណាលសួរសុខទុក្ខ និងចែកគ្រឿងឧបភោគ បរិភោគ ជូនប្រជាពលរដ្ឋភៀសសឹក



ចំនួន៣.០០០គ្រួសារ ដែលរងផលប៉ះពាល់ដោយការឈ្លានពានតាមបណ្តោយព្រំដែនកម្ពុជា-ថៃ ពីសំណាក់យោធាថៃ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចក្រឡាហោម **ស ខេង** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា នៅសាលាខេត្តបន្ទាយមានជ័យ។

❈នាថ្ងៃព្រហស្បតិ៍ ទី១៩ ខែមីនា ឆ្នាំ២០២៦ ឯកឧត្តម **ឈើយ ចាន់ណា** លេខាធិការគណៈកម្មការទី៧ព្រឹទ្ធសភា



ឯកឧត្តមបណ្ឌិត **អ៊ុក គង់** សមាជិកគណៈកម្មការទី៦ព្រឹទ្ធសភា និងឯកឧត្តម **អន ស៊ុំ** សមាជិកព្រឹទ្ធសភា បានអញ្ជើញចុះសួរសុខទុក្ខឯកឧត្តម **ឆាត់ ឈឿម** ទីប្រឹក្សាសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និងជាអតីតប្រធានក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៤ នៅគេហដ្ឋាន ក្រុងសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ។

❈លោកជំទាវ **ឃួន យុនឌី** លេខាធិការគណៈកម្មការទី៨ព្រឹទ្ធសភា បានអញ្ជើញ៖

-ជួបសំណេះសំណាលនិងជូនវត្ថុអនុស្សាវរីយ៍ដល់លោកគ្រូ អ្នកគ្រូ សាលាបឋមសិក្សាកំពង់ធំ ចំនួន២៣នាក់ នៅសណ្ឋាគារកំពង់ធំរ៉ូយ៉ាល់ ខេត្តកំពង់ធំ នាថ្ងៃទី១ ខែមីនា ឆ្នាំ២០២៦។



-ជួបសំណេះសំណាលនិងចែកអំណោយជូនដល់គ្រួសារកងទ័ព ព្រមទាំងជនភៀសសឹកមកស្នាក់នៅបណ្តោះអាសន្ន

ក្នុងស្រុកកំពង់ស្វាយ ចំនួន១០៦គ្រួសារ នៅសាលាស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ នាថ្ងៃទី២ ខែមីនា ឆ្នាំ២០២៦។

❋ឯកឧត្តម **លី សារី** សមាជិកគណៈកម្មការទី១ព្រឹទ្ធសភា បានអញ្ជើញ៖



-ជាគណៈអធិបតីក្នុងពិធីសំណេះសំណាល និងចែកកញ្ចប់អាហារសម្រាប់បួសខែរ៉ាម៉ាឌន ជូនប្រជាពលរដ្ឋ ដែលមកពីភូមិនានា ក្នុងឃុំព្រៃកឃ្មុំ ឃុំកំពង់ក្រែង ស្រុកទឹកឈូ ខេត្តកំពត នាព្រឹកថ្ងៃទី២៦ ខែកុម្ភៈ និងថ្ងៃទី៨ ទី១០ ខែមីនា ឆ្នាំ២០២៦។



-ជាអធិបតីក្នុងពិធីចែកអាល់គួរអានបកប្រែជាភាសាខ្មែរនិងពិធីចែកកញ្ចប់ផ្លែល្មើជូនថ្នាក់ដឹកនាំអ៊ិស្លាម និងគ្រូបង្រៀនសម្រាប់ប្រើប្រាស់ និងជាអាហារស្រោយបួសខែរ៉ាម៉ាឌន នៅទីស្នាក់ការគណៈអ៊ីមុាំខេត្តកំពត ក្នុងភូមិកំពង់កែស ឃុំត្រពាំងសង្កែ ស្រុកទឹកឈូ ខេត្តកំពត នាព្រឹកថ្ងៃទី៨ ខែមីនា ឆ្នាំ២០២៦។

❋នាព្រឹកថ្ងៃទី១ និងថ្ងៃទី១៤ ខែមីនា ឆ្នាំ២០២៦ ឯកឧត្តម **គង់ មុនីកា** សមាជិកគណៈកម្មការទី១ព្រឹទ្ធសភា បានអញ្ជើញជួបសំណេះសំណាលនិងស្តាប់បញ្ហាប្រឈមរបស់បងប្អូនប្រជាពលរដ្ឋ នៅភូមិទ្រា ឃុំសេនារាជឧត្តម ស្រុកព្រះស្តេច ភូមិបទសន្ទ្រា ឃុំកំពង់ពពិល ស្រុកពារាំង និងឃុំរំលេច ស្រុកស៊ីធរកណ្តាល ខេត្តព្រៃវែង។

❋លោកជំទាវបណ្ឌិត **អ៊ុក ម៉ាលី** សមាជិកាគណៈកម្មការទី២ព្រឹទ្ធសភា បានអញ្ជើញ៖

-ចូលរួមពិធីបុណ្យឆ្លងសាលាបុណ្យ និងអភិសេកផ្ទាំងគំនូរសាលាបុណ្យ ដើម្បីឧទ្ទិសមហាកុសលផលបុណ្យជូនដួងវិញ្ញាណក្ខន្ធ អ្នកឧកញ៉ា មហាឧបាសិកាធម្មញាណវិវឌ្ឍនា **ប៊ុន ស៊ាងលី** និងឧទ្ទិសមហាកុសលជូនមហាឧបាសក **លីន គ្រី** ដែលត្រូវជាមាតា បិតាក្មេកសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** និងជាមាតាបិតាបង្កើតសម្តេចកិត្តិព្រឹទ្ធបណ្ឌិត **ប៊ុន រ៉ានី ហ៊ុនសែន** នៅស្រុកក្រូចឆ្មារ ខេត្តត្បូងឃ្មុំ នាថ្ងៃទី២ និងថ្ងៃទី៣ ខែមីនា ឆ្នាំ២០២៦។



-ចូលរួមពិធីទទួលនូវព្រះរាជទ្រព្យដ៏ឧត្តុង្គឧត្តមរបស់ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចព្រះមហាក្សត្រី **នរោត្តម មុនិនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត ចំនួន១០០.០០០$ (ដប់ម៉ឺនដុល្លារអាមេរិក) ជូនកាកបាទក្រហមកម្ពុជា ក្នុងឱកាសខួបទី១៦៣ ទិវាពិភពលោកកាកបាទក្រហមនិងអឌ្ឍចន្ទក្រហម ៨ ឧសភា ២០២៦ នៅទីស្នាក់ការកណ្តាលកាកបាទក្រហមកម្ពុជា នាថ្ងៃទី៦ ខែមីនា ឆ្នាំ២០២៦។

❋នាថ្ងៃទី១ ខែមីនា ឆ្នាំ២០២៦ ឯកឧត្តម **សត ណាឌី** សមាជិកគណៈកម្មការទី៤ព្រឹទ្ធសភា និងលោកជំទាវ **ឯម ផលាមុនី** សមាជិកាគណៈកម្មការទី១០ព្រឹទ្ធសភា បានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងារឆ្នាំ២០២៥ របស់ក្រុមការងារចុះមូលដ្ឋានខេត្តសៀមរាប និងទិសដៅការងារឆ្នាំ២០២៦ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចពិជ័យសេនា **ទៀ បាញ់** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា នៅខេត្តសៀមរាប។

❋នាថ្ងៃចន្ទ ទី១៦ ខែមីនា ឆ្នាំ២០២៦ លោកជំទាវ





**ចឹក ហេង** សមាជិកាគណៈកម្មការទី៤ព្រឹទ្ធសភា បានអញ្ជើញជួបសំណេះសំណាលនិងពិភាក្សាការងារជាមួយក្រុមប្រឹក្សាឃុំលំជ័រ ឃុំប៉ាតតេ ឃុំប៉ក់ញៃ និងឃុំសេសាន ស្មៀន និងនាយប៉ុស្តិ៍នគរបាលរដ្ឋបាល ដើម្បីឈ្វេងយល់អំពីការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ បញ្ហាប្រឈម និងសំណូមពរ នៅស្រុកអូរយ៉ាដាវ ខេត្តរតនគិរី។

❋នាថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២៦ ឯកឧត្តម **សាយ បូរិន** សមាជិកគណៈកម្មការទី៥ព្រឹទ្ធសភា បានអញ្ជើញចូលរួមកម្មវិធីផ្តល់អាហារតាមសាលារៀនដោយប្រើប្រាស់កសិផលក្នុងសហគមន៍ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់លោកជំទាវបណ្ឌិត **ពេជ ចន្ទមុន្នី ហ៊ុនម៉ាណែត** នៅសាលាបឋមសិក្សាប្រាសាទដាងទង ស្ថិតក្នុងភូមិគ្រាំងប្រស្វាយ ឃុំស្វាយជ្រុំ ស្រុករលាប្អៀរ ខេត្តកំពង់ឆ្នាំង។



❋នាព្រឹកថ្ងៃសៅរ៍ ទី១៤ ខែមីនា ឆ្នាំ២០២៦ ឯកឧត្តម **សាយ បូរិន** សមាជិកគណៈកម្មការទី៥ព្រឹទ្ធសភា និង ឯកឧត្តម **អ៊ឹង លាងហ៊ួ** សមាជិកគណៈកម្មការទី៧ព្រឹទ្ធសភា បានអញ្ជើញជួបសំណេះសំណាលសួរសុខទុក្ខក្រុមប្រឹក្សាឃុំកំពង់អុស ស្មៀនឃុំ ប៉ុស្តិ៍នគរបាលរដ្ឋបាល នៅស្រុកជលគីរី ខេត្តកំពង់ឆ្នាំង។

❋នារសៀលថ្ងៃសុក្រ ទី១៣ ខែមីនា ឆ្នាំ២០២៦ លោកជំទាវ **មុំ សណ្ណាប់** សមាជិកាគណៈកម្មការទី៦ព្រឹទ្ធសភា បានអញ្ជើញជួបសំណេះសំណាលជាមួយសមាជិក (ជាមេគ្រួសារ) នៅក្នុងភូមិ៥ សរុបចំនួន១០គ្រួសារ ស្មើនឹងសមាជិក៥០នាក់ និងបានឧបត្ថម្ភថវិកាមួយចំនួនជូនដល់សមាជិកចូលរួម នៅសង្កាត់ផ្សារដើមថ្កូវ ខណ្ឌចំការមន រាជធានីភ្នំពេញ។

❋ឯកឧត្តម **អ៊ឹង លាងហ៊ួ** សមាជិកគណៈកម្មការទី៧ព្រឹទ្ធសភា បានអញ្ជើញ៖

-ជួបសំណេះសំណាលជាមួយក្រុមប្រឹក្សាឃុំ ដើម្បីពិនិត្យវឌ្ឍនភាពការងារនិងទិសដៅការងារបន្ត នៅឃុំព្រៃគ្រី ស្រុកជលគីរី ខេត្តកំពង់ឆ្នាំង នាថ្ងៃទី៧ ខែមីនា ឆ្នាំ២០២៦។



-ចូលរួមកម្មវិធីប្រគល់ថវិកាដ៏ថ្លៃថ្លារបស់សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី ជូនគ្រួសារវីរកងទ័ពពលីក្នុងសមរភូមិមុខ នៅសាលាខេត្តកំពង់ឆ្នាំង នាថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២៦។

❋លោកជំទាវ **ឯម ផលាមុនី** សមាជិកាគណៈកម្មការទី១០ព្រឹទ្ធសភា បានអញ្ជើញ៖

-នាំយកថវិកាមួយចំនួនចូលបច្ច័យបុណ្យផ្កាប្រាក់សាមគ្គី នៅវត្តគោកធ្លក ស្ថិតក្នុងបរិវេណអង្គរធំ សង្កាត់នគរធំ ក្រុងសៀមរាប ខេត្តសៀមរាប នាថ្ងៃទី២ ខែមីនា ឆ្នាំ២០២៦។

-ជាអធិបតីក្នុងពិធីអបអរសាទរ ៨មីនា ខួបលើកទី១១៥ ក្រោមប្រធានបទ «សន្តិភាព និងសន្តិសុខសម្រាប់ស្ត្រី និងគ្រួសារ» នៅស្រុកប្រាសាទបាគង ខេត្តសៀមរាប នាថ្ងៃទី៧ ខែមីនា ឆ្នាំ២០២៦៕

# សមាជិក សមាជិកាព្រឹទ្ធសភាចូលរួមក្នុងពិធីផ្សេងៗ

❈នាព្រឹកថ្ងៃ១២ ខែមីនា ឆ្នាំ២០២៦ សមាជិក សមាជិកាព្រឹទ្ធសភា ចំនួន២៩រូប បានអញ្ជើញចូលរួមសិក្ខាសាលាស្ដីពី «ការពង្រឹងភាពធន់ជាតិ និងកាលានុវត្តភាពនៃយុទ្ធសាស្ត្រអភិបាលកិច្ចវិទ្យាសាស្ត្រ បច្ចេកវិទ្យា នវានុវត្តន៍ ឧស្សាហកម្ម និងពាណិជ្ជកម្មកម្ពុជា» ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្ដេចមហារដ្ឋសភាធិការធិបតី **ឃួន សុដារី** ប្រធានរដ្ឋសភា នៅវិមានរដ្ឋសភា។



❈នារសៀលថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២៦ សមាជិក សមាជិកាព្រឹទ្ធសភាចំនួន១០រូប បានអញ្ជើញចូលរួមពិធីទិវាប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ក្រោមអធិបតីភាពឯកឧត្តមអភិសន្តិបណ្ឌិត **ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ។



❈នាថ្ងៃទី៦ ខែមីនា ឆ្នាំ២០២៦ សមាជិក សមាជិកាព្រឹទ្ធសភាចំនួន៨រូប បានអញ្ជើញចូលរួមពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២៥ និងលើកទិសដៅការងារឆ្នាំ២០២៦ របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងផ្សព្វផ្សាយផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី១១ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្ដេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅសណ្ឋាគាររ៉េស៊ីដង់សុខាភ្នំពេញ។

❈នារសៀលថ្ងៃទី៦ ខែមីនា ឆ្នាំ២០២៦ ឯកឧត្តមបណ្ឌិត **ឈឹម ឃីស៊ាង** ប្រធានគណៈកម្មការទី៥ព្រឹទ្ធសភា បានអញ្ជើញចូលរួមសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២៥ និងលើកទិសដៅការងារឆ្នាំ២០២៦ ព្រមទាំងបានបំពាក់គ្រឿងឥស្សរិយយសជូនថ្នាក់ដឹកនាំ និងមន្ត្រីរាជការ ក្រោមអធិបតីភាពឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ប្រាក់ សុខុន** រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៅទីស្ដីការក្រសួង។

❈នាថ្ងៃទី១៥ ខែមីនា ឆ្នាំ២០២៦ លោកជំទាវបណ្ឌិត **ចាន់ សុទ្ធាវី** ប្រធានគណៈកម្មការទី៦ព្រឹទ្ធសភា បានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការអគារទីស្នាក់ការនិងសមិទ្ធផលនានា ស្ថិតក្នុងក្រុងសំពៅពូន ខេត្តកណ្ដាល។

❈លោកជំទាវ **មាន សំអាន** ប្រធានគណៈកម្មការទី៨ព្រឹទ្ធសភា បានអញ្ជើញ៖

-ចូលរួមពិធីបូកសរុបលទ្ធផលការងារឆ្នាំ២០២៥ និងទិសដៅការងារឆ្នាំ២០២៦ របស់ក្រសួងសង្គមកិច្ច អតីត

យុទ្ធជន និងយុវនារីតិសម្បទា ក្រោមអធិបតីភាពឯកឧត្តម សន្តិបណ្ឌិត **នេត សាវឿន** នាយករដ្ឋមន្ត្រីស្តីទី នៃព្រះរាជាណាចក្រកម្ពុជា នៅទីស្តីការក្រសួង នាព្រឹកថ្ងៃពុធ ទី២៥ ខែកុម្ភៈ ឆ្នាំ២០២៦។




-ចូលរួមពិធីអបអរសាទរទិវាអន្តរជាតិនារី ៨មីនា ២០២៦ ខួបលើកទី១១៥ ក្រោមប្រធានបទ «សន្តិភាពនិងសន្តិសុខសម្រាប់ស្ត្រី និងគ្រួសារ» និងពិធីប្រកាសទទួលស្គាល់ការកែសម្រួល និងបំពេញបន្ថែមសមាសភាពគណៈកម្មការសាខាសមាគមនារីកម្ពុជាដើម្បីសន្តិភាព និងអភិវឌ្ឍន៍ ក្រសួងអធិការកិច្ច នៅទីស្តីការក្រសួងអធិការកិច្ច នាព្រឹកថ្ងៃទី៤ ខែមីនា ឆ្នាំ២០២៦។

-ចូលរួមពិធីអបអរសាទរទិវាអន្តរជាតិនារី ៨មីនា ២០២៦ ខួបលើកទី១១៥ ក្រោមប្រធានបទ «សន្តិភាពនិងសន្តិសុខសម្រាប់ស្ត្រី និងគ្រួសារ» និងពិធីប្រកាសទទួលស្គាល់ការកែសម្រួល និងបំពេញបន្ថែមសមាសភាពគណៈកម្មការ



សាខាសមាគមនារីកម្ពុជា ដើម្បីសន្តិភាព និងអភិវឌ្ឍន៍ ក្រសួងធនធានទឹក និងឧតុនិយម នៅសណ្ឋាគារ Raffles Hotel Le Royal Phnom Penh នាព្រឹកថ្ងៃទី៥ ខែមីនា ឆ្នាំ២០២៦។



-ដឹកនាំក្រុមសមាជិកាព្រឹទ្ធសភា ចូលរួមក្នុងពិធីអបអរសាទរទិវាអន្តរជាតិនារី ៨មីនា ខួបលើកទី១១៥ ឆ្នាំ២០២៦ ក្រោមប្រធានបទ «សន្តិភាពនិងសន្តិសុខសម្រាប់ស្ត្រី និងគ្រួសារ» និងសន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ ២០២៥ និងលើកទិសដៅបន្តឆ្នាំ២០២៦ របស់សាខាសមាគមនារីកម្ពុជា ដើម្បីសន្តិភាព និងអភិវឌ្ឍន៍ខេត្តកំពត ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ និងជាប្រធានសមាគមនារីកម្ពុជា ដើម្បីសន្តិភាព និងអភិវឌ្ឍន៍ នៅខេត្តកំពត នាព្រឹកថ្ងៃទី៧ ខែមីនា ឆ្នាំ២០២៦។

-ដឹកនាំក្រុមសមាជិកាព្រឹទ្ធសភា និងក្រុមសមាជិក



ព្រឹទ្ធសភាប្រចាំភូមិភាគទី៦ ចូលរួមសំណេះសំណាលសួរសុខទុក្ខ និងនាំយកអំណោយជូនកងពលតូចអន្តរាគមន៍លេខ៩ និងតំបន់ប្រតិបត្តិការសឹករងព្រះវិហារ-កំពង់ធំ និងអបអរសាទរខួបអនុស្សាវរីយ៍ លើកទី១១៥ ទិវាអន្តរជាតិនារី ៨មីនា ឆ្នាំ២០២៦ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា នៅខេត្តព្រះវិហារ និងបន្តអមដំណើរសម្តេចកិត្តិសង្គហបណ្ឌិត ចុះសួរសុខទុក្ខ ព្រមទាំងនាំយកថវិកា និងសម្ភារៈប្រើប្រាស់ចែកជូនរីកងទ័ពនិងប្រជាពលរដ្ឋ ដែលកំពុងសម្រាកព្យាបាលជំងឺនៅមន្ទីរពេទ្យបង្អែកស្រុកជាំក្សាន្ត ខេត្តព្រះវិហារ នាព្រឹកថ្ងៃទី៩ ខែមីនា ឆ្នាំ២០២៦។




❉នាថ្ងៃទី៧ ខែមីនា ឆ្នាំ២០២៦ ឯកឧត្តម **ម៉ម ប៊ុននាង** ប្រធានគណៈកម្មការទី១០ព្រឹទ្ធសភា បានអញ្ជើញទទួលអំណោយមនុស្សធម៌លើកទី១៧ របស់មូលនិធិចែករំលែកសង្គ្រោះជីវិតសកល នៃសាធារណរដ្ឋកូរ៉េ ដែលរួមមាន ឱសថ សម្ភារៈវេជ្ជសាស្ត្រ និងសម្ភារៈប្រើប្រាស់ប្រចាំថ្ងៃ នៅវិមានព្រឹទ្ធសភា។

❉នាល្ងាចថ្ងៃសុក្រ ទី២៧ ខែកុម្ភៈ ឆ្នាំ២០២៦ ឯកឧត្តម **ឆាយ វណ្ណា** លេខាធិការគណៈកម្មការទី៥ព្រឹទ្ធសភា បានអញ្ជើញចូលរួមអាហារស្រាយបួស នៅស្ថានទូតម៉ាឡេស៊ី។





❉នាថ្ងៃព្រហស្បតិ៍ ទី២៦ ខែកុម្ភៈ ឆ្នាំ២០២៦ ឯកឧត្តម **អ៊ឹង លាងហ៊ួ** សមាជិកគណៈកម្មការទី៧ព្រឹទ្ធសភា បានអញ្ជើញចូលរួមពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២៥ និងលើកទិសដៅការងារឆ្នាំ២០២៦ របស់ក្រសួងធម្មការ និងសាសនា ក្រោមអធិបតីភាពឯកឧត្តម **ឆាយ បូរិន** រដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា នៅសាលសន្និសីទចតុម្មុខ រាជធានីភ្នំពេញ។

❉នាថ្ងៃសៅរ៍ ទី២៨ ខែមីនា ឆ្នាំ២០២៦ សម្តេចរាជបុត្រី ព្រះអនុជ **នរោត្តម អរុណរស្មី** សមាជិកាគណៈកម្មការទី១០ព្រឹទ្ធសភា បានយាងជង្ហែព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត យាងទៅពិនិត្យព្រះរាជសុខភាពនៅរដ្ឋធានីប៉េកាំង នៃសាធារណរដ្ឋប្រជាមានិតចិន នៅអាកាសយានដ្ឋានអន្តរជាតិតេជោ៕

# សកម្មភាពថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចូលរួមពិធីផ្សេងៗ



❈នារសៀលថ្ងៃទី២៧ ខែកុម្ភៈ និងថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២៦ ឯកឧត្តម **ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា និងជាសមាជិកក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ បានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំក្រុមប្រឹក្សាជាតិប្រឆាំងអំពើពុករលួយ (ក.ជ.ប.ព.) លើកទី៧ និងលើកទី៨ អាណត្តិទី៤ នៅអង្គភាពប្រឆាំងអំពើពុករលួយ។

❈នារសៀលថ្ងៃចន្ទ ទី២ ខែមីនា ឆ្នាំ២០២៦ ឯកឧត្តម **ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញដឹកនាំកិច្ចប្រជុំចង្អៀត ស្ដីពីការរៀបចំការងារប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងការប្រគល់សិទ្ធិលើកិច្ចការងារមួយចំនួនដល់អគ្គនាយកដ្ឋាននីមួយៗ ដើម្បីបង្កើនប្រសិទ្ធភាពការងារនិងការទទួលខុសត្រូវ ព្រមទាំងពិភាក្សាលើការងារត្រៀមរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២៥ និងទិសដៅការងារឆ្នាំ២០២៦ និងការងារសំខាន់ៗ នាពេលខាងមុខ នៅបន្ទប់ប្រជុំរបស់ឯកឧត្តមអគ្គលេខាធិការ វិមានសាមគ្គីភាព នៃព្រឹទ្ធសភា។





❈នារសៀលថ្ងៃពុធ ទី១៨ ខែមីនា ឆ្នាំ២០២៦ ឯកឧត្តម **ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញដឹកនាំកិច្ចប្រជុំចង្អៀត ដើម្បីពិនិត្យលើបច្ចុប្បន្នភាពគេហទំព័រព្រឹទ្ធសភា ក្នុងទម្រង់រូបរាងថ្មី និងការរៀបចំមាតិកាបន្ថែមឱ្យស្របទៅតាមបរិបទ និងការវិវត្តថ្មីៗ នៃព្រឹទ្ធសភានីតិកាលទី៥ ការរៀបចំសម្របសម្រួលការអញ្ជើញចុះបំពេញមុខងារតំណាងរបស់ថ្នាក់ដឹកនាំព្រឹទ្ធសភា ការរៀបចំពិធីសិក្ខាសាលា និងកិច្ចប្រជុំគណៈកម្មការនយោបាយ APF នៅខេត្តសៀមរាប ព្រមទាំងការត្រៀមលក្ខណៈធ្វើជាម្ចាស់ផ្ទះកិច្ចប្រជុំប្រចាំឆ្នាំនៃសន្និសីទប្រធានសភា នៃអន្តរសភា(ISC)នៅកម្ពុជា នាពេលខាងមុខ នៅបន្ទប់ប្រជុំរបស់ឯកឧត្តមអគ្គលេខាធិការ វិមានសាមគ្គីភាព នៃព្រឹទ្ធសភា។

❈នាព្រឹកថ្ងៃពុធ ទី២៥ ខែមីនា ឆ្នាំ២០២៦ ឯកឧត្តម **ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានអញ្ជើញចុះពិនិត្យទីតាំងដោយផ្ទាល់សម្រាប់ត្រៀមរៀបចំការដ្ឋានសាងសង់អគារថ្មីនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងអញ្ជើញពិនិត្យបច្ចុប្បន្នភាពគុណភាព និងសោភ័ណភាពសំណង់អគារនានាស្ថិតក្នុងបរិវេណវិមានព្រឹទ្ធសភា។



# សកម្មភាពថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចូលរួមពិធីផ្សេងៗ



❈នាព្រឹកថ្ងៃអង្គារ ទី៣ ខែមីនា ឆ្នាំ២០២៦ ឯកឧត្តម **ខេង សិទ្ធិគុណា** អគ្គលេខាធិការរងព្រឹទ្ធសភា និងឯកឧត្តម **ទុយ រី** នាយកខុទ្ទកាល័យឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា តំណាងដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **អ៊ុច បូរិទ្ធ** ប្រធានស្ដីទីព្រឹទ្ធសភា និងឯកឧត្តម **ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញគោរពវិញ្ញាណក្ខន្ធសព ឯកឧត្តម **មុំ អេឆម** ទីប្រឹក្សារាជរដ្ឋាភិបាល និងត្រូវជាឪពុកបង្កើតរបស់ឯកឧត្តម **មុំ រ៉ាទីន** នាយករងខុទ្ទកាល័យឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា នៅសង្កាត់ស្វាយរៀង ក្រុងស្វាយរៀង ខេត្តស្វាយរៀង។

❈នាថ្ងៃទី៣ ខែមីនា ឆ្នាំ២០២៦ ឯកឧត្តម **ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញជាអធិបតីក្នុងកិច្ចប្រជុំបូកសរុបលទ្ធផលការងាររបស់អគ្គនាយកដ្ឋានសេវាច្បាប់ និងសមូហភាពដែនដី និងអគ្គនាយកដ្ឋានស្រាវជ្រាវ ប្រចាំខែកុម្ភៈ និងកំណត់ទិសដៅការងារខែមីនា ឆ្នាំ២០២៦ នៅសាលប្រជុំពិសេសក្រោម វិមានព្រឹទ្ធសភា។





❈នាថ្ងៃទី៦ ខែមីនា ឆ្នាំ២០២៦ ឯកឧត្តម **អេឆ បូរ៉ា** អគ្គលេខាធិការរងព្រឹទ្ធសភា និងជាអនុប្រធានគណៈកម្មាធិការលទ្ធកម្ម តំណាងរបស់ឯកឧត្តម **ឡាយ សំកុល** អគ្គលេខាធិការ និងជាប្រធានគណៈកម្មាធិការលទ្ធកម្មនៃព្រឹទ្ធសភា បានអញ្ជើញជាអធិបតីក្នុងពិធីដេញថ្លៃស្ដីពី ការផ្គត់ផ្គង់ប្រេងឥន្ធនៈរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា សម្រាប់ឆ្នាំ២០២៦ នៅសាលប្រជុំពិសេសក្រោម វិមានព្រឹទ្ធសភា។

❈នាថ្ងៃព្រហស្បតិ៍ ទី៥ ខែមីនា ឆ្នាំ២០២៦ ឯកឧត្តម **ម៉ុន ឌុន្នា** អគ្គនាយក នៃអគ្គនាយកដ្ឋានសេវាច្បាប់និងសមូហភាពដែនដី បានអញ្ជើញជួបប្រជុំជាមួយគ្រូបង្រៀនផ្នែកនីតិសាស្ត្រ និងបុគ្គលិកអប់រំ នៃសាកលវិទ្យាល័យជាតិបាត់ដំបង ដឹកនាំដោយលោក **ខ៉ុយ ឈាន់** ប្រធានគ្រូបង្រៀនផ្នែកនីតិសាស្ត្រ ដើម្បីស្វែងយល់អំពីនីតិវិធីនៃដំណើរការធ្វើច្បាប់របស់ព្រឹទ្ធសភា នៅសាលប្រជុំពិសេសក្រោម វិមានព្រឹទ្ធសភា។



សូមស្កេន QR Code
ដើម្បីចូលទៅកាន់បណ្តាញសង្គមព្រឹទ្ធសភា

**Senate of Cambodia**

វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ
ទូរសព្ទ៖ (855) 23 211 411, 211 422, 211 443
ទូរសារ៖ (855) 23 211 446
E-mail: secretariat@senate.gov.kh